ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា





កំណែទម្រង់ឧត្តមសិក្សា
ឆ្ពោះតបនឹង
ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០

កញ្ញា ២០២៦



ទស្សនវិស័យ

«ប្រទេសមួយ ដែលអាចអភិវឌ្ឍបាន គឺមានឧត្តមសិក្ខាខ្លាំង!»

*ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី*
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២៥

«ការរីកចម្រើននៃសេដ្ឋកិច្ច ដោយគ្មានការវិនិយោគលើ
ការអភិវឌ្ឍមនុស្ស គឺមិនមានន័យរួតរាល!»

Amartya Sen, ពានរង្វាន់ណូបែលផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ១៩៩៨

«មូលធនមនុស្ស មានគុណភាពខ្ពស់ និង សុខភាពល្អ ជាទ្រព្យសកម្មជាតិ
ដ៏រឹងមាំសម្រាប់បង្កើនតម្លៃសេដ្ឋកិច្ច លើកកម្ពស់តម្លៃវប្បធម៌ និង បង្កើត
គំនិតថ្មីៗ សំដៅធានាចីរភាពកំណើនរយៈពេលវែង និង ជវភាព នៃការ
អភិវឌ្ឍសង្គម-សេដ្ឋកិច្ច។»

ពជរង្គាកិបាលកម្ពុជា, យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, ២០២៣

មាតិកា

១. សេចក្តីផ្តើម 1

២. ការអនុវត្តយុទ្ធសាស្ត្រ និង កម្មវិធីវិនិយោគលើកំណែទម្រង់ឧត្តមសិក្សា 2

២.១. យុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សា 2

២.២. កម្មវិធីវិនិយោគលើកំណែទម្រង់ឧត្តមសិក្សា 4

៣. លទ្ធផលសម្រេចបាន 6

៣.១. ផ្នែកបរិមាណវិស័យ 6

៣.២. ផ្នែកគុណវិស័យ 7

៤. ការប្រឈម 15

៥. ដំណោះស្រាយ 15

៦. សេចក្តីសន្និដ្ឋាន 16

៧.ឧបសម្ព័ន្ធ៖ របាយការណ៍វឌ្ឍនភាពរបស់គ្រឹះស្ថានឧត្តមសិក្សា 17

ឧបសម្ព័ន្ធ១៖សាកលវិទ្យាល័យភូមិន្ទភ្នំពេញ 17

ឧបសម្ព័ន្ធ២៖ សាកលវិទ្យាល័យជាតិគ្រប់គ្រង 33

ឧបសម្ព័ន្ធ៣៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច 39

ឧបសម្ព័ន្ធ៤៖ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា 48

ឧបសម្ព័ន្ធ៥៖ សាកលវិទ្យាល័យភូមិន្ទកសិកម្ម 59

ឧបសម្ព័ន្ធ៦៖សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ 68

ឧបសម្ព័ន្ធ៧៖ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល 104

ឧបសម្ព័ន្ធ៨៖ រាជបណ្ឌិត្យសភាបច្ចេកវិទ្យាកម្ពុជា 113

១. សេចក្តីផ្តើម

ក្នុងនីតិកាលទី៧ នៃរដ្ឋសភា ដើម្បីតម្រង់ទិសអន្តរាគមន៍សម្រាប់ការអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលអាណត្តិទី៧ ក្រោមការដឹកនាំដ៏ស្វាហាប់ និងឈ្លាសវៃរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បី **កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សម្រាប់កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ គឺកម្ពុជានឹងក្លាយជាប្រទេសមានចំណូលខ្ពស់** ដោយបន្តផ្តោតជាសំខាន់លើរបៀបវារៈធានា«ប្រសិទ្ធភាពសមិទ្ធកម្ម»។ដើម្បីឈានទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០, រាជរដ្ឋាភិបាលបានកំណត់អាទិភាពគន្លឹះចំនួន ៥ និងបន្តកំណត់យក មនុស្ស ជាអាទិភាពទី១ ហើយ ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា ជាពិសេស បច្ចេកវិទ្យាឌីជីថលជាអាទិភាពបន្តបន្ទាប់តាមលំដាប់។ អាទិភាព មនុស្ស ត្រូវបានឆ្លុះបញ្ចាំងជាចម្បងនៅក្នុងបញ្ចកោណទី១ និងបំពេញបន្ថែមដោយ មុំទី១ នៃបញ្ចកោណទី៣, មុំទី១ នៃបញ្ចកោណទី៤, និង មុំទី១ នៃបញ្ចកោណទី៥។ ក្នុងន័យនេះ ការអភិវឌ្ឍមូលធនមនុស្ស ជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានសម្រាប់ជំរុញពិពិធកម្ម និង កំណើនសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គម។ ការណ៍នេះបង្ហាញថា ការវិនិយោគក្នុងការអភិវឌ្ឍមូលធនមនុស្ស មានសារៈសំខាន់ ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃតម្រូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ។

ដើម្បីឱ្យវិស័យអប់រំជួយគាំទ្រដល់ការអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលបានកំណត់គោលដៅរយៈពេលវែងសម្រាប់វិស័យនេះ ក្នុងការបណ្តុះបណ្តាលប្រជាជនកម្ពុជាឱ្យ **«មានចំណេះដឹងខ្ពស់ និង ជំនាញមួយយ៉ាងគិចប្រចាំជីវិត»** ប្រកបដោយអំណត់ធន់, សហគ្រិនភាព, នវានុវត្តន៍ និង សីលធម៌ប្រពៃ ដោយរដ្ឋធានាពង្រឹងគុណភាពវិស័យឧត្តមសិក្សាឱ្យក្លាយជាមជ្ឈមណ្ឌលមូលធនបញ្ញាជាតិ និងឃ្លាំងពុទ្ធិសកល ដែលអាចសម្រេចបានតាមរយៈការលើកកម្ពស់គុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា, ការបង្កើនការចុះឈ្មោះចូលរៀនមុខជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា, ការបន្តពង្រឹងគុណភាពអប់រំ និងការធ្វើទំនើបកម្មកម្មវិធីសិក្សានៅគ្រប់កម្រិត, ការបង្កើតកាលានុវត្តភាពសម្រាប់រៀនពេញមួយជីវិត, ការកែលម្អសមត្ថភាពស្រាវជ្រាវ និងនវានុវត្តន៍ និងការពង្រឹងអភិបាលកិច្ច វិស័យឧត្តមសិក្សា។

ដើម្បីចូលរួមចំណែកក្នុងការធ្វើឱ្យសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០២៤-២០២៨ ដែលបន្តផ្តោតលើការកែទម្រង់អប់រំនៅគ្រប់កម្រិត ដោយកំណត់គោលនយោបាយយុទ្ធសាស្ត្រគន្លឹះគឺ **«ជានាថាប្រជាជនកម្ពុជាគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ពោរពេញដោយចំណេះដឹង បំណិន វិន័យ សីលធម៌និងឥរិយាបទល្អ ព្រមទាំងសុខភាពល្អ កាយសម្បទារឹងមាំ និង ការសិក្សាពេញមួយជីវិត។»** ផែនការយុទ្ធសាស្ត្រវិស័យអប់រំនេះ ត្រូវបានរៀបចំឡើងដើម្បីប្រែក្លាយអាទិភាព ដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, កំណែទម្រង់វិស័យអប់រំ, និងគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាពស្តីពីការអប់រំឆ្នាំ២០៣០ ឱ្យទៅជាការអនុវត្តជាក់ស្តែង និងនាំទៅរកសមិទ្ធកម្ម ប្រកបដោយគណនេយ្យភាពរបស់អង្គភាពគ្រប់កម្រិត រួមទាំងគ្រឹះស្ថានសិក្សាឧត្តមសិក្សាក្នុងការផលិតមូលធនមនុស្ស ដែលមានចំណេះដឹង, ចំណេះធ្វើ និង អាកប្បកិរិយាល្អ។ ដើម្បីជានាបានប្រសិទ្ធភាពខ្ពស់ក្នុងការផលិតមូលធនមនុស្សដើម្បី គាំទ្រ

ដល់កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព និង ចីរភាព ឈានទៅសម្រេចគោលដៅជាតិ ឆ្នាំ២០៥០ ការធ្វើកំណែទម្រង់ឧត្តមសិក្សា ជាការចាំបាច់ ។

ក្នុងការអភិវឌ្ឍមូលធនមនុស្ស ដើម្បីចូលរួមចំណែកធ្វើឱ្យសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងអនុវត្តកម្មវិធីកំណែទម្រង់ស៊ីជម្រៅលើវិស័យអប់រំ ពិសេសផ្នែកឧត្តមសិក្សា ចាប់ពីឆ្នាំ២០១១ មក តាមរយៈកម្មវិធីវិនិយោគ នៃគម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា (Higher Education Quality and Capacity Improvement Project, HEQCIP) ២០១១-២០១៧ គម្រោងកែលម្អការអប់រំឧត្តមសិក្សា (Higher Education Improvement Project, HEIP) ២០១៨-២០២៥ និងគម្រោងកែលម្អការអប់រំឧត្តមសិក្សាទី២ (Second Higher Education Improvement Project, HEIP2) ២០២៥-២០៣០។

២. ការអនុវត្តយុទ្ធសាស្ត្រ និង កម្មវិធីវិនិយោគលើកំណែទម្រង់ឧត្តមសិក្សា

២.១. យុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សា

ក្នុងការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា អនុវិស័យឧត្តមសិក្សាបានធ្វើបច្ចុប្បន្នភាពកំណែទម្រង់របស់ខ្លួនឱ្យកាន់តែឆ្លើយតបគ្រប់ជ្រុងជ្រោយ និង ស៊ីជម្រៅលើសពីការផ្ទេរសិទ្ធិដល់គ្រឹះស្ថានឧត្តមសិក្សាចុះហត្ថលេខាលើសន្លឹកសញ្ញាបត្រ, ការពង្រឹងការបណ្តុះបណ្តាលផ្នែកស្នេម និង ការពង្រឹងសមត្ថភាពគ្រឹះស្ថានឧត្តមសិក្សា។ ក្នុងន័យនេះ យុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សាបច្ចុប្បន្ន គឺផ្តោតលើអាទិភាពដូចខាងក្រោម៖

- **ការធ្វើទំនើបកម្មកម្មវិធីសិក្សា, វិធីសាស្ត្របង្រៀន និង វិធីសាស្ត្រវាយតម្លៃទទួលសិក្សា៖** ដើម្បីផលិតមូលធនមនុស្សឆ្លើយតបនឹងតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច កិច្ចការចំពោះមុខពីរដែលត្រូវវិនិយោគគឺ៖ ១. ការពន្លឿន និងការពង្រីកវិសាលភាពនៃការធ្វើទំនើបកម្មកម្មវិធីអប់រំ-ឧត្តមសិក្សាស្របតាម "ក្របខ័ណ្ឌអប់រំអនាគតផលសម្រាប់ការអប់រំផ្អែកលើលទ្ធផលនៅឧត្តមសិក្សាកម្ពុជា" (FutureFit Educational Framework for Outcome-Based Education in Cambodian Higher Education) និង២. ការបង្កើតកម្មវិធីសិក្សាដែលទាក់ទងនឹងស្នេម និងបច្ចេកវិទ្យាឌីជីថល។
- **ការលើកកម្ពស់សមត្ថភាពស្រាវជ្រាវ និងនវានុវត្តន៍៖** ដើម្បីកែលម្អគុណភាព និងភាពឆ្លើយតបនៃការស្រាវជ្រាវ និងនវានុវត្តន៍នៅឧត្តមសិក្សា ក្នុងការផលិតលទ្ធផលស្រាវជ្រាវ សម្រាប់ចូលរួមចំណែកធ្វើឱ្យមានកំណើនសេដ្ឋកិច្ច ការកសាង និងអនុវត្តប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវ និងនវានុវត្តន៍នៅតាមគ្រឹះស្ថានឧត្តមសិក្សាជាការចាំបាច់ ដោយផ្តោតលើចំណុចគន្លឹះមួយចំនួនដូចខាងក្រោម៖
  - បង្កើតក្របខ័ណ្ឌគ្រប់គ្រងការស្រាវជ្រាវ និងលើកទឹកចិត្តអ្នកស្រាវជ្រាវ,
  - លើកកម្ពស់សមត្ថភាពស្រាវជ្រាវ សម្រាប់ផលិតលទ្ធផលស្រាវជ្រាវ ដែលប្រើប្រាស់ដោយឧស្សាហកម្ម សហគមន៍ និង/ឬ ស្ថាប័នរដ្ឋ,
  - អភិវឌ្ឍសមត្ថភាពគ្រឹះស្ថានឧត្តមសិក្សា សម្រាប់គ្រប់គ្រងការស្រាវជ្រាវ និង ការបណ្តុះអ្នកស្រាវជ្រាវវ័យក្មេង, និង
  - បង្កើតមូលនិធិស្រាវជ្រាវឧត្តមសិក្សា ដោយមានការចូលរួមចំណែកជាថវិកាពីរដ្ឋ ដៃគូអភិវឌ្ឍ និងវិស័យឯកជន។

- **ការកែលម្អការចូលរៀន, សមធម៌ និង គុណភាព៖** ដើម្បីកែលម្អការចូលរៀន សមធម៌ និងគុណភាព ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងថ្នាលបច្ចេកវិទ្យាឌីជីថល, ការបំពាក់សម្ភារូបវន្ត, ការពង្រឹងសមត្ថភាព អនុវត្តបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា និងការផ្តល់អាហារូបករណ៍ពេញលេញដល់និស្សិត ចូលរៀននៅឧត្តមសិក្សា ជាកត្តាចាំបាច់។ ជាមួយគ្នានេះ ការអនុវត្តកម្មវិធីភាពជាដៃគូ នៃការអប់រំរវាង គ្រឹះស្ថានឧត្តមសិក្សា និងសាលារៀនមធ្យមសិក្សា គួរត្រូវបានបន្ត និងពង្រីកវិសាលភាពអនុវត្ត ដើម្បី លើកកម្ពស់សមត្ថភាព និងលទ្ធភាពរបស់សិស្សសម្រាប់បន្តការសិក្សានៅឧត្តមសិក្សា។
- **ការលើកកម្ពស់អន្តរជាតូបនីយកម្មឧត្តមសិក្សា៖** ដើម្បីកសាងមូលធនមនុស្សសកល និង លើកកម្ពស់ គុណភាពឧត្តមសិក្សា កម្មវិធីគន្លឹះមួយចំនួន គួរត្រូវបាន៖ ១. បង្កើត និងបន្តអនុវត្តកម្មវិធីភាពជាដៃគូ ជាមួយសាកលវិទ្យាល័យល្អៗនៅក្រៅប្រទេស ក្នុងការបង្កើតកម្មវិធីអន្តរជាតិ (កម្មវិធី ២+២, កម្មវិធី សញ្ញាបត្រទ្វេ), កម្មវិធីស្រាវជ្រាវរួមគ្នា (Joint research) និង កម្មវិធីសហដឹកនាំនិស្សិតថ្នាក់បណ្ឌិត (Co-supervision), ២. ពង្រីកវិសាលភាពអនុវត្តកម្មវិធីចល័តនិស្សិតអន្តរជាតិនៃអាស៊ី (Asian International Mobility Students, AIMS) និងកម្មវិធីចល័តក្រេឌីតអន្តរជាតិ (International Credit Mobility, ICM) ជាមួយសាកលវិទ្យាល័យនៃប្រទេសក្នុងតំបន់អាស៊ី និង អឺរ៉ុប, និង ៣. បង្កើនកម្រិត សមត្ថភាពភាសាអង់គ្លេសនៅតាមគ្រឹះស្ថានឧត្តមសិក្សា ។
- **ការធ្វើទំនើបកម្មអភិបាលកិច្ចវិស័យឧត្តមសិក្សា និង គ្រឹះស្ថានឧត្តមសិក្សា៖** ការផ្តល់ស្វ័យភាពពេញលេញ ដល់គ្រឹះស្ថានឧត្តមសិក្សាស្របតាមបរិបទតំបន់ និងអន្តរជាតិ ជាយុទ្ធសាស្ត្រគន្លឹះ នៃកំណែទម្រង់ឧត្តម-សិក្សាកម្ពុជាឆ្ពោះទៅគុណភាពកម្រិតតំបន់ និងអន្តរជាតិ, ភាពឆ្លើយតបទាន់ពេលវេលា និងនិរន្តរភាពក្នុង យុគសម័យបច្ចេកវិទ្យាឌីជីថល និងបញ្ញាសិប្បនិម្មិត ។ ក្នុងន័យនេះ ការកសាងប្រព័ន្ធអភិបាលកិច្ច ប្រកបដោយតម្លាភាព និងគណនេយ្យភាព និង សមត្ថភាពសម្រាប់ប្រតិបត្តិប្រព័ន្ធនេះ ជាកត្តាចាំបាច់ និងជាអាទិភាព ។
- **ការពង្រឹងការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង៖** ប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងជាយន្តការ ស្វ័យវាយតម្លៃរបស់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីកែលម្អគុណភាពជាប្រចាំឆ្ពោះទៅការទទួលស្គាល់គុណ-ភាពដោយទីផ្សារការងារ និង ស្ថាប័នវាយតម្លៃគុណភាពថ្នាក់ជាតិ តំបន់ និង អន្តរជាតិ ។ ក្នុងន័យនេះ ការកសាងសមត្ថភាពសម្រាប់ពង្រីកវិសាលភាពក្នុងការប្រតិបត្តិប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង និង កិច្ចសហការភាពជាដៃគូជាមួយ ASEAN University Network-Quality Assurance (AUN-QA) ដើម្បី កសាងសមត្ថភាពឧត្តមសិក្សាកម្ពុជា ឆ្ពោះទៅការទទួលស្គាល់គុណភាពកម្រិតតំបន់ និងអន្តរជាតិ ជាសកម្មភាពអាទិភាព ដែលត្រូវអនុវត្តបន្ត និង វិនិយោគបន្ថែម ។
- **ការអភិវឌ្ឍសមត្ថភាព៖** ដើម្បីធានាបាននូវគុណភាព នៃនិស្សិតបញ្ចប់ការសិក្សា និង គុណភាពនៃ ផលិតផលស្រាវជ្រាវ ឆ្លើយតបនឹងតម្រូវការទីផ្សារការងារ, ឧស្សាហកម្ម និង ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ការវិនិយោគលើការកសាងសមត្ថភាពគ្រូបង្រៀនកម្រិតបណ្ឌិតនៅឧត្តមសិក្សា ជាអាទិភាពចម្បង។

២.២. កម្មវិធីវិនិយោគលើកំណែទម្រង់ឧត្តមសិក្សា

ដើម្បីឈានទៅសម្រេចគោលដៅនៃយុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំ និងអនុវត្តកម្មវិធីវិនិយោគលើវិស័យឧត្តមសិក្សាតាមរយៈគម្រោងដូចខាងក្រោម៖

- **គម្រោងលើកកម្ពស់គុណភាព និង សមត្ថភាពឧត្តមសិក្សា (២០១១-២០១៧)៖** បន្ទាប់ពីច្បាប់ស្តីពីការអប់រំត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅឆ្នាំ២០០៧ អនុវិស័យឧត្តមសិក្សា តាមរយៈគម្រោងHEQCIP បានទទួលថវិកា ២៣ លានដុល្លាអាម៉េរិក ក្នុងនោះ ៥០% ជាឥណទាន និង ៥០% ជាជំនួយ ដែលហិរញ្ញប្បទានដោយធនាគារពិភពលោក។ វត្ថុបំណងនៃគម្រោងនេះ គឺកែលម្អគុណភាពនៃការបង្រៀន ការស្រាវជ្រាវ និងការគ្រប់គ្រង។ គម្រោងនេះ បានផ្តោតលើ៖ ១. ការពង្រឹងសមត្ថភាពប្រព័ន្ធឧត្តមសិក្សា គឺកសាងសមត្ថភាពអគ្គនាយកដ្ឋានឧត្តមសិក្សា គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ព្រមទាំងគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជន លើការបង្រៀន ការស្រាវជ្រាវ ការគ្រប់គ្រង និងការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំ ២. ការលើកកម្ពស់ការស្រាវជ្រាវ តាមរយៈការផ្តល់កញ្ចប់ថវិកាស្រាវជ្រាវដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជន និង ៣. ការផ្តល់អាហារូបករណ៍ដល់សិស្សជួបការលំបាកឱ្យចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជន និង ៤. ការពង្រឹងអភិបាលកិច្ចអនុវិស័យ និងគ្រឹះស្ថាន-ឧត្តមសិក្សា គឺ អភិវឌ្ឍគោលនយោបាយចក្ខុវិស័យឧត្តមសិក្សាឆ្នាំ២០៣០, ផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍឧត្តមសិក្សាឆ្នាំ២០៣០ និង ក្រោយឆ្នាំ២០៣០, និងកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យឧត្តមសិក្សា។
- **គម្រោងកែលម្អការអប់រំឧត្តមសិក្សា** (២០១៨-២០២៥)៖ បន្ទាប់ពីការដាក់ចេញនូវកម្មវិធីកំណែទម្រង់មុតស្រួច ក្រោមពាក្យស្លោក **«អ្នកចេះជាប់»** និង **«ការធានាគុណភាពអប់រំផ្ទៃក្នុង គឺសំខាន់ណាស់»** របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ទឹកប្រាក់ ៩២,៥ លានដុល្លារអាម៉េរិក ក្នុងនោះ ៩០ លានដុល្លារអាម៉េរិក ជាឥណទានរបស់ធនាគារពិភពលោក និង ២,៥ លានដុល្លារអាម៉េរិក ជាថវិការបស់រាជរដ្ឋាភិបាល ត្រូវបានបន្តវិនិយោគក្នុងវិស័យឧត្តមសិក្សា តាមរយៈគម្រោងកែលម្អការអប់រំឧត្តមសិក្សា។ វត្ថុបំណងនៃគម្រោងនេះ គឺកែលម្អគុណភាព និងភាពឆ្លើយតបរបស់ឧត្តមសិក្សា និង ការស្រាវជ្រាវលើផ្នែកស្នូម និងកសិកម្មជាចម្បងនៅគ្រឹះស្ថានឧត្តមសិក្សាគោលដៅ និង កែលម្អអភិបាលកិច្ចវិស័យឧត្តមសិក្សា។ គម្រោងនេះ បានជួយដល់គ្រឹះស្ថានឧត្តមសិក្សាគោលដៅចំនួន ១១ (រដ្ឋ៥ និង ឯកជន៦) និងគ្រឹះស្ថានឧត្តមសិក្សាមិនមែនគោលដៅទាំងរដ្ឋ និងឯកជននៅក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា។ គម្រោងនេះ បានផ្តោតលើកម្មវិធីកំណែទម្រង់សំខាន់ៗ ៤គឺ៖
  - **ការកែលម្អសមត្ថភាពបង្រៀន និងរៀន** តាមរយៈ៖ ១. ការកែលម្អកម្មវិធីសិក្សាស្របតាមទស្សនវិជ្ជានៃការអប់រំផ្តែកលើលទ្ធផល (Philosophy of Outcome-Based Education) និងការបង្កើតកម្មវិធីសិក្សាថ្មីទាំងកម្រិតបរិញ្ញាបត្រ និងក្រោយបរិញ្ញាបត្រ ដោយផ្តោតជាចម្បងលើផ្នែកស្នូម និងបច្ចេកវិទ្យាឌីជីថល, ២. ការបង្កើនគុណវុឌ្ឍិ និងការផ្តល់វគ្គបំប៉នសមត្ថភាពរយៈពេលខ្លីសម្រាប់គ្រូបង្រៀន និងបុគ្គលិកគាំទ្រ, ៣. ការអនុវត្តកម្មវិធីផ្លាស់ប្តូរគ្រូបង្រៀន និងការស្រាវជ្រាវរួមគ្នា, ៤. ការកសាង និងជួសជុលអគារសិក្សា, ថ្នាក់រៀន, បន្ទប់ពិសោធន៍ និងអន្តេវាសិកដ្ឋានសម្រាប់និស្សិតនារី និងនិស្សិត

មកពីគ្រួសារក្រីក្រ, ៥. ការបំពាក់ឧបករណ៍ និង សម្ភារៈទំនើប ដើម្បីបម្រើឱ្យការបង្រៀន និង ការរៀន, និង ៦. ពង្រឹងទំនាក់ទំនងជាមួយផ្នែកឧស្សាហកម្ម។ សកម្មភាពទី ១, ទី២ និងទី៣ ត្រូវ បានរៀបចំនិងអនុវត្តតាមរយៈកម្មវិធីភាពជាដៃគូជាមួយសាកលវិទ្យាល័យអន្តរជាតិល្បីៗ និង សាកលវិទ្យាល័យក្នុងស្រុក។

- **ការកែលម្អការស្រាវជ្រាវផ្នែកស្នែម និងកសិកម្ម** តាមរយៈ៖ ១. ការសាងសង់ និងជួសជុលបន្ទប់ពិសោធន៍, ២. ការផ្តល់ឧបករណ៍ និងសម្ភារៈបម្រើឱ្យសកម្មភាពស្រាវជ្រាវ និង ៣. ការផ្តល់មូលនិធិស្រាវជ្រាវ ។ គម្រោងស្រាវជ្រាវទាំងនេះ ត្រូវផ្សារភ្ជាប់នឹងតម្រូវការរបស់ឧស្សាហកម្ម ។
- **ការពង្រឹងអភិបាលកិច្ចឧត្តមសិក្សា** តាមរយៈ៖ ១. ការកសាង និងការអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានមនុស្សនៅតាមគ្រឹះស្ថានឧត្តមសិក្សាដើម្បីធានាបាននូវតម្លាភាព និងគណនេយ្យភាព ២.ការប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល, ៣. ការអភិវឌ្ឍផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍអនុវិស័យ និងគ្រឹះស្ថានឧត្តមសិក្សា, ៤. ការកែលម្អ និងការអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យឧត្តមសិក្សាសម្រាប់ការរៀបចំគោលនយោបាយ និងផែនការ, និង៥. ការរៀបចំ និងការអនុវត្តគោលការណ៍ណែនាំស្តីពីការសិក្សាស្ថានភាព និស្សិតក្រោយបញ្ចប់ការសិក្សា និងគោលការណ៍ណែនាំស្តីពីការតាំរបស់និស្សិត ។
- **ការកែលម្អប្រព័ន្ធធានាគុណភាពអប់រំ** តាមរយៈ៖ ១. ការកែលម្អយន្តការធានាគុណភាពអប់រំផ្ទៃក្រៅ (គណៈកម្មការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា) ដោយធានាថាគ្រឹះស្ថានឧត្តមសិក្សា និងមន្ត្រីវាយតម្លៃគុណភាពត្រូវបានបណ្តុះបណ្តាលសម្រាប់ប្រតិបត្តិសកម្មភាព នៃការទទួលស្គាល់គុណ-ភាពអប់រំប្រកបដោយប្រសិទ្ធភាព និង២. ការអភិវឌ្ឍ និងការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងនៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

➢ **គម្រោងកែលម្អការអប់រំឧត្តមសិក្សាទី២** (២០២៥-២០៣០)៖ បន្ទាប់ពីរាជរដ្ឋាភិបាលអាណត្តិទី៧ បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដោយបានកំណត់យក «ការអភិវឌ្ឍមូលធនមនុស្ស» ជាអាទិភាពទី១ ក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ចកម្ពុជា ដើម្បីឈានទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ គម្រោងកែលម្អការអប់រំឧត្តមសិក្សាទី២ ដែលមានទឹកប្រាក់ ៨១,៧ លានដុល្លារអាម៉េរិក ក្នុងនោះ ៨០ លានដុល្លារ ជាឥណទានរបស់ធនាគារពិភពលោក និង ១,៧ លានដុល្លារ ជាថវិការាជរដ្ឋាភិបាល ត្រូវបានដាក់ឱ្យអនុវត្ត ។ គម្រោងនេះ សង់បន្តពីសមិទ្ធផល នៃគម្រោងកែលម្អការអប់រំឧត្តមសិក្សា និង ផ្តោតលើកម្មវិធីកំណែទម្រង់សំខាន់ៗ ៥គឺ៖

- **ការកែលម្អគុណភាព និងភាពឆ្លើយតបនៃកម្មវិធីសិក្សា** តាមរយៈ៖ ១. ការធ្វើទំនើបកម្មកម្មវិធីអប់រំឧត្តមសិក្សាស្របតាម «ក្របខ័ណ្ឌអប់រំអនាគតផលសម្រាប់ការអប់រំផ្អែកលើលទ្ធផលនៅឧត្តមសិក្សាកម្ពុជា» (FutureFit Educational Framework for Outcome-Based Education in Cambodian Higher Education), ២. ការបង្កើនគុណវុឌ្ឍិ និងសមត្ថភាពគ្រូបង្រៀន, ៣. ការពង្រឹងទំនាក់ទំនងរវាងសាកលវិទ្យាល័យ និងឧស្សាហកម្ម, ៤. ការកសាងសមត្ថភាពគ្រឹះស្ថានឧត្តមសិក្សាគោលដៅដើម្បីរៀបចំកម្មវិធីសិក្សាបានការទទួលស្គាល់គុណភាពកម្រិតជាតិ និងតំបន់, ៥. ការបង្កើតកម្មវិធីបណ្តុះ-បណ្តាលខ្លីៗ និងការអភិវឌ្ឍកម្មវិធីអប់រំឧត្តមសិក្សា តាមប្រព័ន្ធអនឡាញ ដើម្បីពង្រីកការចូលរៀន

នៅតាមគ្រឹះស្ថានឧត្តមសិក្សាគោលដៅ, ៦. ការពង្រឹងសមត្ថភាពបណ្តាញសាកលវិទ្យាល័យសាយប័រ-កម្ពុជា សម្រាប់ផ្តល់កម្មវិធីបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រ និងក្រោយបរិញ្ញាបត្រ, ៧. ការកសាង និងជួសជុលអគារសិក្សា, ថ្នាក់រៀន, បន្ទប់ពិសោធន៍ និងបណ្ណាល័យ, និង ៨. ការបំពាក់ឧបករណ៍ និងសម្ភារៈទំនើប ដើម្បីបម្រើឱ្យការបង្រៀន និងការរៀន។

- **ការកែលម្អគុណភាព និងភាពឆ្លើយតបនៃការស្រាវជ្រាវ** តាមរយៈ៖ ១. ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវនៅឧត្តមសិក្សា, ២. ការផ្តល់មូលនិធិដល់គម្រោងស្រាវជ្រាវសក្តានុពលសម្រាប់ធ្វើពាណិជ្ជ-កម្ម, ៣. ការធ្វើទំនើបកម្មបន្ទប់ពិសោធន៍សម្រាប់ទទួលបានវិញ្ញាបនបត្រស្តង់ដាបន្ទប់ពិសោធន៍កម្រិតបឋមនៅគ្រឹះស្ថានឧត្តមសិក្សា, ៤. ការអនុវត្តមូលនិធិស្រាវជ្រាវឧត្តមសិក្សា សម្រាប់គាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីកសាងសមត្ថភាពគ្រប់គ្រងការស្រាវជ្រាវ, ថែបំប៉នអ្នកស្រាវជ្រាវវ័យក្មេង និង គាំទ្រនិស្សិតថ្នាក់ក្រោយបរិញ្ញាបត្រ, និង៥. ការគាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សាក្នុងការបង្កើតទស្សនាវដ្តីស្រាវជ្រាវ។
- **ការកែលម្អអភិបាលកិច្ច នៅតាមគ្រឹះស្ថានឧត្តមសិក្សា និងវិស័យឧត្តមសិក្សា**៖ ដើម្បីលើកកម្ពស់ស្វ័យភាព, តម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព និង ចីរភាព នៅឧត្តមសិក្សា ទាមទារកែលម្អ និងអនុវត្តប្រព័ន្ធ និង គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ, ការគ្រប់គ្រងធនធានមនុស្ស, ការគ្រប់គ្រងទិន្នន័យ, ការធ្វើផែនការផ្អែកលើលទ្ធផល និងការពិនិត្យតាមដាននិងវាយតម្លៃ និងអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញគ្រប់លំដាប់ថ្នាក់ ព្រមទាំងបំពាក់បច្ចេកវិទ្យាដើម្បីគាំទ្រដល់ដំណើរការប្រតិបត្តិ ។
- **ការពង្រឹងការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង៖** គឺផ្តោតលើការកសាងសមត្ថភាព និងការអនុវត្តប្រព័ន្ធធានាគុណភាពផ្ទៃក្នុងឱ្យមានប្រសិទ្ធភាពខ្ពស់ ។
- **ការកែលម្អគុណភាពឆ្ពោះទៅស្តង់ដាតំបន់ AUN-QA និងអន្តរជាតិ៖** គឺការកសាងសមត្ថភាពគ្រឹះស្ថានឧត្តមសិក្សា ឆ្ពោះទៅទទួលបានការទទួលស្គាល់គុណភាពកម្រិតតំបន់ និងអន្តរជាតិ ។

៣. លទ្ធផលសម្រេចបាន

៣.១. ផ្ទៃកបរិមាណវិស័យ

៣.១.១. ចំនួននិស្សិតកំពុងសិក្សា

ចំនួននិស្សិតចូលរៀននៅឧត្តមសិក្សាចាប់ពីកម្រិតបរិញ្ញាបត្ររង ដល់ថ្នាក់បណ្ឌិត បានកើនឡើងពី ១៩៨ ៣៦៣ នាក់ នារីមាន ៤៩,៦៧% នៅឆ្នាំសិក្សា២០២០-២០២១ ដល់ ៣១៨ ៩១៩ នាក់ នារីមាន ៥៣,៩៨% នៅឆ្នាំសិក្សា២០២៤-២០២៥។ និស្សិត រៀនផ្នែកស្នេមបានកើនពី ៣០,៧% ដល់ ៣៦,១%។

អត្រារួមនៃការចូលសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រក្នុងចំណោមយុវជនដែលមានអាយុចាប់ពីអាយុ១៨ ដល់ ២២ឆ្នាំ បានកើនឡើងពី ១៣,៨០% នៅឆ្នាំសិក្សា២០១៥-២០១៦ ដល់ ១៩%[1] នៅឆ្នាំសិក្សា ២០២៤-២០២៥ ។ អត្រានេះ បានកើនឡើងជាមធ្យមប្រមាណ ០,៨៣% ក្នុងមួយឆ្នាំ។

1 សន្និតបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០២៤-២០២៥ និងទិសដៅឆ្នាំសិក្សា២០២៥-២០២៦

ក្នុងឆ្នាំសិក្សា ២០២៣-២០២៤ មាននិស្សិតអាហារូបករណ៍សរុប ៣៩ ១៨៦ នាក់ នារី ២៣ ៩៨៦នាក់ ស្មើ ៦១.២១% ក្នុងនោះនិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រមាន ៣៥ ៦៤៧ នាក់ នារី ២២ ០៨១នាក់ ស្មើ ៦១.៩៤%[2] ។

៣.១.២. ចំនួនគ្រឹះស្ថានឧត្តមសិក្សា

ចំនួនគ្រឹះស្ថានឧត្តមសិក្សាសរុបទាំងរដ្ឋ និងឯកជន បានកើនឡើងពី ១៣០ នៅឆ្នាំសិក្សា២០២០-២០២១ ដល់ ២០០ នៅឆ្នាំសិក្សា ២០២៤-២០២៥។ គ្រឹះស្ថានឧត្តមសិក្សាឯកជន បានកើនឡើងពី ៧៣ នៅឆ្នាំសិក្សា២០១៥-២០១៦ ដល់ ១២១ នៅឆ្នាំសិក្សា ២០២៤-២០២៥។ ក្នុងឆ្នាំ ២០២៥ គ្រឹះស្ថាន-ឧត្តមសិក្សាឯកជនចំនួន ៦ ត្រូវបានទទួលស្គាល់ក្នុងការបង្កើត តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនិងមិនមានការទទួលស្គាល់ការបង្កើតតាមរយៈក្រសួងអប់រំ យុវជន និងកីឡាទេ។

គ្រឹះស្ថានឧត្តមសិក្សាទាំង២០០ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង-ស្ថាប័ន ១៧។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានគ្រឹះស្ថានឧត្តមសិក្សាសរុប ៨១ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សារដ្ឋ មាន៣៧, គ្រឹះស្ថានឧត្តមសិក្សាឯកជន ៤៤ និងមានសាខា ១១។

ក្រសួងអប់រំ យុវជន និងកីឡា មានគ្រឹះស្ថានឧត្តមសិក្សា ៩៤ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សារដ្ឋមាន ១៧ និងសាខា ៤ និងគ្រឹះស្ថានឧត្តមសិក្សាឯកជនមាន ៧៧ និងសាខា ៣៩[3]។ ក្នុងចំណោមគ្រឹះស្ថានឧត្តម-សិក្សាឯកជនទាំង៧៧ និងសាខា៣៩នេះ គ្រឹះស្ថានឧត្តមសិក្សាឯកជនចំនួន៩ និងសាខា ២ បានផ្អាក ការបណ្តុះបណ្តាល និងកំពុងរៀបចំតាមនីតិវិធីដើម្បីបញ្ឈប់ការទទួលស្គាល់។ ដូចនេះ គ្រឹះស្ថានឧត្តមសិក្សា ឯកជនកំពុងដំណើរការ មាន ៦៨ និងសាខា ៣៧។

គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជន បានចូលរួមចំណែកស្រូបយកនិស្សិតឱ្យចូលរៀនថ្នាក់បរិញ្ញាបត្ររង និង បរិញ្ញាបត្រ ប្រមាណ ៥០% ដូចគ្នា នៅក្នុងឆ្នាំសិក្សា២០២២-២៣ និង ២០២៣-២៤។ ជាក់ស្តែងក្នុងឆ្នាំសិក្សា ២០២២-២៣ មាននិស្សិតថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រសរុប ២៧០ ២៦១ នាក់ ក្នុងនោះ គ្រឹះស្ថានឧត្តមសិក្សាឯកជន មាននិស្សិត ១៣៥ ៥១០ នាក់ និង គ្រឹះស្ថានឧត្តមសិក្សារដ្ឋមាន ១៣៤ ៧៥១ នាក់។ ក្នុងឆ្នាំសិក្សា ២០២៣-២០២៤ មាននិស្សិតថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រសរុប ២៩៩ ៧៧៩ នាក់ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សាឯកជន មាននិស្សិត ១៥១ ១៣១ នាក់ និង គ្រឹះស្ថានឧត្តមសិក្សារដ្ឋមាន ១៤៨ ៦៤៨ នាក់។

៣.២. ផ្នែកគុណភាពវិស័យ

៣.២.១. ការធ្វើទំនើបកម្មកម្មវិធីសិក្សា វិធីសាស្ត្របង្រៀននិងរៀន និងវិធីសាស្ត្រវាយតម្លៃលទ្ធផលសិក្សា

ក្រសួងអប់រំ យុវជន និងកីឡា ដែលមានអគ្គនាយកដ្ឋានឧត្តមសិក្សាជាសេនាធិការ បានរៀបចំ និងអនុវត្ត គោលនយោបាយសម្រាប់ការអភិវឌ្ឍកម្មវិធីអប់រំឧត្តមសិក្សាផ្អែកតាមទស្សនវិជ្ជានៃការអប់រំផ្អែកលើលទ្ធផល និង ការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំមកពីអគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សា ដើម្បីអនុវត្ត

2 សន្និតបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០២៤-២០២៥ និងទិសដៅឆ្នាំសិក្សា២០២៥-២០២៦

3 សាខាចំនួន ២ ត្រូវបានបិទក្នុងឆ្នាំ២០២៥។

កំណែទម្រង់កម្មវិធីសិក្សានៅឧត្តមសិក្សាឱ្យមានគុណភាព និងប្រសិទ្ធភាព។ លទ្ធផលបឋម ដែលទទួលបានមានដូចខាងក្រោម៖

- **ការអភិវឌ្ឍគោលនយោបាយ (Policy Development)៖** ឯកសារក្របខ័ណ្ឌអភិវឌ្ឍកម្មវិធីសិក្សានៅឧត្តមសិក្សាគ្រប់ជ្រុងជ្រោយលើកដំបូង គឺ **«ក្របខ័ណ្ឌអនាគតផលសម្រាប់ការអប់រំផ្អែកលើលទ្ធផលនៅឧត្តមសិក្សាកម្ពុជា»** (FutureFit Educational Framework for Outcome-Based Education in Cambodian Higher Education, FEF-for-OBE) អមដោយគោលការណ៍ណែនាំ និង សៀវភៅសាស្ត្រាក្បួន (Playbook) ស្តីពីកម្មវិធីសិក្សាបរិវត្តន៍ (Transformative Curriculum) គរុកោសល្យនវានុវត្តន៍ (Innovative Pedagogy) និង សមាហរណកម្មវាយតម្លៃលទ្ធផលសិក្សា (Holistic Assessment) ត្រូវបានតាក់តែងដោយគណៈកម្មការបច្ចេកទេសក្របខ័ណ្ឌអប់រំអនាគតផល (DGHE-OBE Team) និង មានការណែនាំផ្ទាល់ពីអ្នកជំនាញផ្នែកគ្រប់គ្រង និងអភិវឌ្ឍកម្មវិធីអប់រំឧត្តមសិក្សា ពីរូប ដែលជាសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យពូត្រាម៉ាឡេស៊ី (University of Putra Malaysia, UPM) ។ គណៈកម្មការបច្ចេកទេសក្របខ័ណ្ឌអប់រំអនាគតផលនេះ មានសមាសភាពមកពីអគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សា ។ ឯកសារ «ក្របខ័ណ្ឌអនាគតផលសម្រាប់ការអប់រំផ្អែកលើលទ្ធផលនៅឧត្តមសិក្សាកម្ពុជា» (FEF-for-OBE) នេះ ត្រូវបានចុះហត្ថលេខា ដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៥ និង ប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ។

- **ការអភិវឌ្ឍមនុស្ស (People Development)៖** ដើម្បីកសាងគោលនយោបាយសម្រាប់កែទម្រង់កម្មវិធីសិក្សានៅឧត្តមសិក្សា គណៈកម្មការដឹកនាំ គណៈកម្មការបច្ចេកទេស និងក្រុមលេខាធិការដ្ឋាន ដែលមានសមាសភាពចម្រុះមកពីក្រសួងអប់រំ យុវជន និងកីឡា អគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សា ៥៥ រូប ត្រូវបានបង្កើត។ គណៈកម្មការនេះ មានការកិច្ចដឹកនាំ ស្រាវជ្រាវឯកសារពាក់ព័ន្ធ និង សរសេរគោលនយោបាយ ព្រមទាំងសាកល្បងធ្វើទំនើបកម្ម និងអនុវត្តកម្មវិធីសិក្សាក្រោមការណែនាំ និងការបង្វឹក ដោយផ្ទាល់ពីអ្នកជំនាញពីរូបមកពីសាកលវិទ្យាល័យពូត្រាម៉ាឡេស៊ី (University Putra Malaysia) ប្រទេសម៉ាឡេស៊ី។ មកដល់បច្ចុប្បន្ននេះ បុគ្គលិកអប់រំ ២៧០នាក់ មកពីអគ្គនាយកដ្ឋានឧត្តមសិក្សា និង គ្រឹះស្ថានឧត្តមសិក្សាគោលដៅ៩ (វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យស្វាយរៀង សាកលវិទ្យាល័យជាតិបាត់ដំបង សាកលវិទ្យាល័យហេងសំរិនត្បូងឃ្មុំ សាកលវិទ្យាល័យជាតិជាស៊ីម-កំចាយមារ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និង វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប) ត្រូវបានបណ្តុះឱ្យមានសមត្ថភាពសម្រាប់ធ្វើទំនើបកម្ម និងអនុវត្តកម្មវិធីអប់រំស្របតាមក្របខ័ណ្ឌអប់រំអនាគតផល ។

បុគ្គលិកអប់រំ៦១ នាក់ ក្នុងចំណោម២៧០នាក់នេះ ត្រូវបានបង្វឹកឱ្យក្លាយជាគ្រូបង្គោល ដែលជាធនធានសម្រាប់ពង្រីកវិសាលភាពក្នុងការអនុវត្តក្របខ័ណ្ឌអប់រំអនាគតផលនេះ ។

- **ការអភិវឌ្ឍកម្មវិធី (Program Development)៖** មកដល់ពេលនេះ កម្មវិធីសិក្សាចំនួន ៥១ ត្រូវបានធ្វើទំនើបកម្ម និងដាក់ឱ្យអនុវត្ត ។ កម្មវិធីសិក្សាគំរូចំនួន៥ ដែលត្រូវបានដាក់ឱ្យអនុវត្តចាប់ពីឆ្នាំសិក្សា ២០២៤-២០២៥ មក គឺ៖ ១. បរិញ្ញាបត្រវិទ្យាសាស្ត្រ ផ្នែករូបវិទ្យា ឯកទេសថាមពល និងអេឡិចត្រូនិក ២. បរិញ្ញាបត្រវិទ្យាសាស្ត្រ ជំនាញវិទ្យាសាស្ត្រអាហារ និងបច្ចេកវិទ្យាក្រោយប្រមូលផល ៣.បរិញ្ញាបត្រវិស្វករ ជំនាញអេឡិចត្រូនិក និងស្វ័យប្រវត្តិកម្ម ៤. បរិញ្ញាបត្រវិទ្យាសាស្ត្រ ជំនាញវិស្វកម្មមេកានិក ជាមួយវិស្វកម្មឧស្សាហកម្ម និង៥. បរិញ្ញាបត្រវិទ្យាសាស្ត្រ ជំនាញសាកវប្បកម្ម ជាមួយអាជីវកម្ម កសិកម្ម។

ក្រសួងបាននិងកំពុងពង្រីកការវិនិយោគលើការអប់រំឌីជីថល និង ជំនាញថ្មីៗនៅតាមគ្រឹះស្ថានឧត្តម-សិក្សាសាធារណៈ និងលើកទឹកចិត្តដល់គ្រឹះស្ថានឧត្តមសិក្សាឯកជនក្នុងការបង្កើតជំនាញស្នូម និងឌីជីថលនៅក្នុងយុគសម័យបញ្ញាសិប្បនិម្មិត។ ជាក់ស្តែង វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា បានបង្កើតជំនាញវិស្វកម្មបញ្ញាសិប្បនិម្មិត, វិទ្យាសាស្ត្រទិន្នន័យ, ប្រព័ន្ធបញ្ជានិងបណ្តាញអគ្គិសនី, វិស្វកម្មផ្នែកទន់ (Software), សន្តិសុខសាយប័រ (Cybersecurity), រ៉ូបូទិកនិងស្វ័យប្រវត្តិកម្ម។ សាកលវិទ្យាល័យជាតិគ្រប់គ្រងក៏បានបង្កើតជំនាញសេដ្ឋកិច្ចឌីជីថល និង មានគម្រោងដាក់បញ្ចូលបញ្ញាសិប្បនិម្មិត នៅគ្រប់មុខជំនាញ។

ឯកទេស វិស្វកម្មសុសវៃរ (Specialized in Software Engineering)

៣.២.២. ការលើកកម្ពស់សមត្ថភាពនៃការស្រាវជ្រាវ និងនវានុត្តន៍

ដើម្បីធានាបាននូវសមត្ថភាពនៃការស្រាវជ្រាវ និងនវានុត្តន៍របស់គ្រឹះស្ថានឧត្តមសិក្សាក្នុងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡាបានកសាងប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវដែលផ្សារភ្ជាប់ការស្រាវជ្រាវជាមួយឧស្សាហកម្ម និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច តាមរយៈការអនុវត្តនូវកម្មវិធីគន្លឹះមួយចំនួនដូចជា៖

ក. ការកសាងគោលនយោបាយ

- «ក្របខ័ណ្ឌគ្រប់គ្រងការស្រាវជ្រាវសម្រាប់ឧត្តមសិក្សាកម្ពុជា» ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។ ក្របខ័ណ្ឌនេះ ត្រូវបានចុះហត្ថលេខាដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៦។
- ឧបករណ៍សម្រាប់ធ្វើងផ្ទាត់កម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតត្រូវបានរៀបចំ ស្របតាមគោលការណ៍ណែនាំសម្រាប់ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត។
- គោលការណ៍ណែនាំស្តីពីការវាយតម្លៃ ការជ្រើសរើស និង ការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ ត្រូវបានចុះហត្ថលេខាដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤។
- ទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្នូម ត្រូវបានបង្កើតនៅឆ្នាំ២០២៣។

- សៀវភៅប្រតិបត្តិស្តីពីការស្រាវជ្រាវត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ។

ខ. ការកសាងសមត្ថភាពស្រាវជ្រាវ

តាមរយៈគម្រោងវិនិយោគទាំងបីខាងលើ សមត្ថភាពនៃការស្រាវជ្រាវ និង ការគ្រប់គ្រងការស្រាវជ្រាវ ត្រូវបានបណ្តុះបណ្តាល។ លទ្ធផលទទួលបាន មានដូចខាងក្រោម៖

- **គម្រោង HEQCIP** មានទឹកប្រាក់សម្រាប់ការស្រាវជ្រាវប្រមាណ ៤,៦ លានដុល្លារអាម៉េរិក, មានគ្រឹះស្ថានឧត្តមសិក្សា ២៤ (រដ្ឋ១៣) បានទទួលមូលនិធិស្រាវជ្រាវ, អ្នកស្រាវជ្រាវចំនួន៥៧៩ នាក់ បានទទួលការបណ្តុះបណ្តាល និង មានគម្រោងស្រាវជ្រាវចំនួន៤៥ ។ លទ្ធផលពីគម្រោងស្រាវជ្រាវនេះ គឺរបាយការណ៍ស្រាវជ្រាវ ។
- **គម្រោង HEIP** មានទឹកប្រាក់សម្រាប់ការស្រាវជ្រាវប្រមាណ ១៥,៨ លានដុល្លារអាម៉េរិក, មានគ្រឹះស្ថានឧត្តមសិក្សាគោលដៅ៥ បានទទួលមូលនិធិស្រាវជ្រាវ, អ្នកស្រាវជ្រាវប្រមាណ ៣០០ នាក់ បានទទួលការបណ្តុះបណ្តាល និងចូលរួមអនុវត្តគម្រោងស្រាវជ្រាវចំនួន៥៣ ដែលបានផ្តោតលើស្នេមនិងកសិកម្ម ។ក្នុងចំណោមគម្រោងទាំង៥៣នេះ មានគម្រោងចំនួន៤៤ ដែលផ្សារភ្ជាប់នឹងឧស្សាហកម្ម។ លទ្ធផលដែលទទួលបានគឺ៖ ១. ផលិតផលចំនួន ៧៣ ដែលក្នុងនោះមានផលិតផលសម្រេច (Products) ៣០ និងផលិតផលគំរូ (Prototypes) ៤៣ ត្រូវបានផលិត, ២. អត្ថបទស្រាវជ្រាវចំនួន ១៣២ ត្រូវបានបោះពុម្ពក្នុងទស្សនាវដ្តីស្រាវជ្រាវអន្តរជាតិ និង ៥១ ទៀតត្រូវបានបោះពុម្ពនៅក្នុងទស្សនាវដ្តីស្រាវជ្រាវក្នុងស្រុក, ៣. ទស្សនាវដ្តីស្រាវជ្រាវចំនួនមួយត្រូវបានបង្កើត និង ៤. បុគ្គលិកអប់រំ ៣២៨ នាក់ ត្រូវបានតែងតាំងហាន:សាស្ត្រាចារ្យក្នុងវិស័យអប់រំលើកដំបូងក្នុងនោះសាស្ត្រាចារ្យ ៣២នាក់ សាស្ត្រាចារ្យរង ៥៨នាក់ និង សាស្ត្រាចារ្យជំនួយ ២៣៨នាក់ ។
- **គម្រោង HEIP 2** មានកម្មវិធីស្រាវជ្រាវពីរប្រភេទ ដែលមានទឹកប្រាក់ប្រមាណ ៨,៤ លានដុល្លារអាម៉េរិក។ ប្រភេទទី១ ជាកម្មវិធីស្រាវជ្រាវសម្រាប់ធ្វើពាណិជ្ជកម្ម (Research for Commercialization) ដែលត្រូវអនុវត្តដោយគ្រឹះស្ថានឧត្តមសិក្សាគោលដៅចំនួន៥ (វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យស្វាយរៀង និង សាកលវិទ្យាល័យជាតិបាត់ដំបង)។ កម្មវិធីនេះ មានគម្រោងស្រាវជ្រាវចំនួន៩ និងមានទឹកប្រាក់ប្រមាណ ៣,៥ លានដុល្លារអាម៉េរិក ។ ប្រភេទទី២ ជាមូលនិធិស្រាវជ្រាវឧត្តមសិក្សា ដែលមានទឹកប្រាក់ ៣,១ លានដុល្លារអាម៉េរិក ដើម្បីកសាងថ្នាលសម្រាប់បណ្តុះ និងថែបំប៉នអ្នកស្រាវជ្រាវវ័យក្មេង។ មូលនិធិនេះ ត្រូវបានផ្តល់ឱ្យគ្រឹះស្ថានឧត្តមសិក្សាទាំងរដ្ឋ និងឯកជន ដែលបំពេញបានលក្ខខណ្ឌតម្រូវ ។ គម្រោងស្រាវជ្រាវនៃប្រភេទទី២នេះ មានពីរខ្នាត គឺ ខ្នាតតូច មានទឹកប្រាក់ប្រមាណ ២០.០០០ ដុល្លារអាម៉េរិក និង ខ្នាតធំមានទឹកប្រាក់ប្រមាណ ៥០.០០០ ដុល្លារអាម៉េរិក ។

៣.២.៣. ការកែលម្អការចូលរៀន សមធម៌ និង គុណភាព

ក. ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការបំពាក់សម្ភារូបវន្ត

គ្រឹះស្ថានឧត្តមសិក្សារដ្ឋ តាមរយៈថវិកាបង់ថ្លៃសិក្សា និង ការវិនិយោគផ្ទាល់ពីថវិកាជាតិ និងថវិកាដៃគូអភិវឌ្ឍ បានសាងសង់អគារសិក្សា អគារ/បន្ទប់ពិសោធន៍ អន្តេវាសិកដ្ឋាន អគារមជ្ឈមណ្ឌលស្រាវជ្រាវ និង

បណ្តុះធុរកិច្ច ព្រមទាំងបំពាក់សម្ភារៈទំនើបៗដើម្បីបម្រើឱ្យការបង្រៀន ការរៀន និងការស្រាវជ្រាវ។ ជាក់ស្តែងតាមរយៈគម្រោងHEIP, កសិដ្ឋាននិងរោងកសិកម្ម ២៣២ ត្រូវបានសាងសង់, បន្ទប់ពិសោធន៍ ៨៦ ត្រូវបានកែលម្អ និងសាងសង់, អគារសិក្សា ៦ និង អន្តេវាសិកដ្ឋាន ៤ ត្រូវបានសាងសង់។

នៅក្នុងគម្រោង HEIP2 មានការសាងសង់ហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត ដែលមានអគារ ៩ គឺ៖ បណ្ណាល័យ ១, មជ្ឈមណ្ឌលបណ្តុះបណ្តាល និងស្រាវជ្រាវវារីវប្បកម្ម ១, អគាររដ្ឋបាល ១, អគារពហុបំណង ៣, អគារឧស្សាហកម្ម៤.០និងផ្ទះបច្ចេកវិទ្យា ១, អគារបណ្តុះបណ្តាលនិងភ្ញាស់ធុរកិច្ច ១ និង អគារផ្សារភ្ជាប់ឧស្សាហកម្ម ១ ព្រមទាំង បន្ទប់ពិសោធន៍, កសិដ្ឋាន និង រោងកសិកម្ម។ ជាមួយគ្នានេះក៏មានការបំពាក់សម្ភារៈ និងឧបករណ៍ពិសោធន៍បន្ថែមទៀតផងដែរ។

ចំណែក គ្រឹះស្ថានឧត្តមសិក្សាឯកជន តាមរយៈថវិកាបង់ថ្លៃ និង ថវិកាលើកលែងពន្ធពីរាជរដ្ឋាភិបាល ក៏បានវិនិយោគត្រឡប់ទៅវិញដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង បំពាក់សម្ភាររូបវន្តបន្ថែម សម្រាប់បម្រើឱ្យការបង្រៀន និងការរៀន។ ក្នុងករណីនេះ គ្រឹះស្ថានឧត្តមសិក្សាឯកជននៅក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ៣៦ ក្នុងចំណោម ៧៧ បានប្រែមុខមាត់ពីការជួលទីតាំង ទៅមានទីតាំងជាកម្មសិទ្ធិផ្ទាល់ខ្លួនទាំងដីធ្លី និងអគារ ។

ខ. ការពង្រឹងការអនុវត្តកម្មវិធីបណ្តាញសាលកវិទ្យាល័យសាយប័រកម្ពុជា

គ្រឹះស្ថានឧត្តមសិក្សា២០ (ឯកជន៧) បានចូលរួមអនុវត្តកម្មវិធីបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា, គ្រូបង្រៀន ១៩០នាក់ និងបុគ្គលិកជំនាញ ៤៨៨នាក់ បានទទួលការបណ្តុះបណ្តាល, កម្មវិធីសិក្សាចំនួន២៩ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន២ បានដាក់ឱ្យអនុវត្ត, មុខវិជ្ជាចំនួន១២៥ និង ៩៦២មេរៀន បានផលិតសម្រាប់ថ្នាលបណ្តុះបណ្តាលអនឡាញ និង និស្សិត ៦ ៥៤២នាក់ បានចូលរៀន[4]។

គ. ការផ្តល់អាហារូបករណ៍

គ្រឹះស្ថានឧត្តមសិក្សា ដែលបានផ្តល់អាហារូបករណ៍តាមរយៈក្រសួងអប់រំ យុវជន និងកីឡា ដល់សិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចូលរៀនថ្នាក់បរិញ្ញាត្រ បានកើនឡើងពី ៣៩ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ១៩ ដល់ ៤២ ក្នុងនោះ គ្រឹះស្ថានឧត្តមសិក្សារដ្ឋ ២០ ។ សិស្សដែលត្រូវទទួលបានអាហារូបករណ៍នេះ បែងចែកជា ៤ ប្រភេទគឺ៖ ១. សិស្សទូទៅ ៦០%, ២. អាទិភាពក្រីក្រ ២០%, ៣. អាទិភាពនារី ១៥% និង ៤. អាទិភាពតំបន់ជាច់ស្រយាល៥%។ ជាមធ្យមក្នុងមួយឆ្នាំ ចំនួនអាហារូបករណ៍ ដែលផ្តល់តាមរយៈក្រសួងអប់រំ យុវជន និងកីឡា មានប្រមាណ ៩ ១៨៨ នាក់ និង សិស្សជាប់អាហារូបករណ៍ជាមធ្យមប្រមាណ ៨១% ។ ជាមួយគ្នានេះ ក្រោមគម្រោងសហភាពអឺរ៉ុប-កម្ពុជា អាហារូបករណ៍ពេញលេញ ត្រូវបានផ្តល់ឱ្យសិស្ស និងនិស្សិត បានចូលរៀនថ្នាក់បរិញ្ញាបត្រ, បរិញ្ញាបត្រជាន់ខ្ពស់ និង បណ្ឌិត ដោយផ្តោតលើមុខជំនាញស្នែម។ បន្ថែមពីលើនេះ កម្មវិធីអាហារូបករណ៍រដ្ឋ តាមរយៈកិច្ចព្រមព្រៀរវាងក្រសួងអប់រំ យុវជន និងកីឡា និង ភាគីបារាំង ត្រូវបានផ្តល់ឱ្យនិស្សិតកម្ពុជា ៥នាក់ ក្នុងមួយឆ្នាំទៅសិក្សាថ្នាក់បណ្ឌិត ដោយផ្តោតចម្បងលើជំនាញស្នែម នៅសាកលវិទ្យាល័យនៃប្រទេសបារាំង។ មកដល់ពេលនេះ មាននិស្សិតចំនួន ៣២ នាក់ បានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតពីកម្មវិធីនេះ។

4 សន្និតបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០២៣-២០២៤ និងទិសដៅឆ្នាំសិក្សា២០២៤-២០២៥។

៣.២.៤. អន្តរជាតូបនីយកម្មឧត្តមសិក្សា

- កម្មវិធីចល័តនិស្សិតអន្តរជាតិនៃអាស៊ី៖ កម្ពុជាបានចូលជាសមាជិកនៅឆ្នាំ ២០២៣, និស្សិត ២៥ នាក់ ស្រី១៨នាក់ បានចូលរួមកម្មវិធីនេះ នៅសាកលវិទ្យាល័យដៃគូ ក្នុងប្រទេសម៉ាឡេស៊ី ជប៉ុន និង ឥណ្ឌូនេស៊ី
- កម្មវិធីសិក្សារួមគ្នា (Joint degree) ជាមួយគ្រឹះស្ថានឧត្តមសិក្សាដៃគូអន្តរជាតិ៖ កម្រិតវិស្វកម និង បរិញ្ញាបត្រ ៤៦, បរិញ្ញាបត្រជាន់ខ្ពស់ ២៣, និង ថ្នាក់បណ្ឌិត ៦
- គម្រោងស្រាវជ្រាវរួមគ្នាជាមួយគ្រឹះស្ថានឧត្តមសិក្សាដៃគូអន្តរជាតិ៖ ៤៤គម្រោង
- កម្មវិធីភាពជាដៃគូជាមួយ៖ គ្រឹះស្ថានឧត្តមសិក្សាគោលដៅចំនួន៥ បានបង្កើតកម្មវិធីភាពជាដៃគូ ចំនួន២៤ ដោយសហការជាមួយសាកលវិទ្យាល័យអន្តរជាតិ ១៩ មកពី១១ប្រទេស
- គ្រឹះស្ថានឧត្តមសិក្សា ចំនួន ២៦ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សាឯកជន ១១ បានបញ្ជូននិស្សិតទៅ សិក្សារយៈពេលខ្លីនៅសាកលវិទ្យាល័យដៃគូនៅសហភាពអឺរ៉ុបក្នុងកម្មវិធីចល័តក្រៅឌីតអន្តរជាតិនៃ គម្រោង Erasmus+។

៣.២.៥. អភិបាលកិច្ចឧត្តមសិក្សា

ដើម្បីពង្រឹងការអនុវត្តអភិបាលកិច្ចឧត្តមសិក្សាឱ្យមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ឯកសារគោលនយោយបាយ និង គោលការណ៍ណែនាំចាំបាច់មួយចំនួនត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់ដូច ខាងក្រោម៖

- គោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សា ឆ្នាំ២០៣០ និង ផែនទីបង្ហាញផ្លូវឧត្តមសិក្សាកម្ពុជា ឆ្នាំ២០៣០ និងក្រោយឆ្នាំ២០៣០។
- យុទ្ធសាស្ត្រអនុវិស័យឧត្តមសិក្សាឆ្នាំ២០២១-២០៣០៖ គ្រឹះស្ថានឧត្តមសិក្សា ៦ បានអនុវត្ត។
- ប្រកាសស្តីពីការគ្រប់គ្រងបុគ្គលិកអប់រំនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈរដ្ឋបាល៖ គ្រឹះស្ថានឧត្តមសិក្សា ២ បានចូលរួមអនុវត្ត។
- ប្រកាសស្តីពីការរៀបចំសៀវភៅណែនាំប្រតិបត្តិការគ្រប់គ្រងហិរញ្ញវត្ថុផ្ទៃក្នុងគ្រឹះស្ថានឧត្តមសិក្សា៖ គ្រឹះស្ថានឧត្តមសិក្សា ៦ បានអនុវត្ត។
- ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យពី Off-line ទៅ Online ៖ គ្រឹះស្ថានឧត្តមសិក្សា ៤៩ បាន ចូលរួមអនុត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យឧត្តមសិក្សា Off-line និងគ្រឹះស្ថានឧត្តមសិក្សា ៤ បាននិងកំពុង អនុវត្តសាកល្បងប្រព័ន្ធគ្រប់គ្រងទិន្នន័យឧត្តមសិក្សា Online។
- សេចក្តីណែនាំស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា៖ គ្រឹះស្ថានឧត្តមសិក្សា២៣ (រដ្ឋ១៣) បានអនុវត្តគោលការណ៍ណែនាំស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា និង បានរៀបចំរបាយការណ៍លទ្ធផល។
- សេចក្តីណែនាំស្តីពីការតាំរបស់និស្សិត៖ គ្រឹះស្ថានឧត្តមសិក្សា ២៣ (រដ្ឋ១៣) បានអនុវត្តគោល ការណ៍ណែនាំ និងបានផលិតរបាយការណ៍ ស្តីពីការតាំរបស់និស្សិតនៅតាមគ្រឹះស្ថានឧត្តមសិក្សា។ ក្នុង

ឆ្នាំ២០២៥ នេះ មានករណីតវ៉ា ៣១៤ករណី និងបានដោះស្រាយជូននិស្សិតរួចរាល់ក្នុងនោះភាគច្រើនទាក់ទងនឹងការផ្តល់សេវាសិក្សារបស់គ្រឹះស្ថានឧត្តមសិក្សា។

- ប្រព័ន្ធគ្រប់គ្រងការជ្រើសរើសនិស្សិតអាហារូបករណ៍ចូលរៀនបរិញ្ញាបត្របានប្តូរពី Off-line ទៅ Online ។
- គោលការណ៍ណែនាំស្តីពីកម្មវិធីផ្តល់អាហារូបករណ៍នៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈក្រោមក្រសួងអ.យ.ក នៃគម្រោងសហភាពអឺរ៉ុប-កម្ពុជាលើបរិវត្តកម្មអប់រំបច្ចេកវិទ្យា២០២៤-២០២៧។
- សេចក្តីណែនាំស្តីពីកម្មវិធីពន្លឿនតាមរយៈការផ្ទេរក្រេឌីត និងទទួលស្គាល់ក្រេឌីតសិក្សារបស់សិស្សមានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ បន្តការសិក្សាកម្រិតបរិញ្ញាបត្រនៅគ្រឹះស្ថានឧត្តមសិក្សាក្រោមក្រសួងអប់រំ យុវជន និងកីឡា។

៣.២.៦. ការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំ

ដើម្បីធានាបាននូវគុណភាពនៃការអប់រំឧត្តមសិក្សាទាំងនៅតាមគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជន ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវប្រព័ន្ធ និងគោលការណ៍ណែនាំនានា និង ផ្តល់ការគាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សាទាំងរដ្ឋ និងឯកជនក្នុងការអនុវត្តប្រព័ន្ធ និងគោលការណ៍ណែនាំទាំងនោះ ដូចខាងក្រោម៖

ក. ការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង

ការធានាគុណភាពអប់រំផ្ទៃក្នុងជាយន្តការស្វ័យវាយតម្លៃរបស់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីកែលម្អគុណភាពជាប្រចាំឆ្ពោះទៅការទទួលស្គាល់គុណភាពដោយទីផ្សារការងារ និង ស្ថាប័នទទួលស្គាល់គុណភាពថ្នាក់ជាតិ, តំបន់ និង អន្តរជាតិ ។

- **ការកសាងគោលនយោបាយ៖** សៀវភៅណែនាំប្រតិបត្តិប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង ត្រូវបានអនុម័តដាក់ឱ្យអនុវត្តនៅឆ្នាំ២០២១ ។ ប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងនេះ ត្រូវបានធ្វើបច្ចុប្បន្នកម្មឡើងវិញដោយធ្វើការឆ្លុះបញ្ចាំងទៅនឹងក្របខ័ណ្ឌអប់រំអនាគតផលសម្រាប់ការអប់រំផ្អែកលើលទ្ធផល, ស្តង់ដាគុណភាពរបស់ ACC និង ស្តង់ដា និងសូចនាករបស់ AUN-QA ដោយគណៈកម្មការបច្ចេកទេសធានាគុណភាពអប់រំផ្ទៃក្នុង (DGHE-IQA Team)។ គណៈកម្មការបច្ចេកទេសនេះ មានសមាសភាពមកពីអគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជន។
- **ការកសាងមនុស្ស៖** ដើម្បីកសាងគោលនយោបាយសម្រាប់កែលម្អគុណភាពជាប្រចាំនៅឧត្តមសិក្សា គណៈកម្មការដឹកនាំ គណៈកម្មការបច្ចេកទេស និង ក្រុមលេខាធិការដ្ឋាន ដែលមានសមាសភាពចម្រុះមកពីក្រសួងអប់រំ យុវជន និងកីឡា អគ្គនាយកដ្ឋានឧត្តមសិក្សា និង គ្រឹះស្ថានឧត្តមសិក្សា៤៦រូប ត្រូវបានបង្កើត។ គណៈកម្មការនេះ មានភារកិច្ចដឹកនាំ, សិក្សាស្រាវជ្រាវឯកសារពាក់ព័ន្ធ, សរសេរគោលនយោបាយ ព្រមទាំងសាកល្បងរៀបចំរបាយការណ៍ស្វ័យវាយតម្លៃ ស្របតាមគោលការណ៍ណែនាំស្តីពីការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងសម្រាប់គ្រឹះស្ថានឧត្តមសិក្សា។ បច្ចុប្បន្ននេះ បុគ្គលិកអប់រំចំនួន ១១១ នាក់មកពីអគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សាចំនួន១២ (រដ្ឋ៩

និងឯកជន៣) ត្រូវបានបណ្តុះបណ្តាលសម្រាប់អនុវត្តគោលការណ៍ណែនាំស្តីពីការវាយតម្លៃគុណភាពអប់រំផ្នែកក្នុងនេះ។

- **ការធ្វើស្វ័យវាយតម្លៃកម្មវិធីៈ** គ្រឹះស្ថានឧត្តមសិក្សា ៤៩ (ឯកជន ៣០) បានធ្វើការស្វ័យវាយតម្លៃគុណភាពកម្រិតកម្មវិធីចំនួន១០៣ ស្របតាមសៀវភៅណែនាំប្រតិបត្តិប្រព័ន្ធធានាគុណភាពអប់រំផ្នែកក្នុងដែលមិនទាន់ធ្វើបច្ចុប្បន្នកម្ម។ គ្រឹះស្ថានឧត្តមសិក្សា ១៥ (រដ្ឋ ៩) បានទទួលការបណ្តុះបណ្តាលប្រព័ន្ធធានាគុណភាពអប់រំផ្នែកក្នុង ដែលបានធ្វើបច្ចុប្បន្នកម្មនេះ និង គ្រឹះស្ថានឧត្តមសិក្សារដ្ឋ ៥ បានអនុវត្តសាកល្បងដោយធ្វើការស្វ័យវាយតម្លៃលើកម្មវិធីសិក្សាចំនួន ៥។

ខ. ការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំរបស់បណ្តាញសាកលវិទ្យាល័យអាស៊ាន

- **ការកសាងគោលនយោបាយៈ** កិច្ចព្រមព្រៀងភាពជាដៃគូរយៈពេលវែង (២០២៦-២០៣០) រវាងអគ្គនាយកដ្ឋានឧត្តមសិក្សា និង AUN អមដោយផែនការសកម្មភាព ៥ឆ្នាំ ត្រូវបានចុះហត្ថលេខា នៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៦ ។
- **ការកសាងមនុស្សៈ** បុគ្គលិកអប់រំ ១៦៣នាក់ មកពីអគ្គនាយកដ្ឋានឧត្តមសិក្សា និង គ្រឹះស្ថានឧត្តមសិក្សាគោលដៅ៥ បានទទួលការបណ្តុះបណ្តាលវគ្គ «AUN-QA សម្រាប់ការវាយតម្លៃកម្មវិធី (កម្រិត ១)» ដោយអ្នកជំនាញមកពី AUN-QA, បុគ្គលិកអប់រំ ១៧ បានទទួលការបណ្តុះបណ្តាលវគ្គ «មន្ត្រីវាយតម្លៃ សម្រាប់ការវាយតម្លៃកម្មវិធី (កម្រិត២)» នៅប្រទេសហ្វីលីពីន និងប្រទេសម៉ាឡេស៊ី, បុគ្គលិកអប់រំ ៤២ នាក់ បានទទួលការបណ្តុះបណ្តាលវគ្គ «AUN-QA សម្រាប់ការវាយតម្លៃកម្រិត ស្តាប់ន (កម្រិត៣)» និង បុគ្គលិកអប់រំ ១៩៩ នាក់ បានទទួលការបណ្តុះបណ្តាលវគ្គ «AUN-QA សម្រាប់ការសរសេររបាយការណ៍ស្វ័យវាយតម្លៃកម្រិតកម្មវិធី»។
- **ការធ្វើស្វ័យវាយតម្លៃកម្មវិធីៈ** បច្ចុប្បន្ន កម្មវិធីសិក្សា ២ (មួយរបស់វិទ្យាស្ថានខេមអេដ និង មួយទៀតរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ) បានការទទួលស្គាល់គុណភាពពី AUN-QA និង មានអ្នកវាយតម្លៃគុណភាពកម្រិតតំបន់អាស៊ាន AUN-QA ៣នាក់ មកពីវិទ្យាស្ថានខេមអេដ។ កម្មវិធីសិក្សា ៤ (សាកលវិទ្យាល័យភូមិន្ទភ្នំពេញមាន ២, វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា មាន ១ និង សាកលវិទ្យាល័យជាតិបាត់ដំបង មាន ១) កំពុងត្រៀមសម្រាប់ទទួលការវាយតម្លៃដោយ AUN-QA នៅខែធ្នូ ឆ្នាំ ២០២៦ខាងមុខនេះ ។ ជាមួយគ្នានេះ គ្រឹះស្ថានឧត្តមសិក្សាគោលដៅ៥ បាននិងកំពុងរៀបចំរបាយការណ៍ស្វ័យវាយតម្លៃកម្រិតកម្មវិធីចំនួន២០ ទៀត សម្រាប់ទទួលការវាយតម្លៃដោយ AUN-QA នៅឆ្នាំបន្តបន្ទាប់ខាងមុខទៀត ។

គ. ការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្នែកក្រៅ

គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ធ្វើការវាយតម្លៃ និងផ្តល់ការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិកម្រិតស្តាប់ន ចំនួន៥៨គ្រឹះស្ថានឧត្តមសិក្សា (រដ្ឋ២៣ និងឯកជន៣៥) និងកម្រិតកម្មវិធី ចំនួន១០ ដែលជារបស់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ ៩ និងឯកជន ១ ។

៣.២.៧. ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន

តាមរយៈគម្រោងវិនិយោគទាំងបីខាងលើនេះ និងកម្មវិធីអាហារូបករណ៍រដ្ឋទៅសិក្សានៅប្រទេសបារាំង បុគ្គលិកអប់រំចំនួន ៤២៨នាក់ បានទទួលការឧបត្ថម្ភសម្រាប់សិក្សាថ្នាក់ក្រោយបរិញ្ញាបត្រ ក្នុងនោះថ្នាក់បណ្ឌិតមាន១៤៣នាក់ ។

៤. ការប្រឈម

- **ការចូលរៀន និងសមធម៌៖** ហេដ្ឋារចនាសម្ព័ន្ធ ទំហំទីតាំង និងបច្ចេកវិទ្យាឌីជីថល ពុំទាន់ឆ្លើយតបសម្រាប់កែលម្អការចូលរៀន សមធម៌ និងគុណភាព និងអត្រារួមនៃការចូលរៀននៅទាប,
- **គុណភាព និងភាពឆ្លើយតប៖** ការធ្វើទំនើបកម្មកម្មវិធីសិក្សាមានល្បឿនយឺត, ភាគរយគ្រូបង្រៀនមានកម្រិតបណ្ឌិតនៅទាប
- **ការស្រាវជ្រាវ និងនវានុវត្តន៍៖** សមត្ថភាពនៃការស្រាវជ្រាវ និងការគ្រប់គ្រងការស្រាវជ្រាវនៅគ្រឹះស្ថានឧត្តមសិក្សានៅមានគម្លាតធំ ពិសេសសមត្ថភាពធ្វើពាណិជ្ជកម្មលើផលិតផលស្រាវជ្រាវ
- **អន្តរជាតូបនីយកម្មឧត្តមសិក្សា៖** កម្មវិធីអន្តរជាតិនៅមានតិចតួច (កម្មវិធីរួមគ្នា/កម្មវិធីទ្វេ/កម្មវិធីមានការទទួលស្គាល់កម្រិតអន្តរជាតិ ។ល។), និស្សិតចូលរួមកម្មវិធីចល័តមានចំនួនតិច (ការចូលរួមកម្មវិធីចល័តនិស្សិតអន្តរជាតិនៅអាស៊ី, AIMS), និង សមត្ថភាពភាសាអង់គ្លេសនៅតាមគ្រឹះស្ថានឧត្តមសិក្សានៅមានកម្រិតទាប
- **អភិបាលកិច្ចឧត្តមសិក្សា៖** សមត្ថភាព នៃការពង្រឹងអភិបាលកិច្ច និងការធ្វើទំនើបកម្មស្ថាប័ននៅមានគម្លាត ដើម្បីទទួលបានស្វ័យភាព និងធានាបាននូវតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព
- **ប្រព័ន្ធ និងយន្តការធានាគុណភាពអប់រំផ្ទៃក្នុង៖** ការរៀបចំរចនាសម្ព័ន្ធ មុខងារ និងយន្តការ ព្រមទាំងសមត្ថភាពបុគ្គលិកអប់រំ នៅមានគម្លាតធំ សម្រាប់ដំណើរការស្វ័យវាយតម្លៃគុណភាព។

៥. ដំណោះស្រាយ

- **កែលម្អការចូលរៀន និង សមធម៌៖** បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់សម្ភារូបវ័ន្ត, ផ្តល់អាហារូបករណ៍ពេញលេញ និង បន្តអនុវត្តកម្មវិធីភាពជាដៃគូរវាងគ្រឹះស្ថានឧត្តមសិក្សា និងសាលាមធ្យមសិក្សា, ពង្រីកទីតាំងសាកលវិទ្យាល័យដែលចង្អៀត,
- **កែលម្អគុណភាព នៃកម្មវិធីអប់រំ៖** ពន្លឿនការធ្វើទំនើបកម្មកម្មវិធីសិក្សាតាម FEF-for-OBE នៅតាមគ្រឹះស្ថានឧត្តមសិក្សានៅទូទាំងប្រទេស,
- **លើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍៖** បន្តគាំទ្រគម្រោងស្រាវជ្រាវសម្រាប់ធ្វើពាណិជ្ជកម្មលើផលិតផលស្រាវជ្រាវ និងបង្កើនការវិនិយោគជាតិលើការស្រាវជ្រាវដើម្បីបណ្តុះ និងថែបំប៉នអ្នកស្រាវជ្រាវវ័យក្មេង,
- **កែលម្អអភិបាលកិច្ច និងភាពជាអ្នកដឹកនាំ៖** ធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ច និងបន្តកសាងសមត្ថភាពគ្រឹះស្ថានឧត្តមសិក្សា ឆ្ពោះទៅការប្រតិបត្តិស្វ័យភាពពេញលេញ,
- **ប្រព័ន្ធ និង យន្តការធានាគុណភាពអប់រំផ្ទៃក្នុង៖** កសាងសមត្ថភាពអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងឱ្យមានប្រសិទ្ធភាពខ្ពស់,

- **ប្រព័ន្ធធានាគុណភាព AUN-QA៖** កសាងសមត្ថភាពអនុវត្តប្រព័ន្ធធានាគុណភាព AUN-QA ដើម្បីឈានទៅបានការទទួលស្គាល់គុណភាពកម្រិតតំបន់ និង អន្តរជាតិ, និង
- **កសាងសមត្ថភាព៖** បង្កើនគុណវុឌ្ឍិថ្នាក់បណ្ឌិត និង កែលម្អសមត្ថភាពគ្រូបង្រៀន, អ្នកស្រាវជ្រាវ និងមន្ត្រីប្រតិបត្តិ ដើម្បីអនុវត្តកំណែទម្រង់កម្មវិធីអប់រំ, ការស្រាវជ្រាវ និង អភិបាលកិច្ច ប្រកបដោយប្រសិទ្ធភាពនិង ចីរភាព។

៦. សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេលជាង១០ឆ្នាំចុងក្រោយ នៃការអនុវត្តកម្មវិធីកំណែទម្រង់ស៊ីជម្រៅ វិស័យឧត្តមសិក្សា មានការរីកចម្រើនគួរឱ្យកត់សម្គាល់ទាំងបរិមាណ និង គុណភាព។ ជាក់ស្តែង អត្រារួមនៃការសិក្សានៅឧត្តមសិក្សា មានការកើនឡើងគួរឱ្យកត់សម្គាល់គឺ កើនពី ១៣,៨០% នៅឆ្នាំ២០២១ ដល់ ១៩% នៅឆ្នាំ២០២៥។ អត្រានេះ បានកើនឡើងជាមធ្យមប្រមាណ ០,៨៣% ក្នុងមួយឆ្នាំ។ ការរីកចម្រើនទាំងនេះ គឺមានការចូលរួមពីវិស័យឯកជន ដែលរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំង តាមរយៈកម្មវិធីភាពជាដៃគូរដ្ឋ និងឯកជន។ ជាពិសេស ការអនុវត្តកម្មវិធីវិនិយោគលើយុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សា តាមរយៈគម្រោងកែលម្អការអប់រំឧត្តមសិក្សា ។

អត្រារួមនៃការសិក្សានៅឧត្តមសិក្សា នឹងត្រូវកើនដល់២៣% នៅឆ្នាំ២០២៨ ដែលជាចំណុចដៅនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ ។ ក្នុងន័យនេះ ការគាំទ្រជានយោបាយ និង ជាហិរញ្ញវត្ថុបន្ថែមទៀតពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និង ប្រទេសជាមិត្ត ពិតជាត្រូវការចាំបាច់ និងបន្ទាន់ ដើម្បីអភិវឌ្ឍឧត្តមសិក្សាឱ្យមានសមត្ថភាពពេញលេញក្នុងការឈានទៅឱ្យសម្រេចបាននូវចំណុចដៅនៃសូចនាករនេះ នៅឆ្នាំ២០២៨ និង ការបណ្តុះបណ្តាលមូលធនមនុស្សឆ្លើយតបទៅនឹងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ។

៧.ឧបសម្ព័ន្ធ៖ រចនាសម្ព័ន្ធគ្រឹះស្ថានឧត្តមសិក្សា

ឧបសម្ព័ន្ធ១៖សាកលវិទ្យាល័យភូមិន្ទភ្នំពេញ



រចនាសម្ព័ន្ធគាំ១០ឆ្នាំចុងក្រោយនៅ
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

១. សាថាន

បន្ទាប់ពីប្រទេសកម្ពុជាបានទទួលឯករាជ្យពីប្រទេសបារាំងនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ក្រោមស្នាព្រហស្តដឹកនាំរបស់ព្រះបរមរតនកោដ្ឋព្រះបាទ នរោត្តម សីហនុ សាកលវិទ្យាល័យជាតិកម្ពុជាដ៏ទំនើបដំបូងគេត្រូវបានបង្កើតឡើងនៅថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៦០ ដែលគេស្គាល់ថាជា សាកលវិទ្យាល័យភូមិន្ទខ្មែរ ហើយក្រោយមកត្រូវបានផ្លាស់ប្តូរឈ្មោះផ្សេងៗ ជាច្រើនលើកច្រើនសារៗ ក្រោយពីថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ សាកលវិទ្យាល័យដ៏ចំណាស់ជាងគេមួយនេះ បានប្រែក្លាយជាសាកលវិទ្យាល័យសាធារណៈដ៏ធំនិងចំណាស់ជាងគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានបើកទ្វារឱ្យដំណើរការឡើងវិញនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៨០។ ទន្ទឹមនិងនេះផងដែរ សាកលវិទ្យាល័យដ៏ចំណាស់ជាងគេមួយនេះ ក៏ត្រូវបានប្តូរឈ្មោះជាចុងក្រោយមកជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស.ភ.ភ.ព ឬ RUPP) តាមអនុក្រឹត្យលេខ**៣១អនក្រ.បក** ដែលចុះថ្ងៃទី២១ ខែ មិថុនាឆ្នាំ១៩៩៦ និងត្រូវបានប្រែក្លាយមកជាជាគ្រឹះស្ថានសាធារណៈរដ្ឋបាល តាមអនុក្រឹត្យលេខ **១១៤ អនក្រ.បក** ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១។ សព្វថ្ងៃនេះ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បាននឹងកំពុងបណ្តុះបណ្តាលទាំងថ្នាក់បរិញ្ញាបត្រ និងថ្នាក់ក្រោយឧត្តមសិក្សាលើជំនាញឯកទេសជាច្រើនផ្នែកដូចជា៖ វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គមនិងមនុស្សសាស្ត្រ សិក្សាអភិវឌ្ឍន៍ វិស្វកម្ម អប់រំ សិក្សាអន្តរ-ជាតិ និងគោលនយោបាយសាធារណៈ និងភាសាបរទេសជាដើម។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ គឺជាសាកលវិទ្យាល័យសាធារណៈដែលមានអាយុកាលចាស់ជាងគេ និងធំជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា។ សាកលវិទ្យាល័យត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយជាគ្រឹះស្ថានឈានមុខគេលើការបង្រៀន ការស្រាវជ្រាវ និងសេវាសហគមន៍នៅកម្រិតការអប់រំឧត្តមសិក្សានៅក្នុងប្រទេស។ ការអប់រំនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញកំពុងគ្របដណ្តប់លើមុខជំនាញចម្រុះ តាមរយៈការបំពាក់បំប៉នដល់និស្សិតបញ្ចប់ការសិក្សាឱ្យមានទាំងសមត្ថភាពផ្នែកសិក្សា ការស្រាវជ្រាវ និងការទទួលខុសត្រូវចំពោះសង្គមផងដែរ។ កម្មវិធីសិក្សា និងបណ្តុះបណ្តាលរបស់ស្ថាប័នគ្រឹះស្ថានសាធារណៈមួយនេះផ្តល់អាទិភាពលើការគិតបែបត្រិះរិះពិចារណា ការដោះស្រាយបញ្ហា និងភាពបត់បែនក្នុងការសម្របខ្លួន ដែលសុទ្ធសឹងជាជំនាញដ៏ចាំបាច់សម្រាប់ការឆ្លើយតបទៅនឹងបញ្ហាប្រឈមនានានៃតម្រូវការសង្គមដែលកំពុងវិវត្ត

យ៉ាងឆាប់រហ័ស។ តាមរយៈការបណ្តុះបណ្តាល និងអភិវឌ្ឍគុណសម្បត្តិទាំងនេះ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ជានាថា និស្សិតបញ្ចប់ការសិក្សាមិនត្រឹមតែមានលទ្ធភាពទទួលបានការងារសមរម្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានសមត្ថភាពចូលរួមចំណែកប្រកបដោយប្រសិទ្ធភាពក្នុងការអភិវឌ្ឍប្រទេសកម្ពុជាផងដែរ។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ គឺជាគ្រឹះស្ថានឧត្តមសិក្សាពហុជំនាញ និងឯកទេស ដែលផ្តល់ការបណ្តុះបណ្តាលលើវិស័យវិទ្យាសាស្ត្រ សង្គមសាស្ត្រ និងមនុស្សសាស្ត្រ ភាសាបរទេស វិស្វកម្ម សិក្សាអភិវឌ្ឍន៍ សិក្សាអប់រំ សិក្សាអន្តរជាតិ និងគោលនយោបាយសាធារណៈ។ សាកលវិទ្យាល័យទទួលបានការគាំទ្រផ្នែកថវិកា និងបច្ចេកទេសពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈគម្រោង HEIP ព្រមទាំងដៃគូអភិវឌ្ឍន៍សំខាន់ៗ រួមមាន KOICA, JICA, SIDA, រដ្ឋាភិបាលជប៉ុន និងធនាគារពិភពលោក។

តាមរយៈការគាំទ្រទាំងនេះ សាកលវិទ្យាល័យបានអភិវឌ្ឍ និងកែលម្អខ្លួនគួរជាទីមោទនៈ ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងគោលនយោបាយ និងអាទិភាពអភិវឌ្ឍថ្នាក់ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។

តារាងទី១ បង្ហាញថា គិតត្រឹមខែកក្កដា ឆ្នាំ២០២៦ សាកលវិទ្យាល័យមានបុគ្គលិកសរុបចំនួន ១,១១៥ នាក់ ក្នុងនោះបុគ្គលិកស្រីមាន ៣៦៧ នាក់ ស្មើនឹងប្រមាណ ៣២.៩% នៃបុគ្គលិកសរុប។ ដែលក្នុងនោះមានបុគ្គលិកក្របខណ្ឌរដ្ឋក្នុងរចនាសម្ព័ន្ធមានចំនួន ៣៩៧ នាក់ ក្នុងនោះស្រី ៩៧ នាក់។ ក្នុងចំណោមនេះ មានបុគ្គលិកបង្រៀន ២២៧ នាក់ និងបុគ្គលិករដ្ឋបាល ១៦៤ នាក់។ តាមកម្រិតសញ្ញាបត្រ បុគ្គលិកភាគច្រើនមានកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ២៨៣ នាក់ បន្ទាប់មកកម្រិតបណ្ឌិត និង Postdoctoral ចំនួន ១០១ នាក់ ដែលបង្ហាញពីសមត្ថភាពវិជ្ជាជីវៈ និងសក្តានុពលធនធានមនុស្សកម្រិតខ្ពស់របស់សាកលវិទ្យាល័យ។ រីឯ ចំណែកបុគ្គលិកកិច្ចសន្យាមានចំនួន ៧១៨ នាក់ ក្នុងនោះស្រី ២៧០ នាក់។ បុគ្គលិកបង្រៀនមានចំនួន ៤០០នាក់ ខណៈបុគ្គលិករដ្ឋបាលមាន ៣១៨ នាក់។ តាមកម្រិតសញ្ញាបត្រ បុគ្គលិកកិច្ចសន្យាភាគច្រើនមានកម្រិតបរិញ្ញាបត្រចំនួន ៣៩៦ នាក់ បន្ទាប់មកបរិញ្ញាបត្រជាន់ខ្ពស់ ២៧២ នាក់ និងបណ្ឌិត ៥០ នាក់។ សរុបមក ទិន្នន័យនេះឆ្លុះបញ្ចាំងថា សាកលវិទ្យាល័យមានកម្លាំងធនធានមនុស្សចម្រុះទាំងផ្នែកបង្រៀន និងរដ្ឋបាល ដើម្បីគាំទ្រដល់ការអប់រំ ការស្រាវជ្រាវ និងការផ្តល់សេវារដ្ឋបាលប្រកបដោយប្រសិទ្ធភាព។

តារាងទី១. ចំនួនបុគ្គលិកក្របខណ្ឌរដ្ឋ និងបុគ្គលិកកិច្ចសន្យា (គិតត្រឹម ខែកក្កដា ឆ្នាំ២០២៦)

១.បុគ្គលិកក្របខណ្ឌរដ្ឋក្នុងរចនាសម្ព័ន្ធ	**ចំនួនបុគ្គលិក**
១/-ក្រុមប្រឹក្សាភិបាល	០៧នាក់(នារី ០ នាក់)
២/-គណៈគ្រប់គ្រង	០៦ នាក់(នារី១នាក់)
៣/-បុគ្គលិកបង្រៀន	២២៧ នាក់(នារី៥៧នាក់)
៤/-បុគ្គលិករដ្ឋបាល	១៦៤ នាក់(នារី៣៩នាក់)
សរុប	៣៩៧ នាក់(នារី៩៧នាក់)
កម្រិតអប់រំ (ឬសញ្ញាបត្រ)	**ចំនួន**
១/-បណ្ឌិត និង Post Doctoral	១០១ នាក់(នារី២០នាក់)
២/-បរិញ្ញាបត្រជាន់ខ្ពស់	២៨៣នាក់(នារី៦៩នាក់)
៣/-បរិញ្ញាបត្រ	១៣ នាក់(នារី៨នាក់)

សរុប	៣៩៧ នាក់(នារី៩៧នាក់)

២.បុគ្គលិកកិច្ចសន្យា	**ចំនួន**
១/-បុគ្គលិកបង្រៀន	៤០០ នាក់(នារី១១៤នាក់)
២/-បុគ្គលិករដ្ឋបាល	៣១៨ នាក់(នារី១៥៦នាក់)
សរុប	៧១៨ នាក់(នារី២៧០នាក់)
កម្រិតសញ្ញាបត្រ	**ចំនួន**
១/-បណ្ឌិត	៥០ នាក់(នារី៦នាក់)
២/-បរិញ្ញាបត្រជាន់ខ្ពស់	២៧២នាក់(នារី៧០នាក់)
៣/-បរិញ្ញាបត្រ	៣៩៦ នាក់(នារី១៩៤នាក់)
សរុប	៧១៨ នាក់(នារី២៧០នាក់)

តារាងទី២ បង្ហាញថា ក្នុងឆ្នាំសិក្សា ២០២៥–២០២៦ សាកលវិទ្យាល័យមាននិស្សិតសរុបចំនួន ៣០,៧៨៩ នាក់ ក្នុងនោះនិស្សិតស្រីមានចំនួន ១៨,៦០៤ នាក់ ស្មើនឹងប្រមាណ ៦០.៤% នៃនិស្សិតសរុប។ និស្សិតបង់ថ្លៃសិក្សាមានចំនួន ២៦,៦៣៨ នាក់ ក្នុងនោះស្រី ១៥,៨៥៤ នាក់ ខណៈនិស្សិតទទួលអាហារូបករណ៍ មានចំនួន ៤,១៥១ នាក់ ក្នុងនោះស្រី ២,៧៥០ នាក់។ ទិន្នន័យនេះ តាមកម្រិតសិក្សា ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន មានចំនួននិស្សិតច្រើនជាងគេ គឺ ៩,៧៥៥ នាក់ បន្ទាប់មកថ្នាក់បរិញ្ញាបត្រឆ្នាំទី២ មាន ៧,៧១៦ នាក់ និងថ្នាក់បរិញ្ញាបត្រឆ្នាំទី៤ មាន ៦,៨២៦ នាក់។ លទ្ធផលនេះបង្ហាញថា សាកលវិទ្យាល័យមានការចូលរួមយ៉ាងសកម្មពីនិស្សិតស្រីនៅគ្រប់កម្រិតសិក្សា ជាពិសេសក្នុងក្រុមនិស្សិតទទួលអាហារូបករណ៍ ដែលនិស្សិតស្រីមានសមាមាត្រប្រមាណ ៦៦.២%។

តារាងទី២. ស្ថានភាពនិស្សិតថ្នាក់អាហារូបករណ៍ និងបង់ថ្លៃសិក្សា(2025-2026)

ស្ថានភាពនិស្សិត (2025-2026)	បង់ថ្លៃ	ស្រី	អាហារូបករណ៍	ស្រី
ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន	8275	4801	1480	949
ថ្នាក់បរិញ្ញាបត្រ ឆ្នាំទី២	6651	4009	1065	715
ថ្នាក់បរិញ្ញាបត្រ ឆ្នាំទី៣	4485	2739	816	531
ថ្នាក់បរិញ្ញាបត្រ ឆ្នាំទី៤	6036	3795	790	555
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់	1058	477		
ថ្នាក់បណ្ឌិត	133	33		

២. សកម្មភាពដែលសម្រេចបានរយៈពេល ១០ឆ្នាំចុងក្រោយ

២.១. អភិបាលកិច្ច ស្ម័យភាព និងការធានាគុណភាព

២.១.១. អភិបាលកិច្ច និងស្ម័យភាព និងស្ម័យភាព

ស.ភ.ភ.ព. មានចក្ខុវិស័យ ក្លាយជាសាកលវិទ្យាល័យដែលឈានមុខរបស់កម្ពុជា ដោយមានកត្តិនាមថ្នាក់តំបន់ក្នុងការបង្រៀននិងរៀន ការស្រាវជ្រាវនានុវត្តន៍ និងព្រមទាំងការចូលរួមសកម្មភាពសង្គមក្នុងឆ្នាំ ២០៣០។ ដើម្បីសម្រេចបានបេសកម្មដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្ររបស់ ស.ភ.ភ.ព. បានរៀបចំឯកសារគតិយុត្តមួយចំនួនសម្រាប់ការងារអភិបាលកិច្ច និងស្វ័យភាពដូចខាងក្រោម៖

- ផែនការយុទ្ធសាស្ត្រ ២០២៦-២០៣០
- គោលនយោបាយស្រាវជ្រាវស្តីពីការអភិវឌ្ឍស្រាវជ្រាវ និងនវានុវត្តន៍ ២០២០-២០២៤
- សៀវភៅណែនាំស្តីពីការគ្រប់គ្រងការស្រាវជ្រាវនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ២០២៣-២០៣០។

ក្នុងឆ្នាំ២០២៦ មជ្ឈមណ្ឌលបច្ចេកវិទ្យាព័ត៌មាន (IT Center) បានរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យការស្រាវជ្រាវ ហើយការិយាល័យស្រាវជ្រាវកំពុងប្រើប្រាស់ដើម្បីប្រមូលទិន្នន័យទាក់ទងការស្រាវជ្រាវនៅ ស.ភ.ភ.ព. ផ្តោតលើគម្រោងស្រាវជ្រាវ និងការបោះពុម្ពអត្ថបទស្រាវជ្រាវថ្នាក់ជាតិ និងអន្តរជាតិ។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ គឺមាន៣(បី)ទីតាំងដែលក្នុងនោះទីតាំងគោលស្ថិតនៅក្នុងខណ្ឌទួលគោក តាមបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ី ទីតាំងទី២(ពីរ) ស្ថិតនៅក្នុងខណ្ឌសែនសុខ តាមបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ី និងទីតាំងទី៣(បី)ជាទីតាំងថ្មីនៅខណ្ឌជ្រោយចង្វារ ជិតវិមានឈ្នះឈ្នះ គ្របដណ្តប់លើក្រឡាផ្ទៃដីចំនួន ២៨១ ៦៨៤.៣ម^{2}។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញមានអគារសរុបចំនួន២៩អគារ ក្នុងនោះក៏មាន បណ្ណាល័យ **ហ៊ុន សែន** មួយផងដែរ។ ដើម្បីបម្រើផ្នែកវិទ្យាសាស្ត្រឱ្យកាន់តែមានប្រសិទ្ធភាព សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានរៀបចំបន្ទប់ពិសោធន៍សរុបចំនួន៧៤ ក្នុងនោះ បន្ទប់ពិសោធន៍សម្រាប់ការសិក្សាមានចំនួន ៦៤បន្ទប់ និងបន្ទប់ពិសោធន៍សម្រាប់ការស្រាវជ្រាវមានចំនួន១០បន្ទប់ផងដែរ។

២.១.២. ការធានាគុណភាព

ក. ធ្វើទំនើបកម្ម និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា

សាកលវិទ្យាល័យភូមិន្ទភ្នំពេញធ្វើទំនើបកម្ម និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា និងបណ្តុះបណ្តាលដូចខាងក្រោម៖

- រៀបចំស្តង់ដា និងឧបករណ៍សម្រាប់ការវាយតម្លៃទទួលស្គាល់គុណភាពកម្មវិធីសិក្សា (Program Accreditation) លើកម្មវិធីសិក្សាសំខាន់ៗរបស់គ្រឹះស្ថានឧត្តមសិក្សាដើម្បី ពង្រឹងគុណភាពការសិក្សា និងប្រើប្រាស់ជាយន្តការក្នុងការទទួលស្គាល់ទៅលើការផ្ទេរក្រេឌីតការសិក្សា (Credit Transfer) ក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សា ដែលឆ្ពោះទៅការកាត់បន្ថយអត្រាបោះបង់ការសិក្សា និងដើម្បីបង្កភាពងាយស្រួល ដល់ការសិក្សាពេញមួយជីវិតរបស់និស្សិត។
- រៀបចំយន្តការពិនិត្យតាមដាន ដើម្បីជំរុញការអនុវត្តកម្មវិធីសិក្សាឱ្យស្របតាមសូចនាករ និងលទ្ធផលរំពឹងទុករបស់កម្មវិធី និងតាមដំនាញ និងមុខវិជ្ជា។

ខ.ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ

សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានកែលម្អហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួនសំខាន់ៗមួយចំនួន៖

- សាងសង់អន្តេវាសិកដ្ឋាន ចំនួន ០១ (មួយ)
- សាងសង់អគារ STEM Building ចំនួន ០១ (មួយ)
- ធ្វើទំនើបកម្ម និងបង្កើតមន្ទីរពិសោធន៍ ចំនួន៦៤

- សាងសង់អគារមជ្ឈមណ្ឌលសហប្រតិបត្តិការសាកលវិទ្យាល័យ-សហគ្រាស University Industry Cooperation Center ចំនួន ០១ (មួយ)
- សាងសង់អគារមជ្ឈមណ្ឌលជាតិបណ្តុះធុរកិច្ចថ្មីនៃកម្ពុជា National Incubation Center of Cambodia ចំនួន ០១ (មួយ)
- សាងសង់អគារមជ្ឈមណ្ឌល Cambodia Japan Digital Manufacturing Center ចំនួន ០១ (មួយ)
- បង្កើត Smart Classroom ចំនួន ០១ (មួយ)។

២.២. ការបណ្តុះបណ្តាល ការងារបន្ទាប់ពីបញ្ចប់ការសិក្សា និងការបង្កើនសង្គម

២.២.១. ការធ្វើទំនើបកម្ម និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា

ធ្វើទំនើបកម្មនិងការអភិវឌ្ឍកម្មវិធីសិក្សាដោយផ្អែកលើលទ្ធផល (Outcome-Based Education Program-OBE) តាមក្របខណ្ឌអប់រំអនាគតផល (បានរៀបចំចប់ចំនួណ ៦កម្មវិធី និងកំពុងកែលម្អចំនួន ១២កម្មវិធី) រួមទាំងការផ្តល់សិទ្ធិដល់គ្រឹះស្ថានឧត្តមសិក្សា ក្នុងការកែសម្រួល និងការអនុវត្តកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន រួមទាំងការបញ្ចូលមុខវិជ្ជាថ្មីៗ និងការបង្កើតកម្មវិធីសិក្សាជំនាញថ្មី ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃបច្ចេកវិទ្យាឌីជីថល និងបរិបទនៃឧស្សាហកម្ម ៤.០ និងដើម្បីធានានូវគុណភាពនៃការអប់រំសម្រាប់ការប្រកួតប្រជែង ការទទួលស្គាល់គុណភាពកម្រិតតំបន់ និងអន្តរជាតិ នាពេលអនាគតតាមរយៈ៖

- ពង្រឹងគុណភាពការបណ្តុះបណ្តាលគ្រប់កម្រិតផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា (STEM) និងកសិកម្ម ព្រមទាំងកម្មវិធីអាទិភាពដទៃទៀត ស្របតាមស្តង់ដាជាតិ និងអន្តរជាតិ។
- បន្តអនុវត្តកម្មវិធីបណ្តុះបណ្តាល ដោយសហការជាមួយវិស័យឧស្សាហកម្ម និង សាកលវិទ្យាល័យជាតិនិងអន្តរជាតិ ជាលក្ខណៈ Tailor-Made ឬ Dual Education Programs ដើម្បីឆ្លើយតបនឹងនិន្នាការបច្ចុប្បន្ន និងតម្រូវការទីផ្សារការងារ។
- រៀបចំកម្មវិធីសិក្សា ដែលផ្តោតលើការសិក្សាគម្រោង និងការស្រាវជ្រាវ និងបន្តរឹតបន្តឹងស្តង់ដានៃការវាយតម្លៃលទ្ធផលសិក្សា ជាមួយកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល។
- បន្តជំរុញការបង្កើត និងអនុវត្តប្រព័ន្ធគ្រប់គ្រងការសិក្សា (Learning Management System-LMS) ដើម្បីបង្កើនប្រសិទ្ធភាពការសិក្សាដោយការប្រើប្រាស់ធនធានសិក្សារួម ការតាមដាន និងការវាយតម្លៃ និងការឆ្លើយតបទៅនឹងភាពបត់បែននៃពេលវេលាសិក្សារបស់និស្សិត ក៏ដូចជាកាត់បន្ថយបញ្ហាខ្វះខាតធនធានសិក្សា និងបន្ទុកចំណាយផ្សេងៗ។
- ពង្រឹង និងពង្រីកវិសាលភាពការអនុវត្តបណ្តាញសាកលវិទ្យាល័យសាយប័រ (Cyber University Network) ជាមួយគ្រឹះស្ថានឧត្តមសិក្សាគោលដៅ ទាំងក្នុងរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្ត ដើម្បីលើកកម្ពស់ការប្រើប្រាស់ធនធានរួមគ្នាតាមរយៈការអប់រំឌីជីថល។
- វិនិយោគបន្ថែម ដើម្បីធ្វើឱ្យប្រសើរឡើងនូវមន្ទីរពិសោធន៍ កសិដ្ឋាន អន្តេវាសិកដ្ឋាន និងមជ្ឈមណ្ឌលបច្ចេកវិទ្យាឌីជីថល ក្នុងគ្រឹះស្ថានសិក្សាដែលមានសក្តានុពល ដើម្បីប្រែក្លាយគ្រឹះស្ថានទាំងនោះ ឱ្យមានកម្រិតស្តង់ដាអន្តរជាតិ និងប្រែក្លាយជាមជ្ឈមណ្ឌលធនធាន សម្រាប់ប្រើប្រាស់រួមគ្នា។

- ផ្សារភ្ជាប់សាកលវិទ្យាល័យជាមួយកម្មវិធីអគារវៃឆ្លាត និងទីក្រុងវៃឆ្លាត៖ រៀបចំកម្មវិធីសិក្សា និងការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីគាំទ្រដល់ការដំណើរការអគារវៃឆ្លាត និងទីក្រុងវៃឆ្លាត ដោយសហការជាមួយក្រុមហ៊ុនក្នុង និងក្រៅប្រទេស។

២.២.២. ការលើកកម្ពស់គុណភាពអប់រំ និងមន្ទីរពិសោធន៍ស្រាវជ្រាវពហុជំនាញ

ទន្ទឹមនេះផងដែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានលើកម្ពស់គុណភាពបង្រៀន និងរៀន នៅគ្រប់កម្រិត ដែលក្នុងនោះ ផ្នែក STEM ត្រូវបានផ្តល់ជាអាទិភាព។ ការអភិវឌ្ឍផ្តោតសំខាន់ៗលើ (១) ការកែលម្អ និងបង្កើតកម្មវិធីសិក្សាទាំងថ្នាក់ជាតិ និងអន្តរជាតិ (២) ការធ្វើទំនើបកម្ម និងបង្កើតមន្ទីរពិសោធន៍ (៣) ការពង្រឹងសមត្ថភាពគ្រូទាំងជំនាញ បច្ចេកទេស និងបំណិនបង្រៀន តាមរយៈការបណ្តុះបណ្តាលទៅកម្រិតបណ្ឌិត និងការបណ្តុះបណ្តាលបែប upskilling និង Reskilling។ ខាងក្រោមជាលទ្ធផលសំខាន់ដែលសម្រេចបាន៖

- កែលម្អ និងបង្កើតកម្មវិធីសិក្សាទាំងកម្រិតបរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត ចំនួន ២៥ ដែលត្រូវបានកែលម្អក្នុងនោះមានកម្មវិធីវិទ្យាសាស្ត្រចំនួន១២ កម្មវិធីសង្គមសាស្ត្រ និងមនុស្សសាស្ត្រចំនួន៨ កម្មវិធីវិស្វកម្មចំនួន៥ និងកម្មវិធីសិក្សាអប់រំចំនួន ៤។ សម្រាប់ខាងវិស្វកម្ម ការកែលម្អកម្មវិធីសិក្សាបានធ្វើតាមក្របខណ្ឌកម្មវិធីសិក្សាវិស្វកម្មបើបទំនើប CDIO ដែលប្រើដោយកម្មវិធីវិស្វកម្មល្បីៗលើពិភពលោក។
- ពង្រឹងសមត្ថភាពគ្រូបង្រៀនទៅកម្រិតបណ្ឌិតបានចំនួន៣៩ នាក់
- ពង្រឹងសមត្ថភាពតាមរយៈupskilling និង reskilling បានចំនួន ៨៣នាក់
- បង្កើតកម្មវិធីសិក្សាអន្តរជាតិតាមរយៈកម្មវិធី ១+៣ និង ២+២ ជាមួយសាកលវិទ្យាល័យ Angelo State University សហរដ្ឋអាមេរិក លើជំនាញវិទ្យាសាស្ត្រ វិស្វកម្ម សង្គមសាស្ត្រ និងមនុស្សសាស្ត្រ និងគ្រប់គ្រងពាណិជ្ជកម្ម និងព្រមទាំងបង្កើតកម្មវិធីសិក្សា ២+២ ជាមួយ Sirindhorn International Institute of Technology នៃសាកលវិទ្យាល័យ Thammasat លើជំនាញវិស្វកម្មប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ និងស្វ័យប្រវត្តិកម្ម (Supply Chain System Engineering and Automation)
- គាំទ្រ និងជំរុញបង្កើតធុរកិច្ច ដោយប្រើប្រាស់បច្ចេកវិទ្យារបស់និស្សិត សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវតាម រយៈការរៀបចំការប្រកួតប្រជែងធុរកិច្ចថ្មីបានរៀបចំចំនួន៤ដង ការបណ្តុះបណ្តាលដើម្បីបង្កើនសមត្ថភាពជំនាញសហគ្រិនភាពដល់និស្សិត បង្កើតព្រឹត្តិការណ៍ដើម្បីជំរុញ និងគាំទ្រធុរកិច្ចថ្មីចំនួន១០ដង បណ្តុះបណ្តាលនិងទស្សនកិច្ចសិក្សាដល់បុគ្គលិកនៃមជ្ឈមណ្ឌល និងថ្នាក់ដឹកនាំ។
- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានបង្កើតមន្ទីរពិសោធន៍ស្រាវជ្រាវពហុជំនាញមួយដែលមានទីតាំង នៅអគារ STEM (ជាន់ផ្ទាល់ដី ដល់ជាន់ទី៥) ដោយបញ្ចូលមន្ទីរពិសោធន៍ស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទាំងអស់ចូលគ្នា ដែលមានប្រព័ន្ធគ្រប់គ្រងរួមគ្នា។ ស.ភ.ភ.ព បានបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវសូត្រខ្មែរ មជ្ឈមណ្ឌលស្រាវជ្រាវអភិរក្សជីវចម្រុះ និងមន្ទីរពិសោធន៍ក្រៅអគារនៅគីរីរម្យ (Outdoor Lab)ខេត្តកំពង់ស្ពឺ។ ដើម្បីគាំទ្រការស្រាវជ្រាវ ស.ភ.ភ.ព បានតបណ្តាញអ៊ីនធឺណែត WIFI នៅក្នុងបរិវេណរបស់ ស.ភ.ភ.ព ១ និង ព្រមទាំង ស.ភ.ភ.ព ២ សម្រាប់ការស្រាវជ្រាវ រៀនសូត្ររបស់គ្រូ និងនិស្សិតដោយឥតគិតថ្លៃ។

២.២.៣. ការពង្រឹង និងពង្រីកសមត្ថភាពស្រាវជ្រាវ

ចំពោះការពង្រឹង និងពង្រីកសមត្ថភាពស្រាវជ្រាវ ស.ក.ក.ព បានសម្រេចនូវសកម្មភាពមួយចំនួនដូចខាងក្រោម៖

- បញ្ជូនបុគ្គលិកទៅបន្តសិក្សាថ្នាក់បណ្ឌិតផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅប្រទេសស៊ុយអែត ចំនួន ១១នាក់
- បំប៉នលោកគ្រូ-អ្នកគ្រូដែលមានសញ្ញាបត្របណ្ឌិតឱ្យមានសមត្ថភាពដឹកនាំនិស្សិតថ្នាក់ក្រោយបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ ចំនួន ១០ នាក់
- ផ្សារភ្ជាប់កិច្ចការស្រាវជ្រាវរបស់និស្សិតគ្រប់កម្មវិធីសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រទាំងអស់
- ផ្សារភ្ជាប់គម្រោងស្រាវជ្រាវជាមួយឧស្សាហកម្ម បានចំនួន ១១ គម្រោង និង
- ការច្នៃបង្កើត ផលិតផលគំរូ ចំនួន ៦ សំខាន់ៗ និងព្រមទាំងផលិតផលផ្សេងៗមួយចំនួនធំផ្សេងទៀត។

២.២.៤. ការផ្តោតលើការពង្រឹងប្រសិទ្ធភាពនៃការបង្រៀន និងរៀន

សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានផ្តោតលើការពង្រឹងប្រសិទ្ធភាពនៃការបង្រៀន និងរៀនតាមរយៈ៖

- បង្កើនចំនួនគ្រូបង្រៀនថ្នាក់បណ្ឌិត លើជំនាញអាទិភាពដែលស្របទៅតាមតម្រូវការជាតិ និងពង្រឹងគុណភាពគ្រូបង្រៀនឱ្យមានឋានៈសាស្ត្រាចារ្យ សាស្ត្រាចារ្យ និងសាស្ត្រាចារ្យជំនួយ។ ក្រសួងអប់រំបាននឹងកំពុងវិនិយោគទៅលើការបង្កើនគុណវុឌ្ឍិថ្នាក់បណ្ឌិតសម្រាប់គ្រូបង្រៀននៅតាមគ្រឹះស្ថានឧត្តមសិក្សាតាមរយៈការគាំទ្រគម្រោងស្រាវជ្រាវ (HEIP1 និង HEIP2) ជាដើមដែលជាការផ្តល់អាហារូបករណ៍ និងតាមរយៈកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា។
- អនុវត្តវិធីសាស្ត្របង្រៀនទំនើប ដើម្បីលើកកម្ពស់បំណិនសតវត្សទី២១ ជាមួយប្រព័ន្ធនៃការសិក្សាតាមបែបចម្រុះ (Blended Learning) ឬ ដែលផ្សារភ្ជាប់ជាមួយប្រព័ន្ធគ្រប់គ្រងការសិក្សា (Learning Management System)។
- រៀបចំដំរុញការបង្រៀនតាមបែបសិក្សាគម្រោង (អនុវត្តផ្ទាល់ក្នុងមន្ទីរពិសោធន៍ កសិដ្ឋាន ឬជាក្រុម) និងលើកកម្ពស់ការបង្រៀនភាសាបរទេស បំណិនសហគ្រិនភាព បំណិនបច្ចេកវិទ្យា និងបំណិនឌីជីថល។
- រៀបចំយន្តការដំរុញការសិក្សាគម្រោង ការស្រាវជ្រាវ ពិសោធន៍ ចុះកម្មសិក្សា និងការចល័តនិស្សិតជាមួយសាកលវិទ្យាល័យអន្តរជាតិ ស្ថាប័នដៃគូ និងសហគ្រាសឯកជន និងឧស្សាហកម្ម
- រៀបចំយន្តការការបង្កើតក្លឹបសិក្សា និងស្វ័យសិក្សា និងការជួយនិស្សិតរៀនយឺត។

២.២.៥. ការផ្តោតលើការបង្កើនចំនួននិស្សិតចូលរៀននិងបរិយាបន្ន

សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានផ្តោតលើលើការបង្កើនចំនួននិស្សិតចូលរៀននិងបរិយាបន្នតាមរយៈ៖

- ពង្រីកការអនុវត្តកម្មវិធីភាពជាដៃគូការអប់រំស្ពានតាមេយៈគំរូភាពជាដៃគូរវាងមធ្យមសិក្សា និងឧត្តមសិក្សា ដើម្បីលើកកម្ពស់សមត្ថភាពសិស្សានុសិស្ស និងលទ្ធភាពបន្តការសិក្សានៅឧត្តមសិក្សា។
- ពង្រីកការអនុវត្តគោលនយោបាយអាហារូបករណ៍ សម្រាប់និស្សិតក្រីក្រ មកពីជនបទ និងពិការភាព ជាពិសេសការអនុវត្តមូលនិធិសមធម៌ ជាមួយសហគមន៍និងវិស័យឯកជនឱ្យបានកាន់តែទូលំទូលាយ ដើម្បីគាំទ្រឱកាសសម្រាប់និស្សិតចូលរៀននៅកម្រិតឧត្តមសិក្សា។

២.២.៥. ការងារបន្ទាប់ពីបញ្ចប់ការសិក្សា

សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានរៀបចំបញ្ជីគ្រប់គ្រងទិន្នន័យនិស្សិតដែលទទួលបានការងារបន្ទាប់ពីបញ្ចប់ការសិក្សាៈ

- ក្នុងរយៈពេល១ឆ្នាំក្រោយបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និស្សិតមានការងារធ្វើចន្លោះពី៧៣% ទៅដល់៨២% និងនិស្សិតចន្លោះពី៥៥%ទៅ៧០% ប្រើពេលតិចជាង៥ខែក្នុងការស្វែងរកការងារធ្វើ។ ជាមធ្យមនិស្សិតទទួលបានប្រាក់បៀវត្សរ៍ចាប់ពីចន្លោះ ៣៥០ដុល្លារដល់៤៥០ដុល្លារ។
- វិនិយោគបន្ថែមលើកម្មវិធីពង្រឹងសមត្ថភាពមន្ត្រីដឹកនាំ គ្រប់គ្រង និងជំនាញ ដោយដំរុញការសិក្សាលើជំនាញពាក់ព័ន្ធនឹងការងារ ទាំងរយៈពេលខ្លី និងវែង (reskilling & upskilling)។
- អនុវត្តប្រព័ន្ធវាយតម្លៃការអនុវត្តការងារផ្អែកលើសមិទ្ធកម្ម។

២.៣. ស្រាវជ្រាវវិទ្យាសាស្ត្រ ឧទ្ទាមភណ្ឌ និងការប្រើប្រាស់លទ្ធផលស្រាវជ្រាវ

ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ សាកលវិទ្យាល័យភូមិន្ទភ្នំពេញបាន ពង្រឹងសមត្ថភាព និងពង្រីកវិសាលភាពវិស័យស្រាវជ្រាវរបស់ខ្លួនយ៉ាងសកម្មដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យក្នុងឆ្នាំ២០៣០ និង ២០៥០ របស់រាជរដ្ឋាភិបាលកម្ពុជា។ ការអភិវឌ្ឍនេះបានផ្តោតសំខាន់លើ ៥ផ្នែកគឺ (១) ការពង្រឹង និងពង្រីកសមត្ថភាពស្រាវជ្រាវ (២) ប្រព័ន្ធគាំទ្រកិច្ចការស្រាវជ្រាវ និងថវិកាស្រាវជ្រាវ(៣) ហេដ្ឋារចនាសម្ព័ន្ធ (មន្ទីរពិសោធន៍ក្នុងអគារនិងក្រៅអគារ និងបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ) (៤) បោះពុម្ពផ្សាយកិច្ចការស្រាវជ្រាវ និងបង្កើតផលិតផលគំរូ និង (៥) ពង្រឹងភាពជាដៃគូស្រាវជ្រាវ និងដៃគូអភិវឌ្ឍន៍។

២.៣.១. ការវាយតម្លៃស្នាដៃស្រាវជ្រាវដើម្បីផ្តល់ឋានៈសាស្ត្រាចារ្យ

នៅថ្ងៃទី ២០ កក្កដា ២០២៣ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានប្រទានឋានៈ «សាស្ត្រាចារ្យ» ដល់បុគ្គលិកអប់រំ សាកលវិទ្យាល័យភូមិន្ទភ្នំពេញចំនួន១៧ រូប និង ប្រទានឋានៈ «សាស្ត្រាចារ្យរង» និង «សាស្ត្រាចារ្យជំនួយ» មួយចំនួនទៀត។

២.៣.២. ប្រព័ន្ធគាំទ្រកិច្ចការស្រាវជ្រាវ និងថវិកាស្រាវជ្រាវ

- បានបង្កើតក្របខណ្ឌគោលនយោបាយនៃការគ្រប់គ្រងការស្រាវជ្រាវរបស់ ស.ភ.ភ.ព
- បង្កើតក្របខណ្ឌអនុវត្តន៍ការគ្រប់គ្រងការស្រាវជ្រាវ
- បង្កើតមូលនិធិស្រាវជ្រាវរបស់ ស.ភ.ភ.ព និងប្រព័ន្ធលើកទឹកចិត្តដល់កិច្ចការស្រាវជ្រាវ។

២.៣.៣. គម្រោងវិនិយោគ ដើម្បីលើកកម្ពស់កិច្ចការស្រាវជ្រាវរបស់ ស.ភ.ភ.ព ២០១៨-២០២៦

សាកលវិទ្យាល័យមានគម្រោងវិនិយោគសម្រាប់កិច្ចការស្រាវជ្រាវរបស់ស.ភ.ភ.ព ២០១៨-២០២៦ (បង្ហាញក្នុងតារាងទី៣) និងរួមទាំងគម្រោងស្រាវជ្រាវដែលទទួលបានពីដៃគូស្រាវជ្រាវ និងដៃគូអភិវឌ្ឍន៍ (បង្ហាញក្នុងតារាងទី៤)។

តារាងទី៣.គម្រោងវិនិយោគ សម្រាប់កិច្ចការស្រាវជ្រាវរបស់ ស.ភ.ភ.ព ២០១៨-២០២៦

១. គម្រោងវិនិយោគ (២០១៨-២០២៤)	ចំនួនថវិកា (USD)	ចំនួនគម្រោង
1. គម្រោងកែលម្អការអប់រំឧត្តមសិក្សា (HEIP-RUPP ២០១៨-២០២៤)	3,324,372.31	14
2. គម្រោងទ្វេភាគីរវាងប្រទេសស៊ុយអែត និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (២០១៩-២០២២)	10,000,000.00	28
3. គម្រោងស្រាវជ្រាវជាមួយដៃគូថ្នាក់ជាតិ	387,000.00	49
4. គម្រោងស្រាវជ្រាវជាមួយដៃគូថ្នាក់អន្តរជាតិ	895,132.00	12
សរុប	14,606,504.31	162

២. គម្រោងកែលម្អការអប់រំឧត្តមសិក្សា (HEIP-RUPP ២០២៥-២០២៩)	ចំនួនថវិកា (USD)	ចំនួនគម្រោង
២.១. គម្រោងកែលម្អការអប់រំឧត្តមសិក្សា (HEIP-RUPP ២០២៥-២០២៩)		
Project 1. Development of Portable Biosensors (Glucose, Iodine, and Uric acid) for Healthcare: Scale-Up to a Pilot Plant Stage.	941,810.00	1
Project 2. Innovative solution for improving the quality of drinking water and community water supply in the highland areas of Cambodia.	50,040.00	1
Project 3. Beverage- from Kampot Pepper Inflorescence and its Nutritional Profiling	50,000.00	1
Project 4. Building Urban Climate Resilience among urban flood prone areas in Phnom Penh	20,000.00	1
សរុប	1,061,850.00	
២.២. គម្រោងវិនិយោគ (២០២៥-២០២៦)	ចំនួនថវិកា (USD)	ចំនួនគម្រោង
1. គម្រោងវិនិយោគរបស់ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ 2026	750,000.00	1
2. គម្រោងកែលម្អការអប់រំឧត្តមសិក្សា (HEIP-RUPP ២០១៨-២០២៤)	18,000,000.00	1
3. គម្រោងកែលម្អការអប់រំឧត្តមសិក្សា (HEIP-RUPP ២០២៥-២០២៩)	10,000,000.00	1

4. រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ ស.ភ.ភ.ព មណ្ឌលទី៣ (២០២៤-២០២៦)	25,000,000.00	1
5. គម្រោងស្រាវជ្រាវជាមួយដៃគូថ្នាក់អន្តរជាតិ (២០២៥-២០២៦)	660,225.52	57
សរុប	54,410,225.52	

តារាងទី៤. ដៃគូស្រាវជ្រាវ និងដៃគូអភិវឌ្ឍន៍

ដៃគូស្រាវជ្រាវ និងដៃគូអភិវឌ្ឍន៍	ឆ្នាំ
1. គម្រោងស្រាវជ្រាវ និងអភិវឌ្ឍន៍របស់ International Science Program នៃសាកលវិទ្យាល័យ Uppsala នៃប្រទេសស៊ុយអែត	២០០៨-២០២៤
2. គម្រោងស្រាវជ្រាវ និងអភិវឌ្ឍន៍របស់ ប្រទេសស៊ុយអែត (Sweden-RUPP Bilaterial Program)	២០១៩-២០២៤
3. គម្រោងស្រាវជ្រាវ និងអភិវឌ្ឍន៍របស់សាកលវិទ្យាល័យ Sogang នៃប្រទេសកូរ៉េ ខាងត្បូង	២០០៩-២០១៨
4. គម្រោងការកែកម្ពការអប់រំឧត្តមសិក្សា (HEIP) របស់ រាជរដ្ឋាភិបាលកម្ពុជា	២០១៩-២០២៤
5. គម្រោងស្រាវជ្រាវ និងអភិវឌ្ឍន៍របស់សហគមន៍អឺរ៉ុប	
6. គម្រោងស្រាវជ្រាវ និងអភិវឌ្ឍន៍របស់ IAEA លើវិស័យអប់រំ ផ្នែកនុយក្លេអ៊ែរ	២០២២-២០២៣
7. គម្រោងស្រាវជ្រាវ និងអភិវឌ្ឍន៍ស្ថាប័នរដ្ឋ	
8. គម្រោងស្រាវជ្រាវ និងអភិវឌ្ឍន៍ស្ថាប័នអង្គារក្រៅរដ្ឋាភិបាល	
សរុប	៨គម្រោង

២.៣.៤. ក្របខណ្ឌគោលនយោបាយនៃការគ្រប់គ្រងការស្រាវជ្រាវ

សាកលវិទ្យាល័យភូមិន្ទក្នពេញបាន នឹងកំពុងរៀបចំនូវក្របខណ្ឌគោលនយោបាយនៃការគ្រប់គ្រងការស្រាវជ្រាវសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- លើកកម្ពស់ការងារស្រាវជ្រាវតាមរយៈដំណើរការគណៈកម្មការ/អនុគណៈកម្មការ
- អនុគណៈកម្មការក្រមសីលធ៌មស្រាវជ្រាវ
- អនុគណៈកម្មការប្រឹក្សាយោបល់
- អនុគណៈកម្មការគ្រប់គ្រងការបោះពុម្ពអត្ថបទស្រាជ្រាវ
- អភិវឌ្ឍសមត្ថភាពនិងនិន្នភាពហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ
- គោលការលើកទឹកចិត្តស្រាវជ្រាវតាមវិធីច្នៃប្រឌិត
- បោះពុម្ពផ្សាយនិងការផ្សព្វផ្សាយស្នាដៃស្រាវជ្រាវតាមរយៈទស្សនាវដ្តីវិទ្យាសាស្ត្រ
- ការបង្កើតផលិតផលថ្មី (ផលិតផលគំរូ)
- ការបង្កើតផលិតផលថ្មី (ប៉ាតង់)

- ចំណូលដែលទទួលបានពីការស្រាវជ្រាវ (ផលិតផលគំរូ ឬប៉ាតង់)។

២.៣.៥. ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា

សាកលវិទ្យាល័យភូមិន្ទភ្នំពេញបាន នឹងកំពុងរៀបចំការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សាសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- រៀបចំបង្កើតមជ្ឈមណ្ឌលឧត្តមភាពកម្រិតគ្រឹះស្ថាន និងកម្រិតកម្មវិធីនៅតាមគ្រឹះស្ថានឧត្តមសិក្សាដែលមានសក្តានុពល ស្របតាមបរិបទនៃឧស្សាហកម្មឌីជីថល ៤.០ ដោយកែលម្អហេដ្ឋារចនាសម្ព័ន្ធ រួមមាន អគារសិក្សា អន្តេវាសិកដ្ឋាន មន្ទីរពិសោធន៍ កសិដ្ឋាន និងមជ្ឈមណ្ឌលបច្ចេកវិទ្យាឌីជីថល ដើម្បីប្រែក្លាយជាគ្រឹះស្ថានឧត្តមសិក្សាឈានមុខ និងអាចទទួលបានស្គាល់ជាតំបន់ និងអន្តរជាតិ។
- ពង្រឹងតួនាទីយុទ្ធសាស្ត្ររបស់គ្រឹះស្ថានឧត្តមសិក្សាដោយជំរុញវប្បធម៌កសាងឧត្តមភាព ដូចជាការជ្រើសរើសនិងរក្សាទុកអ្នកមានសមត្ថភាពខ្ពស់ ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍ ការចែករំលែកលទ្ធផលស្រាវជ្រាវ និងចំណេះដឹងថ្មីៗ ដើម្បីជំរុញការចូលរួមសហការ អន្តរអង្គភាព។

២.៣.៦. ការពង្រឹងប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវនៅក្នុងគ្រឹះស្ថានឧត្តមសិក្សា

សាកលវិទ្យាល័យភូមិន្ទភ្នំពេញបាន នឹងកំពុងការពង្រឹងប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ជំរុញសកម្មភាពស្រាវជ្រាវ និងនវានុវត្តន៍នៅតាមគ្រឹះស្ថានឧត្តមសិក្សា ដោយរៀបចំផ្តល់មូលនិធិសម្រាប់គម្រោងស្រាវជ្រាវ និងគោលការណ៍ឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការងារស្រាវជ្រាវរបស់និស្សិត (ឧទាហរណ៍៖ សារណាបទសម្រាប់ថ្នាក់បរិញ្ញបត្រ និងនិក្ខេបបទសម្រាប់បរិញ្ញបត្រជាន់ខ្ពស់) និងកសាងថ្នាលបណ្តុះបណ្តាលដល់អ្នកស្រាវជ្រាវវ័យក្មេង និងអ្នកស្រាវជ្រាវអាជីពឱ្យមានសមត្ថភាពក្នុងការបោះពុម្ពអត្ថបទស្រាវជ្រាវក្នុងទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រ កម្រិតជាតិនិងអន្តរជាតិ។
- កសាងបណ្តាញអ្នកស្រាវជ្រាវ ឬសហការគ្នាក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សា ដោយមានកិច្ចសហការពីវិស័យឯកជនដើម្បីស្រាវជ្រាវលើប្រធានបទចាស់លាស់ និងអភិវឌ្ឍន៍វានុវត្តន៍សម្រាប់ផ្សារភ្ជាប់ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារដែលជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។
- ជំរុញការបង្កើតទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រ តាមជំនាញ ឬឯកទេស ដើម្បីផ្សព្វផ្សាយលទ្ធផលដែលទទួលបានពីការស្រាវជ្រាវ ដល់ភាគីពាក់ព័ន្ធ។
- អភិវឌ្ឍ និងលើកកម្ពស់ស្តង់ដាទស្សនាវដ្តីស្រាវជ្រាវរបស់ក្រសួង និងគ្រឹះស្ថានឧត្តមសិក្សាដែលមានសក្តានុពល ដើម្បីឈានទៅទទួលបានការទទួលស្គាល់តាមស្តង់ដាអាស៊ាន និងអន្តរជាតិ។
- ជំរុញការប្រើប្រាស់យន្តការការចុះជួយណែនាំ (Mentoring) ដើម្បីលើកកម្ពស់សមត្ថភាពស្រាវជ្រាវរបស់គ្រឹះស្ថានឧត្តមសិក្សាតាមរយៈការអនុវត្តនូវក្របខណ្ឌការគ្រប់គ្រងលើការស្រាវជ្រាវ(Research Management)។
- ជំរុញការផ្សព្វផ្សាយស្នាដៃស្រាវជ្រាវ តាមរយៈការរៀបចំវេទិកានានា ដើម្បីចែករំលែកឧត្តមានុវត្តន៍បទពិសោធន៍ និងលទ្ធផលស្រាវជ្រាវ។

- ជំរុញការបង្កើតមជ្ឈមណ្ឌលឧត្តមភាព ទាំងនៅគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជន (គ្រឹះស្ថានមួយមានមជ្ឈមណ្ឌលឧត្តមភាពយ៉ាងតិចមួយ)។
- ពង្រឹងយន្តការអនុវត្តប្រព័ន្ធលើកទឹកចិត្តដល់អ្នកស្រាវជ្រាវ តាមរយៈការផ្តល់ហានៈដល់សាស្ត្រាចារ្យ ការទទួលស្គាល់លទ្ធផលស្រាវជ្រាវ និងការវាយតម្លៃការងារផ្អែកលើស្នាដៃស្រាវជ្រាវ។
- បង្កើតសមាគមវិទ្យាសាស្ត្រវិជ្ជាជីវៈ (Professional Scientific Society) ដើម្បីផ្តល់ឱកាសដល់អ្នកសិក្សាស្រាវជ្រាវ និស្សិត និងអ្នកឯកទេស ឬអ្នកជំនាញដែលមានជំនាញដូចគ្នា ឬប្រហាក់ប្រហែលគ្នា អាចចងក្រងជាសហគមន៍សិក្សា និងវិជ្ជាជីវៈ សម្រាប់ចែករំលែកបទពិសោធន៍ និងឧត្តមានុវត្តន៍ តាមរយៈការរៀបចំសិក្ខាសាលា សន្និសីទប្រចាំឆ្នាំ វគ្គបណ្តុះបណ្តាល ការបោះពុម្ពសៀវភៅ និងអត្ថបទបច្ចេកទេស។
- ជំរុញការបង្កើតភាពជាដៃគូ រវាងសាកលវិទ្យាល័យ និងសាកលវិទ្យាល័យ(Consortium Universities) សាកលវិទ្យាល័យ និងបណ្តាញក្រុមហ៊ុនឧស្សាហកម្មឯកជន (University-Industry Linkage) សាកលវិទ្យាល័យ និងសហគមន៍ (University-Community Partnership) ដើម្បីអនុវត្តគម្រោងស្រាវជ្រាវលើប្រធានបទសំខាន់ៗ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់សង្គមជាតិ ក្រុមហ៊ុនឧស្សាហកម្ម និងសហគមន៍ផងដែរ។
- លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិតក្នុងចំណោមសាស្ត្រាចារ្យ អ្នកស្រាវជ្រាវ គ្រូបង្រៀន និងនិស្សិត ដើម្បីរួមចំណែកពង្រឹងគុណភាពការងារស្រាវជ្រាវ តាមរយៈវេទិកាចែករំលែកចំណេះដឹង ទាំងតាមប្រព័ន្ធអនឡាញ និងដោយផ្ទាល់។

២.៣.៧. ប្រព័ន្ធគាំទ្រកិច្ចការស្រាវជ្រាវ និងថវិកាស្រាវជ្រាវ

សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានបង្កើតប្រព័ន្ធគាំទ្រកិច្ចការស្រាវជ្រាវ និងថវិកាស្រាវជ្រាវសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- បានបង្កើតក្របខណ្ឌគោលនយោបាយ និងក្របខណ្ឌអនុវត្តការគ្រប់គ្រងការស្រាវជ្រាវរបស់ ស.ភ.ភ.ព
- បង្កើតមូលនិធីស្រាវជ្រាវរបស់ ស.ភ.ភ.ព និងប្រព័ន្ធលើកទឹកចិត្តកិច្ចការស្រាវជ្រាវ។

២.៣.៨. ការបោះពុម្ព និងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ

ស.ភ.ភ.ព. ជាសាកលវិទ្យាល័យដែលឈានមុខគេ និងចូលរួមយ៉ាងសកម្មក្នុងការការបោះពុម្ពអត្ថបទស្រាជ្រាវ និងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ តាមរយៈធ្វើការស្រាវជ្រាវ បោះពុម្ពផ្សាយ និងដំណើការទស្សនាវដ្តីវិទ្យាសាស្ត្រកម្រិតជាតិ តំបន់ និងអន្តរជាតិ។ ស.ភ.ភ.ព. កំពុងដំណើការនូវទស្សនាវដ្តីវិទ្យាសាស្ត្រចំនួនបី៖

1. Cambodia Journal of Basic and Applied Research (CJBAR) (បង្កើតឆ្នាំ ២០១៨)
2. Cambodia Journal of Natural History (CJNH) (បង្កើតឆ្នាំ ២០០៨)
3. Cambodian Journal of Education, Management, and Development (CJEMD) (បង្កើតឆ្នាំ ២០២៥)

ក្នុងនោះផងដែរ ស.ភ.ភ.ព បានដំណើរការទស្សនាវដ្តីវិទ្យាសាស្ត្រ ចំនួន ២គឺ Cambodian Journal of Natural History ដែលទទួលបាន ACI (Asian Citation Index) និង Cambodia Journal of Basic and Applied Research ដែលមានលេខកំណត់អត្តសញ្ញាណអត្ថបទស្រាវជ្រាវ (DOI) តាមស្តង់ដាត្រឹមត្រូវ។ ខាង

ក្រោមគឺជារូបគម្របនៃទស្សនាវដ្តីវិទ្យាសាស្ត្រទាំង២។ ទស្សនាវដ្តីវិទ្យាសាស្ត្រនៅ ស.ក.ក.ព. មាន Index (បិលិក្រម) កម្រិតតំបន់ និងអន្តរជាតិដូចជា៖ CABI, AGRIS, J-Gate, EuroPub database, ASEAN citation Index, Exaly, Scilit, Semantic scholar, Crossref, Scholar9, និង Google Scholar។

- គិតត្រឹមឆ្នាំ 2026៖ Cambodia Journal of Natural History (CJNH) បោះពុម្ពផ្សាយចំនួន២ Issues ក្នុងមួយឆ្នាំ ហើយបោះពុម្ពបានចំនួន ៣៦៦ អត្ថបទ ដែលមានអ្នកនិពន្ធចំនួន ១,១២៩នាក់។
- គិតត្រឹមឆ្នាំ 2026៖ Cambodia Journal of Basic and Applied Research (CJBAR) បោះពុម្ពផ្សាយចំនួន ២ Issues ក្នុងមួយឆ្នាំ ហើយបោះពុម្ពបានចំនួន ១២៨ អត្ថបទ។

មិនតែប៉ុណ្ណោះបុគ្គលិកអប់រំស.ក.ក.ព បានបោះពុម្ពស្នាដៃស្រាវជ្រាវក្នុងប្រទេស និងអន្តរជាតិនៅក្រៅប្រទេសក្នុងចន្លោះឆ្នាំ២០១៨-២០២៦ ដូចជា៖

- បោះពុម្ពស្នាដៃស្រាវជ្រាវក្នុងប្រទេសបានចំនួន ២១២ អត្ថបទ (ឆ្នាំ២០១៨-២០២៦)
- បោះពុម្ពកម្រិតអន្តរជាតិនៅក្រៅប្រទេសបានចំនួន ៦៥៧ អត្ថបទ (ឆ្នាំ២០០១-២០២៦)។

២.៤. អន្តរជាតូបនីយកម្ម និងសមាហរណកម្មតំបន់

សាកលវិទ្យាល័យកូមិន្នក្នពេញបានផ្តោតទៅលើអន្តរជាតូបនីយកម្ម និងសមាហរណកម្មតំបន់៖

- **ភាពជាដៃគូអន្តរជាតិ៖** បច្ចុប្បន្ន ស.ក.ក.ព បានបង្កើតកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ និងស្ថាប័ននានាទាំងក្នុងនិងក្រៅប្រទេសចំនួន ២១៦ តាមរយៈអនុស្សរណៈនៃការយោគយល់គ្នា (MoU)។ លើសពីនេះ ស.ក.ក.ព គឺជាសមាជិកនៃបណ្តាញ និងកម្មវិធីជាង ១០ ដែលតភ្ជាប់ស្ថាប័ននេះទៅនឹងសាកលវិទ្យាល័យរាប់រយនៅជុំវិញពិភពលោក។
- **ការចល័តនិស្សិត៖** ក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះ សាកលវិទ្យាល័យកូមិន្នក្នំពេញ បានទទួលស្វាគមន៍និស្សិតអន្តរជាតិចំនួន ៩៥៩ នាក់ និងបានបញ្ជូននិស្សិតចំនួន ៤៤៦ នាក់ទៅសិក្សានៅបរទេស ដែលការចល័តនិស្សិតនេះធ្វើឡើងតាមរយៈកម្មវិធីផ្លាស់ប្តូរនិស្សិត កម្មវិធីហាត់ការ កម្មវិធីសិក្សានៅរដូវក្តៅ (Summer Camp) និងឱកាសអាហារូបករណ៍ផ្សេងៗ។
- **ការចល័តបុគ្គលិក និងសាស្ត្រាចារ្យ៖** ក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះ ស.ក.ក.ព បានទទួលស្វាគមន៍បុគ្គលិក និងសាស្ត្រាចារ្យចំនួន ៣៤៥ នាក់ ខណៈដែលបានបញ្ជូនបុគ្គលិក និងសាស្ត្រាចារ្យចំនួន ១១០៥ នាក់ចេញទៅក្រៅប្រទេស ការចល័តនេះធ្វើឡើងតាមរយៈ ការផ្លាស់ប្តូរការបង្រៀន ការដឹកនាំនិស្សិតសរសេរសារណា/និក្ខេបបទរួមគ្នា (joint/co-supervision) ចូលរួមវគ្គបណ្តុះបណ្តាល សន្និសីទអន្តរជាតិ កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្លាស់ប្តូរផ្នែកសិក្សាធិការ។ និងរួមទាំងលើកកម្ពស់ការផ្លាស់ប្តូរគ្រូបង្រៀន អ្នកស្រាវជ្រាវ និងនិស្សិត រវាងសាកលវិទ្យាល័យនៅកម្ពុជា និងសាកលវិទ្យាល័យដៃគូអន្តរជាតិ។
- **ការស្រាវជ្រាវអន្តរជាតិ៖** ក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះ ស.ក.ក.ព បានចូលរួមក្នុងបណ្តាញស្រាវជ្រាវអន្តរជាតិ និងចូលរួមផលិតឯកសារបោះពុម្ពផ្សាយរួមគ្នា បានផ្តួចផ្តើមគម្រោងស្រាវជ្រាវ និងទទួលបានជំនួយហិរញ្ញវត្ថុសម្រាប់ការស្រាវជ្រាវពីអន្តរជាតិផងដែរ។ និងជំរុញការអនុវត្តគម្រោងស្រាវជ្រាវរួមគ្នា ជាមួយសាកលវិទ្យាល័យក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងប្រទេសដៃគូអន្តរជាតិ។

- **កម្មវិធីសិក្សាអន្តរជាតិ៖** ស.ភ.ភ.ព ផ្តល់ជូននូវកម្មវិធីសិក្សាចំនួន ៤០ ដែលបង្រៀនជាភាសាអង់គ្លេស ចាប់ពីកម្រិតថ្នាក់បរិញ្ញាបត្រហូតដល់កម្រិតថ្នាក់ក្រោយបរិញ្ញាបត្រ។ បង្កើត និងអនុវត្តកម្មវិធីសិក្សាអន្តរជាតិ (International Academic Programs) រួមមាន កម្មវិធីសិក្សាទ្វេ ឬកម្មវិធីសិក្សារួមគ្នា (Joint-Degree Program) ជាពិសេសសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត តាមរយៈការសហការជាមួយសាកលវិទ្យាល័យ និងក្រុមហ៊ុនឧស្សាហកម្មដៃគូទាំងនៅក្នុងនិងក្រៅប្រទេស។
- រៀបចំគាំទ្រផ្នែកហិរញ្ញវត្ថុដល់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីអញ្ជើញសាស្ត្រាចារ្យ និងអ្នកជំនាញពីបរទេសមកជួយបង្រៀនមុខវិជ្ជាថ្មីៗ ឆ្ពោះទៅការពង្រឹងគុណភាពការសិក្សា ជាពិសេសនៅថ្នាក់ក្រោយបរិញ្ញាបត្រ។
- លើសពីនេះទៅទៀត ស.ភ.ភ.ព លើកកម្ពស់ការធ្វើអន្តរជាតូបនីយកម្មនៅក្នុងបរិវេណសាលាផ្ទាល់តាមរយៈការផ្តល់ជូននូវវគ្គសិក្សាកម្រិតអន្តរជាតិ ការអញ្ជើញវាគ្មិនល្បីៗពីបរទេសមកបង្រៀន ការបង្រៀនអនឡាញពីដៃគូក្រៅប្រទេស សកម្មភាពផ្លាស់ប្តូរវប្បធម៌ និងគម្រោងសហប្រតិបត្តិការនានា ដើម្បីធានាថាទាំងនិស្សិត និងបុគ្គលិកសិក្សាដែលមិនអាចធ្វើដំណើរទៅក្រៅប្រទេសបាន នៅតែទទួលបានបទពិសោធន៍ និងចំណេះដឹងក្នុងបរិបទអន្តរជាតិ។

៣. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផលគួរឱ្យកត់សម្គាល់ទាំងនេះ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស.ភ.ភ.) នៅតែប្រឈមនឹងបញ្ហាមួយចំនួន ដូចខាងក្រោម៖

- កំណើននិស្សិតកើនឡើងខ្ពស់ធៀបនឹងហេដ្ឋារចនាសម្ព័ន្ធ អាគារ និងបន្ទប់សិក្សា សោភណ្ឌភាពនៅមានកម្រិត
- ការគ្រប់គ្រង់ទិន្នន័យដូចជា៖ កម្មវិធីសិក្សា បុគ្គលិក និស្សិត សម្ភារៈរូបវន្តមិនទាន់រលូននៅឡើយ
- មហាវិទ្យាល័យ និងដេប៉ាតឺម៉ង់ភាគច្រើនមិនទាន់បានរៀបចំរបាយការណ៍ស្វ័យវាយតម្លៃបុគ្គលិករបស់ខ្លួនឱ្យបានត្រឹមត្រូវ
- មហាវិទ្យាល័យ និងដេប៉ាតឺម៉ង់មិនទាន់មានផែនការសកម្មភាពកែលម្អគុណភាពកម្មវិធីសិក្សាច្បាស់លាស់
- ការគ្រប់គ្រងដំណើរការប្រតិបត្តិតាមប្រព័ន្ធឌីជីថលនៅមានកម្រិតសម្រាប់និស្សិត និងបុគ្គលិក
- ការិយាល័យធានាគុណភាពមិនទាន់មានប្រព័ន្ធឌីជីថលគ្រប់គ្រងកិច្ចការធានាគុណភាព
- ការិយាល័យនិងដេប៉ាតឺម៉ង់ពាក់ព័ន្ធមិនទាន់មានយន្តការវាយតម្លៃលើប្រសិទ្ធភាពការងារប្រចាំឆ្នាំ
- គ្រឹះស្ថានមិនទាន់មានគោលនយោបាយលើកទឹកចិត្តច្បាស់លាស់សម្រាប់បុគ្គលិកបំពេញការងារល្អ
- ថវិកាគាំទ្រកិច្ចការស្រាវជ្រាវ និងអ្នកស្រាវជ្រាវនៅមានកម្រិត ជាពិសេសថវិកាស្រាវជ្រាវទៀងទាត់នៅថ្នាក់ជាតិ
- មិនទាន់មានប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវ ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើគម្រោងស្រាវជ្រាវបានដោយរលូននៅឡើយ
- អ្នកស្រាវជ្រាវនៅបែកខ្ញែក និងចាប់អារម្មណ៍លើការបង្រៀនជាងការស្រាវជ្រាវ

- មន្ទីរពិសោធន៍នៅមានកម្រិត និងត្រូវការបំពាក់ឧបការណ៍ទំនើបៗសម្រាប់ស្រាវជ្រាវឱ្យស្របតាមតម្រូវការរបស់ជាតិ និងសង្គម។

៤. ទិសដៅ និងផែនការសកម្មភាព

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស.ភ.ភ.) មានទិសដៅសម្រាប់ជាផែនការសកម្មភាពដែលត្រូវអនុវត្តមួយចំនួនដូចខាងក្រោម៖

- កែលម្អ និងពង្រឹងប្រសិទ្ធភាពការអនុវត្តប្រព័ន្ធធានាគុណភាពផ្ទៃក្នុង ប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវ ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ប្រព័ន្ធអភិបាលកិច្ច ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងប្រព័ន្ធគ្រប់គ្រងការងារនិស្សិត ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។
- កែលម្អ និងបន្តអនុវត្តការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា ដើម្បីផ្តល់ការទទួលស្គាល់គុណភាពអប់រំ។
- ផ្តល់ការគាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សា ក្នុងការកសាងផែនការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងការរៀបចំផែនទីបង្ហាញផ្លូវ សម្រាប់រយៈពេល១០ឆ្នាំ ដើម្បីផលិតនូវមូលធនមនុស្សស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី១។
- ពង្រឹងគណនេយ្យភាព និងបន្តផ្តល់ស្វ័យភាពបន្ថែមដល់គ្រឹះស្ថានឧត្តមសិក្សា ក្នុងការគ្រប់គ្រងអង្គភាព រួមមានកិច្ចការទូទៅ ការងារធនធានមនុស្ស ការងារសិក្សាធិការ និងការងារហិរញ្ញវត្ថុ ជាអាទិ៍។
- រៀបចំយន្តការបញ្ចូលក្នុងក្របខ័ណ្ឌ និងរក្សាទុកបុគ្គលមានសមត្ថភាព ទេពកោសល្យ និងសញ្ញាបត្រថ្នាក់បណ្ឌិត រួមទាំងការបង្កើតកម្មវិធីថ្នាក់ក្រោយបណ្ឌិត (Post-Doctoral Fellowship) ដើម្បីបម្រើការនៅតាមគ្រឹះស្ថានឧត្តមសិក្សា។
- បន្តអនុវត្តការវាយតម្លៃកិច្ចការធានាគុណភាពផ្ទៃក្នុងរបស់ភាគីពាក់ព័ន្ធឱ្យបានពេញលេញ
- រៀបចំឧបករណ៍ប្រមូលនិងគ្រប់គ្រងទិន្នន័យទាក់ទងកិច្ចការធានាគុណភាពផ្ទៃក្នុងទៀងទាត់និងមានប្រសិទ្ធភាព
- ជំរុញការប្រើប្រាស់ឧបករណ៍ស្វ័យវាយតម្លៃសម្រាប់គណៈកម្មការធានាគុណភាពផ្ទៃក្នុង
- រៀបចំអនុវត្តយន្តការត្រួតពិនិត្យ និងវាយតម្លៃទទួលស្គាល់គុណភាពផ្ទៃក្នុងពេញលេញ
- បន្តផ្សព្វផ្សាយនីតិវិធីតវ៉ា (មតិត្រឡប់) របស់និស្សិតឱ្យបានទូលំទូលាយនិងដោះស្រាយបញ្ហាឱ្យទាន់ពេលវេលា
- រៀបចំថ្នាលឌីជីថលគ្រប់គ្រងបម្រែបម្រួលទិន្នន័យគុណភាពរបស់ភាគីពាក់ព័ន្ធបានត្រឹមត្រូវ
- វាយតម្លៃគុណផលកិច្ចការធានាគុណភាព និងគណនេយ្យភាពតាមឌីជីថល។

❖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ កំពុងរៀបចំស្តង់ដាប្រតិបត្តិការ SOP សម្រាប់ដំណើការជ្រើសរើសតួនាទី អ្នកស្រាវជ្រាវ Senior និង Junior Research ដើម្បីលើកទឹកចិត្តដល់បុគ្គលិកអប់រំ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញឱ្យបង្កើនសកម្មភាពស្រាវជ្រាវ។

❖ បន្ទាប់ពីដំណើការ Research Management System (ប្រព័ន្ធគ្រប់គ្រងគម្រោងស្រាវជ្រាវ) ដែលជា Database System ឬ Digital Platform ការិយាល័យស្រាវជ្រាវ អាចនឹងធ្វើការតាមដាន និងវាយតម្លៃ

សមិទ្ធផលស្រាវជ្រាវរបស់បុគ្គលិកអប់រំ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីផ្តល់ជា ការលើកទឹកចិត្តតាមរយៈប័ណ្ណសរសើរ ឬជាថវិកាលើស្នាដៃបោះពុម្ព ឬការបង្កើតផលិតផលថ្មី។

- ការគ្រប់គ្រងការស្រាវជ្រាវផ្តោតសំខាន់លើ៖

→ ការគាំទ្រផ្នែករដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស និងប្រកួតប្រជែងការស្រាវជ្រាវទាំងក្នុង និងក្រៅស្ថាប័ន។

- បង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រស្រាវជ្រាវ រួមទាំងកញ្ចប់ថវិការបស់សាកលវិទ្យាល័យសម្រាប់ជំរុញការស្រាវជ្រាវ យុទ្ធសាស្ត្រផ្សព្វផ្សាយការស្រាវជ្រាវ និងនវានុវត្តន៍។

គ្រប់គ្រងមជ្ឈមណ្ឌលស្រាវជ្រាវនិងប្រើប្រាស់ធនធានដែលមានប្រកបដោយប្រសិទ្ធភាព។

ឧបសម័ន្ធ២៖ សាកលវិទ្យាល័យជាតិគ្រប់គ្រង



របាយការណ៍ឥឌ្ឍនភាពឆ្នាំ២០១៤-២០២៦
សាកលវិទ្យាល័យជាតិគ្រប់គ្រង (NUM)

១. សេចក្តីផ្តើម

សាកលវិទ្យាល័យជាតិគ្រប់គ្រង (ហៅកាត់ថា ស.ជ.គ ឬ NUM) ជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈរដ្ឋបាលឈានមុខគេក្នុងព្រះរាជាណាចក្រកម្ពុជា បង្កើតឡើងតាំងពីឆ្នាំ១៩៨៣ ស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សាកលវិទ្យាល័យជាតិគ្រប់គ្រង ផ្តល់ជូននូវការអប់រំ និងការបណ្តុះបណ្តាលបីកម្រិតសិក្សា គឺថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត លើមុខជំនាញសំខាន់ៗជាច្រើនរួមមាន គ្រប់គ្រង, ពាណិជ្ជកម្ម, គណនេយ្យ, ហិរញ្ញវត្ថុ និងធនាគារ, សេដ្ឋកិច្ច, ទេសចរណ៍, នីតិសាស្ត្រ, គោលនយោបាយសាធារណៈ, ព័ត៌មានវិទ្យា, ភាសាបរទេស, សេដ្ឋកិច្ចបច្ចេកវិទ្យាឌីជីថល, និងវិស្វកម្មរ៉ូបូទិច។

ក្នុងចន្លោះឆ្នាំ២០១៤ ដល់ឆ្នាំ២០២៦ សាកលវិទ្យាល័យជាតិគ្រប់គ្រង បានឆ្លងកាត់ដំណាក់កាលអភិវឌ្ឍន៍យ៉ាងសកម្ម និងការធ្វើកំណែទម្រង់ស៊ីជម្រៅ ដោយបានជំនះនូវឧបសគ្គធំៗ ជាពិសេសការប្រឈមមុខនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ ព្រមទាំងការសម្របខ្លួនទៅនឹងបរិវត្តកម្មឌីជីថល និងបដិវត្តឧស្សាហកម្ម ៤.០។ តាមរយៈការដាក់ចេញនូវផែនការយុទ្ធសាស្ត្រ និងការអនុវត្តប្រកបដោយចក្ខុវិស័យ សាកលវិទ្យាល័យបានពង្រឹងគុណភាពអប់រំ ការស្រាវជ្រាវ នវានុវត្តន៍ និងការធ្វើអន្តរជាតិភាវូបនីយកម្ម ដើម្បីឆ្លើយតបយ៉ាងស័ក្តិសិទ្ធិទៅនឹងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលកម្ពុជា និងស្តង់ដាអប់រំកម្រិតតំបន់អាស៊ាន និងសកលលោក។

២. សមិទ្ធភាពដែលសម្រេចបាន

២.១. អភិបាលកិច្ច ស្វ័យភាព និងការធានាគុណភាព

២.១.១. អភិបាលកិច្ច និងស្វ័យភាព

- **ការគ្រប់គ្រងហិរញ្ញវត្ថុ និងស្វ័យភាព៖** ក្នុងនាមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល សាកលវិទ្យាល័យបានដំណើរការប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុដោយស្វ័យភាព ផ្អែកលើចំណូលពីការបង់ថ្លៃសិក្សារបស់

និស្សិត និងត្រូវបានត្រួតពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សាភិបាល ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រកបដោយតម្លាភាព និងគណនេយ្យភាព។

- បរិវត្តកម្មរដ្ឋបាលឌីជីថល៖ បានអភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យនិស្សិត,ប្រព័ន្ធព័ត៌មានធនធានមនុស្ស (HRMIS), ប្រព័ន្ធចុះឈ្មោះ និងទូទាត់ថ្លៃសិក្សាអនឡាញ (E-Registration; E-Payment) ព្រមទាំងសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសាកលវិទ្យាល័យ (UMS) និងផ្ទាល់ផ្ទៀងផ្ទាត់សញ្ញាបត្រ Verify.gov.kh។
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងទីតាំងថ្មី៖ ក្រៅពីការធ្វើទំនើបកម្មបន្ទប់សិក្សា អាហារដ្ឋាន ហាងកាហ្វេសាលប្រជុំ និងបណ្តាញWi-Fi ល្បឿនលឿន (២,៦០០ Mb) នៅទីតាំងវត្តភ្នំ សាកលវិទ្យាល័យបានទទួលដីទំហំ ៦ហិកតា នៅភូមិវាលស្បូវ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ ពីរាជរដ្ឋាភិបាល/ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីអភិវឌ្ឍជាសាខាមហាវិទ្យាល័យសេដ្ឋកិច្ចបច្ចេកវិទ្យាឌីជីថល ដោយបានចាក់ដីបំពេញ ធ្វើផ្លូវបេតុងសាងសង់អគារសិក្សា ១ខ្នង (៤ជាន់ មាន ១៥បន្ទប់) សាលសន្និបាត និងសួនច្បារ ស្រះទឹក និងតារាងបាល់ទាត់។

២.១.២. ការធានាគុណភាព

- **ការបង្កើត និងពង្រឹងយន្តការ IQA៖** បានបង្កើតការិយាល័យធានាគុណភាពផ្ទៃក្នុង (IQA) រៀបចំសៀវភៅណែនាំស្តីពីការធានាគុណភាព (NUM IQA Manual) អនុវត្តយន្តការវាយតម្លៃការបង្រៀនរបស់សាស្ត្រាចារ្យដារៀងរាល់ឆមាស និងការស្ទង់មតិ ស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា។
- ការទទួលស្គាល់គុណភាពអប់រំកម្រិតជាតិ (ACC)៖ បានទទួលការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិកម្រិតស្ថាប័ន (Institutional Accreditation) ពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (ACC) នាខែឧសភា ឆ្នាំ២០២០។
- ការធ្វើសមាហរណកម្មធានាគុណភាពតំបន់ (AUN-QA)៖ បានចូលជាសមាជិកបណ្តាញសាកល-វិទ្យាល័យអាស៊ាន (AUN-QA Associate Member) និងបានរៀបចំវាយតម្លៃស្វ័យវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងកម្រិតកម្មវិធីសិក្សា (Program Level) ស្របតាម AUN-QA Framework Version 4.0។
- ចំណាត់ថ្នាក់ពិភពលោក (WURI Rankings)៖ សាកលវិទ្យាល័យទទួលបានកិត្តិយសជាប់ចំណាត់ថ្នាក់ក្នុងចំណោម World Top 100 នៃសាកលវិទ្យាល័យដែលមានឥទ្ធិពល និងនវានុវត្តន៍ (WURI Rankings) ក្នុងនោះជាប់ចំណាត់ថ្នាក់ Top 50 លើផ្នែក Fourth Industrial Revolution, Entrepreneurial Spirit, Ethical Value, Crisis Management, Industrial Application, និង Student Mobility and Openness។

២.២. កម្មវិធីសិក្សា និង ការបណ្តុះបណ្តាល

២.២.១. ការធ្វើទំនើបកម្ម និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា

- **ការតំរូវតាមក្របខ័ណ្ឌគុណវុឌ្ឍជាតិ (CQF) និង OBE៖** បានធ្វើទំនើបកម្មកម្មវិធីសិក្សាទាំងថ្នាក់បរិញ្ញាបត្រនិងបរិញ្ញាបត្រជាន់ខ្ពស់ជាង ៣០មុខជំនាញ ឱ្យស្របតាមក្របខ័ណ្ឌគុណវុឌ្ឍជាតិកម្ពុជា និងក្របខ័ណ្ឌអប់រំផ្តោតលើលទ្ធផល (Outcomes-Based Education - OBE) ដោយរៀបចំឱ្យមាន

ច្បាស់លាស់នូវ Program Learning Outcomes (PLOs) និង Course Learning Outcomes (CLOs)។

- ការបង្កើតជំនាញថ្មីៗស្របតាមសេដ្ឋកិច្ចឌីជីថល៖ បានអភិវឌ្ឍកម្មវិធីសិក្សាថ្នាក់ជាតិ និងអន្តរជាតិថ្មីៗឆ្លើយតបនឹងទីផ្សារការងារ រួមមាន៖ Global Innovation Management, Entrepreneurship, Digital Economy, Financial Technology (FinTech), Smart City Planning Management, International Bussiness, Global Entrepreneurship and Innovation, International Finance, Supply Chain Management, iLaw និង Robotic Engineering។

២.២.២. ការបណ្តុះបណ្តាល

- **ទំហំបណ្តុះបណ្តាល និងអត្រាទទួលបានការងារ៖** បានបណ្តុះបណ្តាលនិស្សិតសរុបជិត ៧ម៉ឺននាក់តាំងពីបង្កើតមក ហើយជារៀងរាល់ឆ្នាំមាននិស្សិតកំពុងសិក្សាចន្លោះពី ៩,០០០ ទៅ ១៦,០០០ នាក់ លើថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត។ អត្រានិស្សិតបញ្ចប់ការសិក្សាទទួលបានការងារធ្វើភ្លាមៗមានកម្រិតខ្ពស់រហូតដល់ ៦៩% ទៅ ៩៣%។
- ការគាំទ្រសមធម៌ និងអាហារូបករណ៍៖ បានផ្តល់អាហារូបករណ៍រដ្ឋ និងអាហារូបករណ៍សាកលវិទ្យាល័យ ១០០% ជូនដល់និស្សិតក្រីក្រ និស្សិតនារី និងនិស្សិតឆ្នើមរាប់ពាន់នាក់ជាប្រចាំ។
- ដំណោះស្រាយឆ្លើយតបវិបត្តិ(E-Learning)៖ក្នុងកំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩ សាកល-វិទ្យាល័យបានផ្លាស់ប្តូរទៅជាការសិក្សាតាមប្រព័ន្ធអនឡាញ (Google Classroom និង Google Meet) បានទាន់ពេលវេលា និងធានាបាននូវនិរន្តរភាពនៃការអប់រំ។

២.៣. បច្ចេកវិទ្យា និង កិច្ចសហប្រតិបត្តិការអន្តរជាតិ

២.៣.១. បច្ចេកវិទ្យា

- **ការបង្កើតមន្ទីរពិសោធន៍ និងបន្ទប់អនុវត្តឌីជីថល៖** បានបង្កើត និងធ្វើទំនើបកម្មបន្ទប់ពិសោធន៍បច្ចេកវិទ្យាជាច្រើន រួមមាន Computer Lab, Social Innovation Lab, Digital Lab, Robot Lab, Camboverse Lab (VR/AR), Smart Classroom, និង Language Lab។
- ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា៖ បានបំពាក់បរិក្ខារបច្ចេកវិទ្យា កុំព្យូទ័រ សែរ៉ាវើ និងការភ្ជាប់បណ្តាញអ៊ីនធឺណិតល្បឿនលឿន Wi-Fi សរុប២,៦០០Mb គ្របដណ្តប់បរិវេណសាកលវិទ្យាល័យ។

២.៣.២. កិច្ចសហប្រតិបត្តិការអន្តរជាតិ

- **បណ្តាញដៃគូសកល៖** បានចុះអនុស្សរណៈយោគយល់ (MoU/MoA) ជាមួយសាកលវិទ្យាល័យ និងស្ថាប័នអន្តរជាតិជាង ១០០ មកពីអាមេរិក បារាំង អាល្លឺម៉ង់ អេស្ប៉ាញ អ៊ីតាលី ជប៉ុន កូរ៉េ ចិន សិង្ហបុរី វៀតណាមម៉ាឡេស៊ី ហ្វីលីពីន ឥណ្ឌូនេស៊ី ជាដើម។
- សមាជិកភាព និងបណ្តាញអន្តរជាតិ៖ សាកលវិទ្យាល័យជាតិគ្រប់គ្រង ជាសាកលវិទ្យាល័យតែមួយគត់ក្នុងប្រទេសកម្ពុជាដែលជាសមាជិកនៃ Global Business School Network (GBSN) និងជាសមាជិក Agence Universitaire de la Francophonie (AUF)។
- កម្មវិធីផ្លាស់ប្តូរបុគ្គលិក និងនិស្សិត (Mobility Programs)៖ បានបញ្ជូនសាស្ត្រាចារ្យ បុគ្គលិក និងនិស្សិតរាប់រយនាក់ទៅចូលរួមវគ្គបណ្តុះបណ្តាល ទស្សនកិច្ចសិក្សា សិក្ខាសាលា និងការផ្លាស់ប្តូរការ

សិក្សានៅក្រៅប្រទេស ក្រោមគម្រោង Erasmus+, SHARE, AIMS, YSS-ASEAN, JENESYS, និង Learning Express (LEX) ជាមួយ Singapore Polytechnic។

- កម្មវិធីសញ្ញាបត្ររួមគ្នា (Dual/Joint Degree)៖ បានដំណើរការកម្មវិធីថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់សញ្ញាបត្ររួមគ្នាជាមួយសាកលវិទ្យាល័យដៃគូអន្តរជាតិ ដូចជា ICN Business School (បារាំង) និង University of Wisconsin-Green Bay (អាមេរិក)។

២.៤. ការស្រាវជ្រាវ និងបណ្តាញដៃគូសាកល

- **ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវឯកទេស៖** បានបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ (CERI), វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន (AERI), មជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន, មជ្ឈមណ្ឌលអាជីវកម្មគ្រួសារ, មជ្ឈមណ្ឌលស្វែងរកការងារ (Career Center) និង Student Research Club (SRC)។
- គម្រោងស្រាវជ្រាវអន្តរជាតិ៖ ទទួលបាន និងអនុវត្តគម្រោងស្រាវជ្រាវធំៗក្រោមមូលនិធិសហភាពអឺរ៉ុប (Erasmus+), ធនាគារពិភពលោក, ADB, UNDP, និង The Asia Foundation រួមមានគម្រោង DOCKSIDE, WANASEA, BALANCE, SEASIN, FAB, ENGAGE, GREENCAP, SCALE, ALIGNING, UNICATION, និង CHAIN។
- ការបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវ៖ បានបោះពុម្ពផ្សាយកម្រងស្នាដៃស្រាវជ្រាវ NUM Research Series ជាទៀងទាត់ (Volume I ដល់ Volume VIII) ព្រមទាំងបោះពុម្ពអត្ថបទស្រាវជ្រាវក្នុងទស្សនាវដ្តីជាតិ និងអន្តរជាតិ (Peer-reviewed Journals) រាប់សិបប្រធានបទ។

៣. បញ្ហាប្រឈម និងដំណោះស្រាយ

៣.១. អភិបាលកិច្ច ស្ថិរភាព និងការធានាគុណភាព

៣.១.១. អភិបាលកិច្ច និងស្ថិរភាព

- **បញ្ហាប្រឈម:** ទីតាំងដើម (វត្តភ្នំ) មានលក្ខណៈតូចចង្អៀត ពិបាកក្នុងការអភិវឌ្ឍបន្ថែម ចំនួនមន្ត្រីក្របខ័ណ្ឌមានតិច និងជិតចូលនិវត្តន៍ច្រើន ព្រមទាំងប្រភពថវិកាសាកលវិទ្យាល័យពឹងផ្អែកស្ទើរតែទាំងស្រុងលើការបង់ថ្លៃសិក្សារបស់និស្សិត។
- **ដំណោះស្រាយ:** ពង្រីកទីតាំងថ្មីនៅវាលស្បូវ ធ្វើតម្រូវការបន្ថែមក្របខ័ណ្ឌមន្ត្រីទៅក្រសួងអប់រំ យុវជន និងកីឡា និងខិតខំកៀរគរប្រភពចំណូលបន្ថែមពីសេវាកម្ម និងដៃគូអភិវឌ្ឍន៍។

៣.១.២. ការធានាគុណភាព

- **បញ្ហាប្រឈម:** ធនធាន និងពេលវេលាក្នុងការរៀបចំឯកសារ និងស្វ័យវាយតម្លៃឱ្យស្របតាមស្តង់ដាតំបន់ និងអន្តរជាតិនៅមានកម្រិត។
- **ដំណោះស្រាយ:** បណ្តុះបណ្តាលមន្ត្រី និងសាស្ត្រាចារ្យអំពីក្របខ័ណ្ឌ AUN-QA តាមដាន និងវាយតម្លៃការបង្រៀនរបស់សាស្ត្រាចារ្យជារៀងរាល់ឆមាស។

៣.២. កម្មវិធីសិក្សា និង ការបណ្តុះបណ្តាល

៣.២.១. ការធ្វើទំនើបកម្ម និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា

- **បញ្ហាប្រឈម:** ការបន្សាំកម្មវិធីសិក្សាឱ្យទាន់ការប្រែប្រួលយ៉ាងលឿននៃបច្ចេកវិទ្យា និងតម្រូវការសេដ្ឋកិច្ចឌីជីថល។

- **ដំណោះស្រាយ:** ធ្វើធ្វើទំនើបកម្មកម្មវិធីសិក្សាជាប្រចាំដោយផ្អែកលើការស្ទង់មតិទីផ្សារការងារ និងការបញ្ចូលជំនាញបច្ចេកវិទ្យាថ្មីៗ។

២.២.២. ការបណ្តុះបណ្តាល

- **បញ្ហាប្រឈម:** ការរៀបចំការបណ្តុះបណ្តាលក្នុងដំណាក់កាលវិបត្តិ (ដូចជាកូវីដ-១៩) និងការអភិវឌ្ឍសមត្ថភាពឌីជីថលរបស់សាស្ត្រាចារ្យមួយចំនួននៅមានកម្រិត។
- **ដំណោះស្រាយ:** បង្កើតវគ្គបណ្តុះបណ្តាលវិធីសាស្ត្របង្រៀនតាមបែបឌីជីថល និងការប្រើប្រាស់ប្រព័ន្ធអនឡាញ។

៣.៣. បច្ចេកវិទ្យា និង កិច្ចសហប្រតិបត្តិការអន្តរជាតិ

៣.៣.១. បច្ចេកវិទ្យា

- **បញ្ហាប្រឈម:** ថវិកាក្នុងការវិនិយោគ និងថែទាំឧបករណ៍បច្ចេកវិទ្យាទំនើបៗនៅមានកម្រិត។
- **ដំណោះស្រាយ:** ស្វែងរកការឧបត្ថម្ភ និងកិច្ចសហប្រតិបត្តិការពីដៃគូឯកជន អង្គការ និងក្រសួងស្ថាប័នពាក់ព័ន្ធ (ដូចជា UNDP, Smart, ក្រសួងប្រៃសណីយ៍)។

៣.៣.២. កិច្ចសហប្រតិបត្តិការអន្តរជាតិ

- **បញ្ហាប្រឈម:** កម្រិតភាសាបរទេស និងការចំណាយលើការធ្វើដំណើរផ្លាស់ប្តូររបស់និស្សិត/សាស្ត្រាចារ្យ។
- **ដំណោះស្រាយ:** ស្វែងរកអាហារូបករណ៍ និងគម្រោងគាំទ្រថវិកាពីដៃគូអន្តរជាតិ (ដូចជា Erasmus+, AIMS, SEAMEO)។

៣.៤. ការស្រាវជ្រាវ និងបណ្តាញដៃគូសាកល

- **បញ្ហាប្រឈម:** ថវិកាសាកលវិទ្យាល័យសម្រាប់ការស្រាវជ្រាវនៅមានកម្រិត ហើយការចូលរួមសកម្មភាពស្រាវជ្រាវពីសាស្ត្រាចារ្យ និងនិស្សិតនៅមានភាគរយតិច។
- **ដំណោះស្រាយ:** បង្កើតកញ្ចប់ថវិកាស្រាវជ្រាវប្រចាំឆ្នាំ, បង្កើនការលើកទឹកចិត្ត, បង្កើត Student Research Club (SRC), និងបង្កើនការចូលរួមក្នុងគម្រោងស្រាវជ្រាវរួមជាមួយបរទេស។

៤. ផែនការសកម្មភាពសម្រាប់ពេលអនាគត

៤.១. អភិបាលកិច្ច ស្ថិរភាព និងការធានាគុណភាព

៤.១.១. អភិបាលកិច្ច និងស្ថិរភាព

- បញ្ចប់ការសាងសង់សាលសន្និបាត និងអគារសិក្សា ២០បន្ទប់ ព្រមទាំងចំណត និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅទីតាំងវាលស្បូវ។
- កៀរគរប្រភពថវិកាស្ថិរភាពបន្ថែមដើម្បីគាំទ្រដល់ដំណើរការអភិវឌ្ឍទីតាំងវាលស្បូវដំណាក់កាលបន្តបន្ទាប់។
- បន្តជ្រើសរើស និងបណ្តុះបណ្តាលសាស្ត្រាចារ្យ និងមន្ត្រីវ័យក្មេងជំនួសគ្រូចាស់ៗដែលត្រូវចូលនិវត្តន៍។

៤.១.២. ការធានាគុណភាព

- អភិវឌ្ឍកម្មវិធីសិក្សាឱ្យស្របតាមស្តង់ដាធានាគុណភាពអប់រំជាតិ និងរៀបចំទទួលការវាយតម្លៃគុណភាពកម្រិតកម្មវិធីពី AUN-QA ឱ្យបានយ៉ាងតិចមួយមុខជំនាញនៅគ្រប់មហាវិទ្យាល័យ។

- បន្តធ្វើការសិក្សាអំពី ស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា និងអត្រាបោះបង់ការសិក្សាដើម្បីយកមកកែលម្អគុណភាពសេវាអប់រំ។

៤.២. កម្មវិធីសិក្សា និង ការបណ្តុះបណ្តាល

៤.២.១. ការធ្វើទំនើបកម្ម និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា

- ធ្វើទំនើបកម្មកម្មវិធីសិក្សាដោយប្រើប្រាស់យន្តការនៃមុខងារមជ្ឈមណ្ឌលការងារ (Career Center) ដើម្បីបណ្តុះបណ្តាលជំនាញឆ្លើយតបនឹងទីផ្សារការងារ និងសេដ្ឋកិច្ចសង្គម។
- បង្កើនការបណ្តុះបណ្តាលជំនាញឌីជីថល បច្ចេកវិទ្យា និងសហគ្រិនភាពក្នុងគ្រប់កម្មវិធីសិក្សា។

៤.២.២. ការបណ្តុះបណ្តាល

- បង្កើនគុណវុឌ្ឍិសាស្ត្រាចារ្យឱ្យបានដល់កម្រិតបណ្ឌិតកាន់តែច្រើន។
- អភិវឌ្ឍ និងពង្រីកកម្មវិធីបណ្តុះបណ្តាលតាមបែបចម្រុះ (Blended Learning) និងការសិក្សាពីចម្ងាយ (Distance Learning)។

៤.៣. បច្ចេកវិទ្យា និង កិច្ចសហប្រតិបត្តិការអន្តរជាតិ

៤.៣.១. បច្ចេកវិទ្យា

- បន្តអភិវឌ្ឍ និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការអប់រំតាមបែបឌីជីថល (Digital Education Infrastructure)។
- ពង្រីកការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក្នុងការគ្រប់គ្រងទិន្នន័យនិស្សិត (UMS) និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឱ្យកាន់តែមានប្រសិទ្ធភាព។

៤.៣.២. កិច្ចសហប្រតិបត្តិការអន្តរជាតិ

- ពង្រឹង និងពង្រីកកម្មវិធីកិច្ចសហប្រតិបត្តិការជាមួយដៃគូក្នុងតំបន់ និងអន្តរជាតិ ដើម្បីសមាហរណកម្មសាកលវិទ្យាល័យទៅក្នុងលំដាប់ថ្នាក់តំបន់ និងពិភពលោក។
- បង្កើនកម្មវិធីសញ្ញាបត្ររួមគ្នា (Dual/Joint Degree) និងការផ្លាស់ប្តូរបុគ្គលិក/និស្សិតទៅក្រៅប្រទេស។

៤.៤. ការស្រាវជ្រាវ និងបណ្តាញដៃគូសាកល

- លើកកម្ពស់ការស្រាវជ្រាវ អភិវឌ្ឍសហគ្រិនភាព និងនវានុវត្តន៍ ព្រមទាំងជំរុញការបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវកម្រិតជាតិ និងអន្តរជាតិ។
- ជំរុញកិច្ចសហការស្រាវជ្រាវជាមួយវិស័យឧស្សាហកម្ម និងស្ថាប័នរដ្ឋដើម្បីដោះស្រាយបញ្ហាសង្គម-សេដ្ឋកិច្ច។

ឧបសម្ព័ន្ធ៣៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច



ឧបាយការណ៍វឌ្ឍនភាព
សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

១. សេចក្តីផ្តើម

១.១. សាថនៈ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច គឺជាគ្រឹះស្ថានឧត្តមសិក្សាដំបូងគេក្នុងប្រទេសកម្ពុជា។ សាកលវិទ្យាល័យនេះបានបង្កើតឡើងក្នុងឆ្នាំ១៩៤៩ ដែលមានឈ្មោះវិទ្យាស្ថានសិក្សាច្បាប់ និងសេដ្ឋកិច្ច បន្ទាប់មកបាន ប្រែក្លាយជាវិទ្យាស្ថានជាតិសិក្សានីតិសាស្ត្រ នយោបាយ និងសេដ្ឋកិច្ចនៃកម្ពុជា នៅឆ្នាំ១៩៥៣។ នៅឆ្នាំ១៩៥៧ វិទ្យាស្ថាននេះបានប្រែក្លាយជាមហាវិទ្យាល័យច្បាប់ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ជាអកុសល មហាវិទ្យាល័យ នេះត្រូវបានបិទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ហើយបានបើកឡើងវិញក្នុងឆ្នាំ១៩៨២ ជាសាលាកម្មាភិបាល រដ្ឋបាល និងនីតិសាស្ត្រ។ នៅឆ្នាំ១៩៩២ បានប្តូរឈ្មោះទៅជាមហាវិទ្យាល័យនីតិសាស្ត្រ។ នៅឆ្នាំ១៩៩៤ មហាវិទ្យាល័យនេះបានប្តូរឈ្មោះសាជាថ្មីមកជាមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

នាដើមសហវត្សថ្មី សាកលវិទ្យាល័យបានអភិវឌ្ឍខ្លួនគួរឱ្យកត់សម្គាល់ ដោយនៅឆ្នាំ២០០៣ មហា-វិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានប្រែក្លាយទៅជាសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលហៅកាត់ថា ស.ភ.ន.វ.ស. និងបន្ទាប់មកនៅឆ្នាំ២០០៧ ស.ភ.ន.វ.ស. បានប្រែក្លាយទៅជា គ្រឹះស្ថានសាធារណៈរដ្ឋបាល។

១.២. អំពីហេដ្ឋារចនាសម្ព័ន្ធ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានទីតាំងស្ថិតនៅលើមហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ មានផ្ទៃដីសរុប ២៣ ៦៣៥ម៉ែតក្រឡា ដែលក្នុងនោះមានអគារសិក្សាចំនួន១២ខ្នង បែងចែកជាបន្ទប់សិក្សាចំនួន ១២១បន្ទប់ បន្ទប់កំព្យូទ័រចំនួន ៨បន្ទប់ បន្ទប់ធ្វើការចំនួន ៥២បន្ទប់ បន្ទប់ប្រជុំចំនួន ៦បន្ទប់ សហសាលសិក្សាចំនួន៦សាល បណ្ណាល័យចំនួន៤ បន្ទប់ Sever ចំនួន២បន្ទប់ ឃ្លាំងសម្ភារចំនួន១៨បន្ទប់ និងកង់ទីន១ រួមជាមួយទីតាំងសួនច្បារ និងចំណតយានយន្ត។

១.៣. អំពីរចនាសម្ព័ន្ធគ្រប់គ្រងរបស់សាកលវិទ្យាល័យ

បច្ចុប្បន្នសាកលវិទ្យាល័យមាន ៤មហាវិទ្យាល័យរួមមាន៖ មហាវិទ្យាល័យនីតិសាស្ត្រ មហាវិទ្យាល័យរដ្ឋបាលសាធារណៈ មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង និងមហាវិទ្យាល័យសេដ្ឋកិច្ចព័ត៌មានវិទ្យា និងមានសាលាក្រោយបរិញ្ញាបត្រ និងមជ្ឈមណ្ឌលស្រាវជ្រាវថ្នាក់ស្មើមហាវិទ្យាល័យ។ សាកលវិទ្យាល័យមានដេប៉ាតឺម៉ង់ចំនួន ០៩ រួមមាន៖ ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដេប៉ាតឺម៉ង់នីតិឯកជន ដេប៉ាតឺម៉ង់នីតិសាធារណៈ ដេប៉ាតឺម៉ង់សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដេប៉ាតឺម៉ង់គណនេយ្យនិងគ្រប់គ្រង ដេប៉ាតឺម៉ង់ទំនាក់ទំនងអន្តរជាតិ ដេប៉ាតឺម៉ង់រដ្ឋបាលសាធារណៈ ដេប៉ាតឺម៉ង់ព័ត៌មានវិទ្យា ដេប៉ាតឺម៉ង់សេដ្ឋកិច្ចព័ត៌មានវិទ្យា។

សាកលវិទ្យាល័យមានការិយាល័យ/អង្គភាពចំនួន១៣ រួមមាន៖ ការិយាល័យហិរញ្ញវត្ថុ ការិយាល័យរដ្ឋបាលនិងបុគ្គលិក ការិយាល័យសិក្សា ការិយាល័យកិច្ចការនិស្សិត ការិយាល័យទំនាក់ទំនងអន្តរជាតិ ការិយាល័យធានាគុណភាព លេខាធិការដ្ឋាន អង្គភាពលទ្ធកម្ម ការិយាល័យបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ការិយាល័យបណ្តុះបណ្តាលថ្នាក់បណ្ឌិត ការិយាល័យស្រាវជ្រាវ នវានុវត្តន៍និងបោះពុម្ពផ្សាយ បណ្ណាល័យ និងមជ្ឈមណ្ឌលជាតិសិក្សាជាភាសាបារាំង។

២. សកម្មភាពដែលសម្រេចបាន

២.១. អភិបាលកិច្ច ស្វ័យភាព និងការធានាគុណភាព

២.១.១. អភិបាលកិច្ច និងស្វ័យភាព

បច្ចុប្បន្នសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចមានក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង បុគ្គលិក និងសាស្ត្រាចារ្យជាតិ-អន្តរជាតិ សរុបចំនួន ៨៧៣ នាក់(នារី២៣៣ នាក់ ស្មើ ២៦,៦៨%) ក្នុងនោះបានចែកចេញជា៖

១/-ក្រុមប្រឹក្សាភិបាល	ចំនួន ៥ នាក់(ជាបុរស)
២/-គណៈគ្រប់គ្រង បុគ្គលិក និងសាស្ត្រាចារ្យ	ចំនួន ៩៤ នាក់(នារី ១៨ នាក់)
៣/-បុគ្គលិកជាប់កិច្ចសន្យា	ចំនួន ១១១ នាក់(នារី ៦០ នាក់)
៤/-សាស្ត្រាចារ្យអញ្ជើញឱ្យមកបង្រៀន	ចំនួន ៦៣០ នាក់(នារី ១៣៣ នាក់)
៥/-សាស្ត្រាចារ្យ និងជំនាញការបរទេស	ចំនួន ១៤ នាក់(នារី ១០ នាក់)
៦/-បុគ្គលិកជំនួយការជនជាតិខ្មែរ	ចំនួន ១៩ នាក់(នារី ១២ នាក់)។

ជំនាញការ និងសាស្ត្រាចារ្យបរទេសកំពុងបំពេញការងារជាអចិន្ត្រៃយ៍ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចសរុបមានចំនួន១៤ នាក់(នារី ១០ នាក់) រួមមានជនជាតិដូចខាងក្រោម៖

១/-ជនជាតិអាមេរិកចំនួន ១ នាក់(ជានារី)
២/-ជនជាតិបារាំងចំនួន ៦ នាក់(នារី ៤ នាក់)
៣/-ជនជាតិជប៉ុនចំនួន ៤ នាក់(នារី ៣ នាក់)
៤/-ជនជាតិអង់គ្លេសចំនួន ១ នាក់(ជានារី)
៥/-ជនជាតិកាណាដាចំនួន ១ នាក់(ជានារី)
៦/-ជនជាតិអូស្ត្រាលីចំនួន ១ នាក់(ជាបុរស)

ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង បុគ្គលិក និងសាស្ត្រាចារ្យចំនួន ៨៧៣ នាក់(នារី២៣៣នាក់) មានកម្រិតសញ្ញាបត្រដូចជា៖

១/-កម្រិតបណ្ឌិត	ចំនួន ៩៤ នាក់(នារី១០ នាក់)
២/-កម្រិតបរិញ្ញាបត្រជាន់ខ្ពស់	ចំនួន ៦១៨ នាក់(នារី១៥៨ នាក់)
៣/-កម្រិតបរិញ្ញាបត្រ	ចំនួន ១១៧ នាក់(នារី៤៧ នាក់)
៤/-កម្រិតក្រោមបរិញ្ញាបត្រ	ចំនួន ៤៤ នាក់(នារី១៨ នាក់)។

២.១.២. ការធានាគុណភាព

- **ឆ្នាំ2015 បានវាយតម្លៃសាកល្បងកម្រិតស្តាប់ដោយACC**
- **ឆ្នាំ2017 បង្កើតក្រុមមន្ត្រីវាយតម្លៃគុណភាពផ្ទៃក្នុងចំនួន១២នាក់**
- **ឆ្នាំ2018 និងឆ្នាំ2019 បណ្តុះបណ្តាលក្រុមមន្ត្រីវាយតម្លៃគុណភាពផ្ទៃក្នុងចំនួន១២នាក់**
- **ឆ្នាំ2021:ការវាយតម្លៃទទួលស្គាល់កម្រិតស្តាប់ដោយACC**
- **ឆ្នាំ2024: ការវាយតម្លៃទទួលស្គាល់កម្មវិធី ELBBLដោយACC**
- **ឆ្នាំ2025 បណ្តុះបណ្តាលក្រុមមន្ត្រីវាយតម្លៃគុណភាពផ្ទៃក្នុង ចំនួន១២នាក់ និងមន្ត្រីគ្រប់គ្រង តាមមហាវិទ្យាល័យនិងសាលាក្រោយបរិញ្ញាបត្រ**
- **ឆ្នាំ2025: ការវាយតម្លៃទទួលស្គាល់កម្មវិធី IR ដោយACC**

២.២.កម្មវិធីសិក្សា និងការបណ្តុះបណ្តាល

២.២.១. ការធ្វើទំនើបកម្ម និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា

ចាប់តាំងពីឆ្នាំ១៩៨២-១៩៨៣ ដល់ឆ្នាំសិក្សា២០២៣-២០២៤ កន្លងមកនេះ សិក្ខាកាម និងនិស្សិតបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចសរុបចំនួន ៧៤ ៣៣៧ នាក់ (នារី ៣០ ៣៧៤នាក់ ស្មើនឹង ៤០,៨៥%) ក្នុងនោះបានចែកចេញជា៖

១/-សិក្ខាកាមសិក្សារយៈពេលខ្លី-មធ្យម	ចំនួន ៣.០០០នាក់
២/-និស្សិតថ្នាក់បរិញ្ញាបត្ររង	ចំនួន ៧០៦ នាក់(នារី ១៩៧នាក់)
៣/-និស្សិតថ្នាក់បរិញ្ញាបត្រ	ចំនួន ៦០.២៤៨នាក់(នារី ២៧.១៦២នាក់)
៤/-និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់	ចំនួន ១០.៣៨៣ នាក់(នារី ៣.០១៥នាក់)។

-បញ្ជាក់៖ក្នុងចំណោមនិស្សិតបានបញ្ចប់ការសិក្សានេះ មាននិស្សិតជនជាតិបរទេសថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអាហារូបករណ៍ និងផ្នែកសិក្សាបង់ថ្លៃសរុបចំនួន ២៦៨នាក់ (នារី ១២១នាក់) ក្នុងនោះចែកជា៖

១/-ថ្នាក់បរិញ្ញាបត្រផ្នែកអាហារូបករណ៍ចំនួន ៦៦ នាក់(នារី ២៦នាក់)៖ ជាជនជាតិឡាវ។

២/-ថ្នាក់បរិញ្ញាបត្រផ្នែកសិក្សាបង់ថ្លៃចំនួន ៣៩ នាក់(នារី ៧នាក់)៖មានជនជាតិកូរ៉េ ១៧នាក់(នារី ៧នាក់) វៀតណាម ១០នាក់(ជាបុរស)ជប៉ុន ១នាក់(ជាបុរស)ចិន ៣នាក់(ជាបុរស)បារាំង ៨នាក់(ជាបុរស)

៣/-ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសិក្សាបង់ថ្លៃចំនួន ១៦៣ នាក់ (នារី ៨៨ នាក់)៖ មានជនជាតិបារាំង ១១៩ នាក់ (នារី៦៤នាក់) ចិន ១២នាក់ (នារី៩នាក់) អាមេរិក ២នាក់(ជាបុរស) បង់ក្លាដែស ១

នាក់(ជាបុរស) កូរ៉េ ៥នាក់ (នារី៣នាក់) ជប៉ុន ៣នាក់(ជាបុរស) ម៉ារ៉ុក ២នាក់ (ជានារី) អង់គ្លេស ៨នាក់ (នារី ៤នាក់) ម៉ាលី ១នាក់(ជាបុរស) ហ្គាបុង១នាក់(ជាបុរស) និងទុយនេស៊ី ១នាក់(ជានារី) អ៊ុយក្រែន ១នាក់(ជានារី) តួគី២នាក់(ជានារី) វៀតណាម ២នាក់(នារី ១នាក់) ហ្វីលីពីន ២នាក់ (នារី ១នាក់) និង ណូវែលហ្សឡង់១នាក់(ជាបុរស)។

២.២.២. ការបណ្តុះបណ្តាល

សាកលវិទ្យាល័យបានបែងចែកកម្រិតបណ្តុះបណ្តាលជាបីកម្រិត និងបានធ្វើទំនើបកម្មកម្មវិធីសិក្សារៀងរាល់បួនឆ្នាំម្តងក្នុងនោះរួមមាន ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ដែលមានដូចខាងក្រោម៖

ថ្នាក់បរិញ្ញាបត្រសិក្សាជាភាសាខ្មែរ កម្មវិធីសិក្សាមានរយៈពេល៤ឆ្នាំ មាន៤មហាវិទ្យាល័យ និងមាន ៩បរិញ្ញាបត្រសម្រាប់ជ្រើសរើស រួមមាន៖

- **❖ មហាវិទ្យាល័យនីតិសាស្ត្រ**
  - បរិញ្ញាបត្រនីតិសាស្ត្រ
- **❖ មហាវិទ្យាល័យរដ្ឋបាលសាធារណៈ**
  - បរិញ្ញាបត្ររដ្ឋបាលសាធារណៈ
- **❖ មហាវិទ្យាល័យសេដ្ឋកិច្ចព័ត៌មានវិទ្យា**
  - បរិញ្ញាបត្រសេដ្ឋកិច្ចព័ត៌មានវិទ្យា
  - បរិញ្ញាបត្រព័ត៌មានវិទ្យា
- **❖ មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង**
  - បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍
  - បរិញ្ញាបត្រគ្រប់គ្រងធុរកិច្ច
  - បរិញ្ញាបត្រគណនេយ្យ
  - បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ
  - បរិញ្ញាបត្រគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច

ថ្នាក់បរិញ្ញាបត្រសិក្សាជាភាសាបរទេសនិស្សិតត្រូវមានវិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋានឬមានបរិញ្ញាបត្រ ជំនាញផ្សេងៗ លើកលែងតែ បរិញ្ញាបត្រនីតិសាស្ត្រ ខ្មែរ-ចិន(២+២)ត្រូវឆ្លងកាត់ការប្រឡងជ្រើសរើសកម្មវិធី សិក្សារយៈពេល៣ឆ្នាំ ក្នុងនោះរួមមាន៖

- បរិញ្ញាបត្រនីតិសាស្ត្រ សិក្សាជាភាសាបារាំង
- បរិញ្ញាបត្រនីតិសាស្ត្រ សិក្សាជាភាសាអង់គ្លេស (ELBBL)
- បរិញ្ញាបត្រសេដ្ឋកិច្ច និងគ្រប់គ្រង សិក្សាពីរភាសា (បារាំង និងអង់គ្លេស) (EM-FR)
- បរិញ្ញាបត្រសេដ្ឋកិច្ច និងគ្រប់គ្រង សិក្សាជាភាសាអង់គ្លេស (EM-ENG)
- បរិញ្ញាបត្រទំនាក់ទំនងអន្តរជាតិ សិក្សាជាភាសាអង់គ្លេស (IR)
- បរិញ្ញាបត្រនីតិសាស្ត្រ ខ្មែរ-ចិន (២+២) (សិក្សានៅកម្ពុជា២ឆ្នាំ និងនៅចិន២ឆ្នាំ)

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់កម្មវិធីជាតិ កម្មវិធីសិក្សាមានរយៈពេល២ឆ្នាំ សម្រាប់ជ្រើសរើសរួមមាន៖

- **បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ**

ឯកទេសរដ្ឋបាលសាធារណៈ (MPA)

ឯកទេសនីតិឯកជន (MPL)

- **បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច**

ឯកទេសគ្រប់គ្រង (MBM)

ឯកទេសហិរញ្ញវត្ថុ (MBF)

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់កម្មវិធីអន្តរជាតិ កម្មវិធីសិក្សាមានរយៈពេល២ឆ្នាំ សម្រាប់ជ្រើសរើសរួមមាន៖

- នីតិអន្តរជាតិ និងប្រៀបធៀប សិក្សាជាភាសាបារាំង (DIC)
- នីតិភូមិបាល និងបេតិកភណ្ឌ (MFP) សិក្សាជាភាសាខ្មែរតាមរយៈការបកប្រែ
- នីតិធុរកិច្ចអន្តរជាតិ សិក្សាជាភាសាអង់គ្លេស (IBL)
- នីតិសាធារណៈ និងអន្តរជាតិ សិក្សាជាភាសាអង់គ្លេស (PIL)
- នីតិឌីជីថល សិក្សាជាភាសាខ្មែរ និងអង់គ្លេស (DL)
- គ្រប់គ្រងហានិភ័យក្នុងផ្នែកធានារ៉ាប់រង ធនាគារ និងហិរញ្ញវត្ថុ សិក្សាជាភាសាអង់គ្លេស (RMIBF)
- សហគ្រិនភាព និងគ្រប់គ្រងគម្រោង សិក្សាជាភាសាអង់គ្លេស (EPM)
- សេដ្ឋកិច្ច និងពាណិជ្ជកម្ម អាស៊ី-អឺរ៉ុប សិក្សាជាភាសាអង់គ្លេស (EATE)

សម្គាល់៖ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់កម្មវិធីអន្តរជាតិ ខាងលើទទួលបានសញ្ញាបត្រចំនួនពីរ (ខ្មែរ និងបារាំង ឬបែលហ្សិក) លើកលែងតែ កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ សិក្សាជាភាសាអង់គ្លេស (ELBML)

និស្សិតកំពុងសិក្សា

ក្នុងឆ្នាំសិក្សា ២០២៥-២០២៦ នេះ៖ និស្សិតកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សរុបចំនួន ២០ ០១៦ នាក់(នារី ១១ ២១២ នាក់ស្មើ ៥៦,០១%)ក្នុងនោះមាននិស្សិតផ្នែកអាហារូបករណ៍ចំនួន ១៨១៧នាក់ (នារី ១១៣២ នាក់ ស្មើ ៦២,៣០%) និងនិស្សិតផ្នែកសិក្សាបង់ថ្លៃ ១៨ ១៩៩នាក់ (នារី ១០ ០៨០ នាក់ ស្មើ ៥៥,៣៨%)បានចែកចេញជា៖

១/-និស្សិតថ្នាក់បរិញ្ញាបត្រ	ចំនួន ១៦ ៥៩៩ នាក់(នារី ៩៣.៩៩ នាក់ ស្មើ៥៦,៦២%)
២/-និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់	ចំនួន ១ ៥៩៧ នាក់ (នារី ៦៧៩នាក់ ស្មើ ៤២,៥១%)
៣/-និស្សិតថ្នាក់បណ្ឌិត	ចំនួន ៣ នាក់ (នារី ២ នាក់ ស្មើ ៦៦,៦៦%)។

-បញ្ជាក់៖ក្នុងចំណោមនិស្សិតកំពុងសិក្សាមាននិស្សិតជនជាតិបរទេសថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអាហារូបករណ៍ និងផ្នែកសិក្សាបង់ថ្លៃសរុបចំនួន ៩៣ នាក់(នារី ៥៩នាក់) ក្នុងនោះរួមមាន៖

១/-ថ្នាក់បរិញ្ញាបត្រ ផ្នែកអាហារូបករណ៍ចំនួន ៣៧ នាក់(នារី១៨ នាក់)ជាជនជាតិឡាវ

២/-ថ្នាក់បរិញ្ញាបត្រ ផ្នែកសិក្សាបង់ថ្លៃចំនួន១ នាក់(ជានារី)ជាជនជាតិកូរ៉េ

៣/-ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសិក្សាបង់ថ្លៃចំនួន ៥៨នាក់ (នារី៣៩ នាក់) ជាជនជាតិបារាំងចំនួន ៤៥នាក់(នារី៣២ នាក់) អេស្បាញ១នាក់(ជានារី) ហ្គាតេមេឡា១នាក់ (ជាបុរស) ជនជាតិចិន៥ នាក់ (នារី ៤នាក់) វៀតណាម១ នាក់ (ជានារី) ហៃទី ១នាក់(ជានារី)។

៤/-ថ្នាក់បណ្ឌិតផ្នែកសិក្សាបង់ថ្លៃចំនួន១ នាក់(ជានារី)ជាជនជាតិចិន

២.៣.បច្ចេកវិទ្យា និង កិច្ចសហប្រតិបត្តិការអន្តរជាតិ

២.២.១. បច្ចេកវិទ្យា

- បង្កើតប្រព័ន្ធឌីជីថលក្នុងការផ្តល់សេវានិស្សិត
- ចូលរួមក្នុងបណ្តាញសាកលវិទ្យាល័យសាយប៊ីរកម្ពុជា (ប.ស.ស.ក)

២.២.២. កិច្ចសហប្រតិបត្តិការអន្តរជាតិ

ល.រ	ឈ្មោះកិច្ចព្រមព្រៀងសហប្រតិបត្តិការ	ឆ្នាំ	ប្រទេស
1	**Inbound Dual Degree Agreement-Study Abroad Option(5 years) The University of Melbourn**	**2025**	**Australia**
2	**Convention Between RULE and Universite Libre de Bruxelles (Master of IBL)/(5 years)**	**2016**	**Belgium**
3	**Research MoU between RULE and Université du Quebec à Montreal (UQAM)**	**2026**	**Canada**
4	**1-MOU between RULE and East China University of Political Science and Law/(5 years)** **2-MOU between RULE and East China University of Political Science and Law/(5 years)**	**2014** **2023**	**China**
5	**1.MOU between RULE and Southwest University of Political Science and Law(SWUPL)(5 years** **2.Agreement Concerning the Implementation of Education Programs at RULE of the Kingdom of Cambodia by Southwest University of Political Science and Law of the People's Republic of China**	**2015** **2018**	**China**
6	**MOU between RULE and China University of Political Science and Law/(5 years)**	**2026**	**China**
7	**Convention between RULE and Lumiere-Lyon 2 (Bachelor of Law and Economics)/(5 years)**	**2017**	**France**
8	**Convention between RULE and JEAN MOULIN-Lyon 3 (Master of Land Law)/(5 years)**	**2017**	**France**
ល.រ	មហាវិទ្យាល័យ/អង្គភាព	ដេប៉ាតឺម៉ង់/អង្គភាពជំនាញ	បរិញ្ញាបត្រ (BSc)	បរិញ្ញាបត្រជាន់ខ្ពស់/វិជ្ជាជីវៈ	បណ្ឌិត
១	មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម	ដេប៉ាតឺម៉ង់ពាក់ព័ន្ធនឹងដំណាំ ដី ការការពារដំណាំ សាកវប្បកម្ម និងវិទ្យាសាស្ត្រកសិកម្ម	**វិទ្យាសាស្ត្រកសិកម្ម**	វិទ្យាសាស្ត្រដំណាំ	វិទ្យាសាស្ត្រកសិកម្ម; វិទ្យាសាស្ត្រដំណាំ
២	មហាវិទ្យាល័យវិទ្យាសាស្ត្រសត្វ	ដេប៉ាតឺម៉ង់ផលិតកម្មសត្វ អាហារូបត្ថម្ភសត្វ បង្កាត់ពូជ និងវិទ្យាសាស្ត្រសត្វ	**វិទ្យាសាស្ត្រសត្វ**	វិទ្យាសាស្ត្រសត្វ	—
៣	មហាវិទ្យាល័យវេជ្ជសាស្ត្រសត្វ	ដេប៉ាតឺម៉ង់វេជ្ជសាស្ត្រសត្វ រោគសាស្ត្រ អតិសុខុមវិទ្យា ប៉ារ៉ាស៊ីតវិទ្យា និងសុខភាពសត្វ	**វេជ្ជសាស្ត្រសត្វ**	វិទ្យាសាស្ត្រវេជ្ជសាស្ត្រសត្វ; បសុវេជ្ជបណ្ឌិត	—
៤	មហាវិទ្យាល័យព្រៃឈើ	ដេប៉ាតឺម៉ង់ព្រៃឈើ ធនធានធម្មជាតិ បរិស្ថាន និងការគ្រប់គ្រងព្រៃឈើ	**ព្រៃឈើ**	កម្មវិធីពាក់ព័ន្ធធនធានធម្មជាតិ/បរិស្ថាន	—

ល.រ	**មហាវិទ្យាល័យ/អង្គភាព**	**ដេប៉ាតឺម៉ង់/អង្គភាពជំនាញ**	**បរិញ្ញាបត្រ (BSc)**	**បរិញ្ញាបត្រជាន់ខ្ពស់/វិជ្ជាជីវៈ**	**បណ្ឌិត**
៥	មហាវិទ្យាល័យជលផល និងវារីវប្បកម្ម	ដេប៉ាតឺម៉ង់ជលផល វារីវប្បកម្ម និងធនធានជលផល	**ជលផល និងវារីវប្បកម្ម**	—	—
៦	មហាវិទ្យាល័យវិស្វកម្មប្រព័ន្ធដីរកសិកម្ម	ដេប៉ាតឺម៉ង់វិស្វកម្មកសិកម្ម ម៉ាស៊ីនកសិកម្ម ទឹក/ដី និងប្រព័ន្ធដីរកសិកម្ម	**វិស្វកម្មប្រព័ន្ធ ដីរកសិកម្ម**	វិស្វកម្មដីរកសិកម្ម	—
៧	មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ	ដេប៉ាតឺម៉ង់សេដ្ឋកិច្ចកសិកម្ម កសិធុរកិច្ច ការគ្រប់គ្រងកសិដ្ឋាន និងអភិវឌ្ឍន៍ជនបទ	**សេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ**	ការគ្រប់គ្រងកសិដ្ឋាន; សេដ្ឋកិច្ច និងគ្រប់គ្រងការអភិវឌ្ឍ; កសិធុរកិច្ច និងសហគ្រិនភាព; កសិអេកូឡូស៊ី និងប្រព័ន្ធស្បៀងអាហារ	សេដ្ឋកិច្ច និងគ្រប់គ្រងការអភិវឌ្ឍ
៨	មហាវិទ្យាល័យកសិឧស្សាហកម្ម	ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាហារ ក្រោយប្រមូលផល គុណភាព និងសុវត្ថិភាពអាហារ	**កសិឧស្សាហកម្ម**	បច្ចេកវិទ្យា និងវិទ្យាសាស្ត្រអាហារ; សុវត្ថិភាពអាហារ និងការគ្រប់គ្រងគុណភាព	—
៩	មហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី	ដេប៉ាតឺម៉ង់រៀបចំដែនដី រដ្ឋបាលដីធ្លី GIS/Remote Sensing និងផែនការតំបន់	**រៀបចំដែនដី និងរដ្ឋបាលដីធ្លី**	ផែនការអភិវឌ្ឍតំបន់ និងទីក្រុង	ផែនការអភិវឌ្ឍតំបន់ និងទីក្រុង
១០	មហាវិទ្យាល័យអប់រំ និងសារគមនាគមន៍កសិកម្ម	ដេប៉ាតឺម៉ង់អប់រំកសិកម្ម ផ្សព្វផ្សាយកសិកម្ម និងសាគមនាគមន៍	**អប់រំ និងសារគមនាគមន៍កសិកម្ម**	—	—

ល.រ	មហាវិទ្យាល័យ/អង្គភាព	ដេប៉ាតឺម៉ង់/អង្គភាពជំនាញ	បរិញ្ញាបត្រ (BSc)	បរិញ្ញាបត្រជាន់ខ្ពស់/វិជ្ជាជីវៈ	បណ្ឌិត
១១	សាលាបណ្តុះ បណ្តាល ទេពកោសល្យកសិកម្ម	អង្គភាពបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ	—	—	—
១២	សាលាក្រោយបរិញ្ញាបត្រ	អង្គភាពសម្របសម្រួលកម្មវិធីក្រោយបរិញ្ញាបត្រ និងកម្មវិធីពហុជំនាញ	—	ការគ្រប់គ្រងចម្រុះសម្រាប់ការអភិវឌ្ឍកសិកម្ម និងជនបទ; ការគ្រប់គ្រងធនធានធម្មជាតិ; ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយចីរភាព *	សម្របសម្រួលកម្មវិធីបណ្ឌិត

៤. លទ្ធផលនៃការបណ្តុះបណ្តាល

ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយ សាកលវិទ្យាល័យភូមិន្ទកសិកម្មបានបន្តបំពេញតួនាទីស្នូលក្នុងការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់វិស័យកសិកម្ម និងវិស័យពាក់ព័ន្ធ ដោយមាននិស្សិតចូលរៀន និងបញ្ចប់ការសិក្សានៅគ្រប់កម្រិត ចាប់ពីបរិញ្ញាបត្រង បរិញ្ញាបត្រ អនុបណ្ឌិត/បសុវេជ្ជបណ្ឌិត រហូតដល់ថ្នាក់បណ្ឌិត។ ទិន្នន័យបង្ហាញថា ចាប់ពីឆ្នាំសិក្សា ២០១៥–២០១៦ ដល់ ២០២៤–២០២៥ មាននិស្សិតចូលរៀនសរុប **១១,៤០១ នាក់** ក្នុងនោះនារី **៤,៥២៦ នាក់** និងមាននិស្សិតបញ្ចប់ការសិក្សាសរុប **៧,១០២ នាក់** ក្នុងនោះនារី **២,៦៨០នាក់**។

បើពិនិត្យក្នុងរយៈពេលវែង ចាប់ពីឆ្នាំ ១៩៨៤ ដល់ឆ្នាំ ២០២៥ សាកលវិទ្យាល័យបានបណ្តុះបណ្តាលនិស្សិតបញ្ចប់ការសិក្សាសរុប **១៦,៦៨៩ នាក់** ក្នុងនោះនារី **៤,៤៥៦ នាក់** នៅកម្រិតបរិញ្ញាបត្រង បរិញ្ញាបត្រ បសុវេជ្ជបណ្ឌិត អនុបណ្ឌិត និងបណ្ឌិត។ លទ្ធផលនេះបង្ហាញពីការរួមចំណែកយ៉ាងសំខាន់របស់សាកលវិទ្យាល័យក្នុងការផ្តត់ផ្គង់ធនធានមនុស្សជំនាញសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម និងសេដ្ឋកិច្ចជាតិ។

ជាមួយគ្នានេះ ការតាមដាននិស្សិតក្រោយបញ្ចប់ការសិក្សា បង្ហាញថា អត្រានិស្សិតមានការងារធ្វើមាននិន្នា ការកើនឡើងពី **៩៤.៧៥% នៅឆ្នាំ ២០២១ ទៅ ៩៩.៨២% នៅឆ្នាំ ២០២៣** ដោយមានមធ្យម **៩៧.២០%** ក្នុង រយៈពេល ៣ ឆ្នាំ។ ទិន្នន័យនេះបង្ហាញពីភាពពាក់ព័ន្ធរវាងការបណ្តុះបណ្តាលរបស់សាកលវិទ្យាល័យ និងតម្រូវការទីផ្សារការងារ។

តារាងទី ២ ៖ ស្ថិតិនិស្សិតចូលរៀន ១០ ឆ្នាំចុងក្រោយ តាមឆ្នាំសិក្សា

ឆ្នាំសិក្សា	បរិញ្ញាបត្រវេង		បរិញ្ញាបត្រ		អនុបណ្ឌិត /DVM		បណ្ឌិត		សរុបរួម	
	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
2015-2016	93	20	945	364	40	13	0	0	1078	397
2016-2017	61	17	920	339	60	24	0	0	1041	380
2017-2018	72	19	768	303	0	0	0	0	840	322
2018-2019	79	27	888	396	17	6	0	0	984	429
2019-2020	85	36	999	425	38	11	0	0	1122	472
2020-2021	0	0	1400	512	38	13	20	4	1458	529
2021-2022	79	26	1130	467	39	23	18	4	1266	520
2022-2023	55	10	1045	437	30	14	0	0	1130	461
2023-2024	82	20	1130	474	28	14	10	0	1250	508
2024-2025	72	16	1,033	448	107	42	20	2	1232	508
សរុប	**678**	**191**	**10,258**	**4165**	**397**	**160**	**68**	**10**	**11,401**	**4,526**

តារាងទី ៣៖ ស្ថិតិនិស្សិតបញ្ចប់ការសិក្សា ១០ ឆ្នាំចុងក្រោយ តាមឆ្នាំសិក្សា

ឆ្នាំសិក្សា	បរិញ្ញាបត្រវេង		បរិញ្ញាបត្រ		អនុបណ្ឌិត		បណ្ឌិត		សរុបរួម	
	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
2015-2016	93	20	1024	302	37	9	1	1	1155	332
2016-2017	51	10	586	187	13	3	0	0	650	200
2017-2018	5	3	460	142	0	0	0	0	465	145
2018-2019	31	8	609	243	23	9	0	0	663	260
2019-2020	27	10	601	233	27	11	2	0	657	254
2020-2021	28	9	431	187	52	18	3	0	514	214
2021-2022	14	4	553	242	19	5	3	1	589	252
2022-2023	50	21	550	269	31	8	0	0	631	298
2023-2024	31	7	822	337	40	15	5	1	898	360
2024-2025	40	10	804	340	33	14	3	1	880	365
សរុប	**370**	**102**	**6,440**	**2,482**	**275**	**92**	**17**	**4**	**7,102**	**2,680**

តារាងទី ៥ ៖ ស្ថិតិនិស្សិតបញ្ចប់ការសិក្សារយៈពេល ៤០ ឆ្នាំ ពីឆ្នាំ១៩៨៤ ដល់ឆ្នាំ២០២៥

ល.រ	កម្រិតជំនាញ	១៩៨៤–២០២៥	
		សរុប	នារី
1	ថ្នាក់បរិញ្ញាបត្រវេ	869	157
2	ថ្នាក់បរិញ្ញាបត្រ	14,992	4,117
3	ថ្នាក់បសុវេជ្ជបណ្ឌិត (DVM)	112	42
4	ថ្នាក់អនុបណ្ឌិត	691	135
5	ថ្នាក់បណ្ឌិត	25	5
សរុប		16,689	4,456

តារាងទី ៦៖ អត្រានិស្សិតមានការងារធ្វើក្រោយបញ្ចប់ការសិក្សា

ល.រ	បរិយាយ	ឯកតា	2021	2022	2023	សរុប
១	ចំនួននិស្សិតបញ្ចប់ការសិក្សាសរុប	នាក់	514	582	548	1,644
២	ចំនួននិស្សិតរកបានការងារធ្វើសរុប	នាក់	487	564	547	1,598
៣	ភាគរយនិស្សិតមានការងារធ្វើ	%	94.75	96.91	99.82	97.20

៥. លទ្ធផលនៃស្រាវជ្រាវ

ជារួម សាកលវិទ្យាល័យភូមិន្ទកសិកម្មបានពង្រឹងសកម្មភាពស្រាវជ្រាវជាបន្តបន្ទាប់ ទាំងតាមរយៈថវិការដ្ឋ គម្រោង HEIP និងកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិ។ គិតត្រឹមឆ្នាំ២០២៥ សាកលវិទ្យាល័យបានអនុវត្តគម្រោងស្រាវជ្រាវសរុបចំនួន ៣២៥គម្រោង។ ក្នុងនោះមានគម្រោងថវិការដ្ឋ ២៩៧ គម្រោង គម្រោងក្រោមHEIP មាន ១០គម្រោង និងគម្រោងសហប្រតិបត្តិការជាតិ និងអន្តរជាតិ ១៨គម្រោង។ ក្នុងឆ្នាំ២០២៥ មានគម្រោងស្រាវជ្រាវកំពុងអនុវត្តសរុប ៩៣ គម្រោង។

ទន្ទឹមនឹងនេះ សាកលវិទ្យាល័យបានបន្តជំរុញគុណភាពស្រាវជ្រាវ និងការផ្សព្វផ្សាយលទ្ធផលវិទ្យាសាស្ត្រ ដោយគិតត្រឹមឆ្នាំ ២០២៥ មានអត្ថបទវិទ្យាសាស្ត្របោះពុម្ពនៅទស្សនាវដ្តីអន្តរជាតិសរុប ១៣១អត្ថបទ ក្នុងនោះ ១៥ អត្ថបទ ត្រូវបានបោះពុម្ពក្នុងឆ្នាំ២០២៥។ សាកលវិទ្យាល័យក៏បានបង្កើត និងកំពុងដំណើរការទស្សនាវដ្តីកសិកម្មកម្ពុជា (Cambodian Journal of Agriculture) ចាប់ពីឆ្នាំ២០២១ ជាភាសាខ្មែរ និងអង់គ្លេស ដើម្បីគាំទ្រការផ្សព្វផ្សាយស្នាដៃស្រាវជ្រាវ និងចំណេះដឹងវិទ្យាសាស្ត្រកសិកម្ម។

តារាងទី ៧ ៖ សង្ខេបលទ្ធផលស្រាវជ្រាវ

ល.រ	សូចនាករ	គិតត្រឹមឆ្នាំ២០២៥
១	គម្រោងស្រាវជ្រាវថវិការដ្ឋ	297
២	គម្រោងស្រាវជ្រាវក្រោម HEIP	10
៣	គម្រោងសហប្រតិបត្តិការជាតិ និងអន្តរជាតិ	18

ល.រ	សូចនាករ	គិតត្រឹមឆ្នាំ២០២៥
	គម្រោងស្រាវជ្រាវសរុប	**325**
៤	អត្ថបទវិទ្យាសាស្ត្របោះពុម្ពថ្នាក់អន្តរជាតិ	131
៥	ទស្សនាវដ្តីស្រាវជ្រាវរបស់សាកលវិទ្យាល័យ (Cambodian Journal of Agriculture; បង្កើតឆ្នាំ២០២១; ភាសាខ្មែរ និងអង់គ្លេស)	1

៦. លទ្ធផលនៃកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ

ក្នុងរយៈពេល ២០១៥–២០២៥ សាកលវិទ្យាល័យភូមិន្ទកសិកម្មបានពង្រីកកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិជាបន្តបន្ទាប់ ដោយបានចុះអនុស្សរណៈយោគយល់ (MOU) ចំនួន ៨៧ និងកិច្ចព្រមព្រៀងសហប្រតិបត្តិការ (MOA) ចំនួន ៣៥ សរុប ១២២ កិច្ចព្រមព្រៀង ជាមួយសាកលវិទ្យាល័យ គ្រឹះស្ថានស្រាវជ្រាវ ស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ទាំងក្នុង និងក្រៅប្រទេស។

ក្នុងនោះ មានកិច្ចសហប្រតិបត្តិការជាមួយដៃគូក្នុងប្រទេសចំនួន ៣៦ កិច្ចព្រមព្រៀង និងដៃគូអន្តរជាតិចំនួន ៨៦ កិច្ចព្រមព្រៀង ដែលគ្របដណ្តប់យ៉ាងតិច ១៨ ប្រទេស ជាពិសេសប្រទេសក្នុងតំបន់អាស៊ី ព្រមទាំងដៃគូពីអឺរ៉ុប អូស្ត្រាលី និងសហរដ្ឋអាមេរិក។

កិច្ចសហប្រតិបត្តិការទាំងនេះ បានរួមចំណែកដល់ការស្រាវជ្រាវរួម ការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាព ការផ្លាស់ប្តូរនិស្សិត និងបុគ្គលិក អាហារូបករណ៍ កម្មសិក្សា ការអភិវឌ្ឍកម្មវិធីសិក្សា ការផ្ទេរបច្ចេកវិទ្យា និងការភ្ជាប់ជាមួយវិស័យឯកជន ដែលជួយពង្រឹងគុណភាពអប់រំ ស្រាវជ្រាវ និងអន្តរជាតិកម្មរបស់សាកលវិទ្យាល័យ។

៧. លទ្ធផលនៃការធ្វើកំណែទម្រង់ផ្ទៃក្នុង

៧.១ ការអភិវឌ្ឍកម្មវិធីសិក្សា និងគុណភាពបណ្តុះបណ្តាល

- សាកលវិទ្យាល័យបានបន្តធ្វើកំណែទម្រង់កម្មវិធីសិក្សាដោយផ្លាស់ប្តូរទៅរកការអប់រំផ្អែកលើលទ្ធផល (OBE/FEF) ពង្រឹងការគ្រប់គ្រងកម្មវិធីការរៀបចំ Course Syllabus និងការវាយតម្លៃតាមស្តង់ដា AUN-QA។ ក្រោម HEIP2 (២០២៥–២០៣០) ការអភិវឌ្ឍ និងកែលម្អកម្មវិធីសិក្សាត្រូវបានដាក់ជា អាទិភាពដើម្បីបង្កើនភាពពាក់ព័ន្ធនឹងទីផ្សារការងារវិស័យឯកជន និងតម្រូវការអភិវឌ្ឍកសិកម្ម ទំនើប។
- កម្មវិធីសិក្សាថ្មី និងកម្មវិធីដែលកំពុងកែលម្អក្រោម HEIP2 ត្រូវបានអភិវឌ្ឍដោយផ្អែកលើ តម្រូវការជំនាញ ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងការកំណត់លទ្ធផលសិក្សាច្បាស់លាស់ ដើម្បីឱ្យនិស្សិតមានសមត្ថភាព អនុវត្តការគិត វិភាគជំនាញឌីជីថល និងភាពត្រៀមខ្លួនចូលទីផ្សារការងារ។
- ការអភិវឌ្ឍគុណភាពបង្រៀនត្រូវបានគាំទ្រតាមរយៈការបណ្តុះបណ្តាល Quality Graduates: Standards and Action, Innovation Pedagogy សម្រាប់គ្រូបង្រៀនវ័យក្មេង និងការពង្រឹងសមត្ថភាពក្រុម IQA/កម្មវិធី ។

៧.២ ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ និងនវានុវត្តន៍

- ក្រោម HEIP2 សាកលវិទ្យាល័យបានផ្តោតលើការពង្រឹងប្រព័ន្ធគ្រប់គ្រងស្រាវជ្រាវទាំងមូល រួមមាន ការសម្រប សម្រួលស្រាវជ្រាវ ការគ្រប់គ្រងឯកសារ ក្រមសីលធម៌ និងសុចរិតភាពស្រាវជ្រាវ យន្តការថវិកាស្រាវជ្រាវផ្ទៃក្នុង និងហេដ្ឋារចនាសម្ព័ន្ធមន្ទីរពិសោធន៍។
- បានអនុវត្ត និងតាមដានគម្រោង Research Investment និង Further Support ដោយភ្ជាប់ការអនុវត្ត ទៅនឹង KPI, ការរាយការណ៍វឌ្ឍនភាព និងប្រព័ន្ធព័ត៌មានស្រាវជ្រាវ (PRMIS) រួមទាំងព័ត៌មាន អ្នកស្រាវជ្រាវ មន្ទីរពិសោធន៍ និងគម្រោង។
- គម្រោងស្រាវជ្រាវ HEIP2 បានចាប់ផ្តើមបង្កើតលទ្ធផលដែលភ្ជាប់ការស្រាវជ្រាវការបណ្តុះបណ្តាល ការប្រើប្រាស់ជាក់ស្តែង ដូចជាការស្រាវជ្រាវវារីវប្បកម្ម ការផលិតពូជត្រីមានគុណភាព ការអភិវឌ្ឍ រុក្ខជាតិព្រៃ/ផ្កាលម្អ និងTissue Culture ព្រមទាំងការចូលរួមរបស់និស្សិតថ្នាក់បរិញ្ញាបត្រ និងក្រោយ បរិញ្ញាបត្រ។
- ទិសដៅកំណែទម្រង់គឺ បម្លែងការស្រាវជ្រាវពីការផ្តោតលើសកម្មភាពទៅការផ្តោតលើ លទ្ធផល និង ផលប៉ះពាល់ ដោយជំរុញ Publication, Prototype, IP, Technology transfer, Commercialization និងការភ្ជាប់ជាមួយ វិស័យឯកជន។
- ក្រោមគម្រោង HEIP1 សាកលវិទ្យាល័យបានទទួលការគាំទ្រគម្រោងស្រាវជ្រាវចំនួន ៩ គម្រោង ដែលបានរួមចំណែកពង្រឹងសមត្ថភាពអ្នកស្រាវជ្រាវ ការប្រើប្រាស់មន្ទីរពិសោធន៍ និងការផ្សារភ្ជាប់ លទ្ធផលស្រាវជ្រាវទៅការអនុវត្ត។

៧.៣ ការពង្រឹងអភិបាលកិច្ច និងប្រព័ន្ធទិន្នន័យ

ការធ្វើកំណែទម្រង់បានផ្លាស់ប្តូរទៅរកការគ្រប់គ្រងផ្អែកលើភស្តុតាង និងទិន្នន័យ ដោយពង្រឹង IQA, M&E និងប្រព័ន្ធព័ត៌មានគ្រប់គ្រង សម្រាប់ការតាមដានលទ្ធផលកម្មវិធីសិក្សា ការស្រាវជ្រាវ និងធនធានមនុស្ស។

៧.៤ ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធអប់រំ–ស្រាវជ្រាវ និងការភ្ជាប់ឧស្សាហកម្ម

- ក្នុងរយៈពេលកន្លងមក ស.វ.ភ.ក បានសាងសង់ និងកែលម្អមន្ទីរពិសោធន៍/បន្ទប់អនុវត្តសរុប ៤១ កន្លែង។ តាមរយៈ HEIP1 បានគាំទ្រការសាងសង់អគារពហុមុខងារ ១ ខ្នង និងអន្តេវាសិកដ្ឋាន ២ ខ្នងព្រមទាំងការ ស្តារ/កែលម្អ និងបំពាក់សម្ភារៈមន្ទីរពិសោធន៍។
- HEIP2 បន្តអភិវឌ្ឍ Complex Building 2, Fish Hatchery Building និង Industrial Linkage Center ដើម្បីគាំទ្រការបណ្តុះបណ្តាល ការស្រាវជ្រាវអនុវត្ត ការផ្ទេរបច្ចេកវិទ្យា និងការភ្ជាប់ជាមួយ វិស័យឧស្សាហកម្ម។

៨. ធនធានមនុស្ស

ធនធានមនុស្សជាកត្តាស្នូលក្នុងការអនុវត្តបេសកកម្មរបស់សាកលវិទ្យាល័យលើការអប់រំ ការស្រាវជ្រាវ នវានុវត្តន៍ និងសេវាសង្គម។ ក្នុងរយៈពេលឆ្នាំ ២០២៣–២០២៥ ចំនួនមន្ត្រី និងបុគ្គលិកពេញម៉ោងបានកើន ពី ៤៣១ នាក់ នៅឆ្នាំ២០២៣ ដល់ ៤៦៧ នាក់ នៅឆ្នាំ២០២៥។ ទន្ទឹមនឹងនេះ សាកលវិទ្យាល័យក៏បន្តប្រើ ប្រាស់គ្រូបង្រៀនវេលាកាល ដើម្បីបំពេញបន្ថែមជំនាញឯកទេស និងតម្រូវការបង្រៀនតាមកម្មវិធីសិក្សា។

តារាងទី ៨៖ ស្ថិតិធនធានមនុស្សរបស់សាកលវិទ្យាល័យ ឆ្នាំ២០២៣–២០២៥

លរ	ប្រភេទមន្ត្រីនិងបុគ្គលិក	2023		2024		2025	
		សរុប	ស្ត្រី	សរុប	ស្ត្រី	សរុប	ស្ត្រី
	សរុបមន្ត្រីក្របខ័ណ្ឌនិងបុគ្គលិកពេញម៉ោង	**431**	**172**	**459**	**192**	**467**	**186**
១	មន្ត្រីក្របខ័ណ្ឌ	163	52	147	47	138	45
២	គ្រូបង្រៀន	145	45	144	47	146	50
៣	បុគ្គលិកកិច្ចសន្យាក្របខ័ណ្ឌមុខងារសាធារណៈ	25	16	25	12	23	11
៤	បុគ្គលិកកិច្ចសន្យាក្របខ័ណ្ឌសាកលវិទ្យាល័យ	98	59	143	86	160	80
៥	គ្រូវេលាកាល	112	9	111	11	112	112

៩. សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេល ១០ ឆ្នាំកន្លងមក សាកលវិទ្យាល័យភូមិន្ទកសិកម្មសម្រេចបានវឌ្ឍនភាពសំខាន់ៗលើការ បណ្តុះបណ្តាលធនធានមនុស្ស ការស្រាវជ្រាវ និងនវានុវត្តន៍ កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ ការអភិវឌ្ឍធនធានមនុស្ស ព្រមទាំងការកែលម្អអភិបាលកិច្ច និងហេដ្ឋារចនាសម្ព័ន្ធអប់រំស្រាវជ្រាវ។ សមិទ្ធផល ទាំងនេះបានរួម ចំណែកពង្រឹងគុណភាព និងភាពពាក់ព័ន្ធនៃការអប់រំ និងការស្រាវជ្រាវ ជាមួយតម្រូវការអភិវឌ្ឍ វិស័យកសិកម្ម សេដ្ឋកិច្ច និងសង្គម។

ឆ្ពោះទៅមុខ ស.វ.ក.ក នឹងបន្តអនុវត្តយុទ្ធសាស្ត្រ២០២១-២០៣០ ដោយផ្តោតលើការកែលម្អកម្មវិធីសិក្សាផ្អែកលើលទ្ធផលការពង្រឹងសមត្ថភាពស្រាវជ្រាវនិងនវានុវត្តន៍ការប្រើប្រាស់ទិន្នន័យសម្រាប់ការគ្រប់គ្រង ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងមន្ទីរពិសោធន៍ឱ្យមានប្រសិទ្ធភាពនិងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយ ដៃគូអភិវឌ្ឍន៍ ស្ថាប័នសិក្សា ស្រាវជ្រាវ និងវិស័យឯកជន ដើម្បីបង្កើនផលជះវិជ្ជមាន និងនិរន្តរភាពរបស់សាកល វិទ្យាល័យ។

ឧបសម្ព័ន្ធ៦៖សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ



យោយការណ៍ទស្សនាវរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
រយៈពេល១០ឆ្នាំ ២០១៦-២០២៦

I. ទស្សនាវឧត្តមសិក្ខា

លទ្ធផលនៃការអនុវត្តគម្រោងកែលម្អការអប់រំឧត្តមសិក្សាទី២ ២០២៥-២០៣០

១. ទស្សនៈវាងនៃការអនុវត្តគម្រោង

សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ហៅកាត់ ស.ភ.វ.ស. បានចូលរួមអនុវត្តគម្រោងកែលម្អការអប់រំឧត្តមសិក្សាទី២ ចាប់ពីឆ្នាំ ២០២៥-២០៣០ ក្នុងទឹកប្រាក់ ១,៥៤១,៥១៧.៨៦ ដុល្លាអាមេរិក។ សកម្មភាពចម្បងៗដែល ស.ភ.វ.ស. ធ្វើការអនុវត្តរួមមាន៖ ១. ការកែលម្អគុណភាព និងភាពឆ្លើយតបនៃកម្មវិធីអប់រំជាមួយនឹងថវិកាសរុប ១,៣២៥,១៩៦.៨៦ ដុល្លាអាមេរិក និង ២. ការពង្រឹងអភិបាលកិច្ច ស្ថាប័នដែលមានថវិកាអនុវត្តចំនួន ២១៦,៣៧៥.០០ ដុល្លាអាមេរិក។

១.១. ការកែលម្អគុណភាព និងភាពឆ្លើយតបនៃកម្មវិធីអប់រំ

ស.ភ.វ.ស. បានសម្រេចយកកម្មវិធីចំនួន ៤ រួមមាន៖ ១. កម្មវិធីសិក្សាបរិញ្ញាបត្រ ស្ថាបត្យកម្ម និងនគរោបនីយវិទ្យា ២. កម្មវិធីសិក្សាបរិញ្ញាបត្របុរាណវិទ្យា ៣. កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ស្ថាបត្យកម្ម និងនគរោបនីយវិទ្យា និង៤. បរិញ្ញាបត្រជាន់ខ្ពស់បុរាណវិទ្យា និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ មកធ្វើការកែលម្អ និងធ្វើទំនើបកម្មកម្មវិធីសិក្សាឱ្យស្របតាមក្របខណ្ឌអប់រំអនាគតផលសម្រាប់ការអប់រំផ្អែកលើលទ្ធផលនៅឧត្តមសិក្សាកម្ពុជា។ ក្រៅពីកម្មវិធីសិក្សាស្នូលទាំងបួន ស.ភ.វ.ស. នឹងធ្វើទំនើបកម្មកម្មវិធីសិក្សាជាមួយកម្មវិធីចំនួន ៣ ផ្សេងទៀតក្រោមថវិកាផ្ទាល់របស់សាកលវិទ្យាល័យ រួមមាន៖ ១. កម្មវិធីបរិញ្ញាបត្រគុបតែងលម្អស្ថាបត្យកម្ម ២.កម្មវិធីបរិញ្ញាបត្រតែងនិពន្ធ និង៣. កម្មវិធីបរិញ្ញាបត្រតន្ត្រីបុរាណ។

ចាប់តាំងពីដើមឆ្នាំ ២០២៥ ស.ភ.វ.ស. បានអនុម័តសេចក្តីសម្រេចចំនួន ២ គឺបង្កើតក្រុមបច្ចេកទេសការធ្វើទំនើបកម្មកម្មវិធីសិក្សាស្របតាមក្របខណ្ឌអនាគតផល សម្រាប់ការអប់រំផ្អែកលើលទ្ធផលនៅឧត្តមសិក្សាកម្ពុជា កម្រិតកម្មវិធីមហាវិទ្យាល័យស្ថាបត្យកម្ម និងនគរោបនីយវិទ្យា និងកម្មវិធីមហាវិទ្យាល័យបុរាណវិទ្យា។

ក្រុមការងារបច្ចេកទេសទាំងពីរ បានធ្វើការងារយ៉ាងសកម្មលើដំណើរការនៃការធ្វើទំនើបកម្មវិធី ហើយកម្មវិធីបរិញ្ញាបត្រស្ថាបត្យកម្មនិងនគរោបនីយវិទ្យាបានបញ្ចប់រួចរាល់ និងចេញរបាយការណ៍នៃ Need

Analysis របស់កម្មវិធីសិក្សា បានបញ្ចប់ PEO, PLO និង CLO។ ក្រុមការងារបច្ចេកទេសនៃការធ្វើទំនើបកម្ម កម្មវិធីបរិញ្ញាបត្រស្តាបត្យកម្ម និងនគរោបនីយវិទ្យា បានដាក់ការពិនិត្យ និងសម្រេចនៃកម្មវិធីសិក្សាដែលបានធ្វើទំនើបកម្មកម្មវិធីសិក្សាជាមួយគណៈកម្មការគរុកោសល្យរបស់មហាវិទ្យាល័យស្តាបត្យកម្ម និងនគរោប-នីយវិទ្យា និងបន្តការដាក់ជូនទៅក្រុមប្រឹក្សាគរុកោសល្យសាកលវិទ្យាល័យ និងចុងក្រោយក្រុមការងារបច្ចេកទេស ក៏ដូចជាថ្នាក់ដឹកនាំសាកលវិទ្យាល័យបានយកកម្មវិធីសិក្សារបស់ស្តាបត្យកម្ម និងនគរោបនីយវិទ្យាដែលបានធ្វើទំនើបកម្មទៅបង្ហាញ និងស្នើសុំធាតុចូលពីគណៈស្តាបត្យករកម្ពុជា។ លើសពីនេះទៀត ក្រុមការងារបច្ចេកទេសបានបណ្តុះបណ្តាលគ្រូបង្រៀនឱ្យរៀបចំ CLO ចំនួន២ លើក ដែលលទ្ធផលទទួលបានគ្រូបង្រៀនបានរៀបចំ CLO បានចំនួន ២៥ ក្នុងចំនួន ៦៩ CLO ហើយមាន CLO ចំនួន ២ ដែលបានរៀបចំរួចរាល់ជាមួយសម្ភារបង្រៀន និងរៀន។ កម្មវិធីសិក្សាថ្មីរបស់កម្មវិធីស្តាបត្យកម្ម និងនគរោបនីយវិទ្យានឹងដាក់ឱ្យអនុវត្តនៅឆ្នាំសិក្សា ២០២៦-២០២៧ សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងឆ្នាំទី២។ ដោយឡែកការធ្វើទំនើបកម្មកម្មវិធីសិក្សាបុរាណវិទ្យា ក្រុមការងារបច្ចេកទេស បានដឹកនាំធ្វើ Need Analysis និងបានបញ្ចប់ PEO និង PLO ត្រៀមរៀបចំសិក្ខាសាលាសម្រាប់ CLO ជាមួយគ្រូបង្រៀនក្រោមជំនួយបច្ចេកទេស និងការផ្តល់ការប្រឹក្សាពីក្រុមការងារបច្ចេកទេសរបស់កម្មវិធីស្តាបត្យកម្ម និងនគរោបនីយវិទ្យា។

លើសពីនេះទៀត ស.ភ.វ.ស. បានផ្តល់វគ្គសិក្ខាសាលាអំពីការធ្វើទំនើបកម្មកម្មវិធីសិក្សាស្របតាមក្របខណ្ឌអនាគតផល សម្រាប់ការអប់រំផ្អែកលើលទ្ធផលនៅឧត្តមសិក្សាកម្ពុជាដល់មហាវិទ្យាល័យ ៣ ផ្សេងទៀតដែលមិនស្ថិតក្នុងគម្រោងនាឆ្នាំ ២០២៥ ហើយចាប់ផ្តើមពង្រឹងការអនុវត្តនៃការធ្វើទំនើបកម្មកម្មវិធីសិក្សារបស់ខ្លួនតាមរយៈវគ្គបណ្តុះបណ្តាលនាខែកញ្ញា ២០២៦។

ក្រៅពីការធ្វើទំនើបកកម្មវិធីសិក្សា ស.ភ.វ.ស. បានរៀបចំធ្វើទំនើបកម្មបណ្ណាល័យតាម រយៈការកែលម្អរចនាសម្ព័ន្ធរូបវន្តបណ្ណាល័យ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្ណាល័យ។ បច្ចុប្បន្ននេះ គម្រោងប្តង់នៃការកែលម្អរចនាសម្ព័ន្ធរូបវន្តបណ្ណាល័យ បានដាក់ដេញថ្លៃ និងបានជ្រើសក្រុមហ៊ុនផ្តល់សេវាកម្មរួចរាល់ ចំពោះប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្ណាល័យកំពុងអនុវត្ត និងត្រូវបញ្ចប់ប្រព័ន្ធនេះនៅខាងតុលាខាងមុខ។

បន្ថែមពីនេះទៀត គម្រោងសំណង់អាគារសិល្បៈសូនរូបកំពុងស្ថិតនៅក្នុងដំណាក់កាលនៃការគូរប្តង់បន្ទាប់ពីទទួលបានការឯកភាពលើតម្លៃប្រែប្រួលនៃគម្រោងប្តង់ពីតម្លៃជាង១៤ ម៉ឺនដុល្លា អាមេរិក មកតម្លៃជាង ១៩ ម៉ឺនដុល្លារអាមេរិក។

១.២. ការពង្រឹងអភិបាលកិច្ចស្ថាប័ន

- **ការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង (IQA)៖** នាខែមេសា ឆ្នាំ ២០២៦ ស.ភ.វ.ស.បានចេញសេចក្តីសម្រេចនៃការបង្កើតគណៈកម្មការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង អនុគណៈកម្មការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងទាំង៥ ផ្នែកវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង និងក្រុមស្វ័យវាយតម្លៃពី៥មហាវិទ្យាល័យ។ ក្រុមការងារស្នូលដែលទទួលបានការបណ្តុះបណ្តាល ពីអគ្គនាយកដ្ឋានឧត្តមសិក្សា បានរៀបចំសិក្ខាសាលាតម្រង់ទិស និងរៀបចំផែនការសកម្មភាពស្តីពីការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងជូនដល់សមាជិកនៃគណៈកម្មការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង អនុគណៈកម្មការវាយតម្លៃគុណភាព

អប់រំផ្នែកក្នុង ផ្នែកវាយតម្លៃគុណភាពអប់រំផ្នែកក្នុង និងក្រុមស្វ័យវាយតម្លៃគុណភាពផ្នែកក្នុងនាខែ មិថុនា ឆ្នាំ ២០២៦។

- **ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា (Tracer Study)៖** ស.ភ.វ.ស.បានរៀបចំ និងបញ្ចប់របាយការណ៍នៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សារយៈពេលមួយឆ្នាំ នៃឆ្នាំសិក្សា ២០២៣-២០២៤ កាលពីខែមេសា ឆ្នាំ ២០២៦ ។ របាយការណ៍នេះបានផ្សព្វផ្សាយជូនថ្នាក់ដឹកនាំក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំនាខែឧសភា ឆ្នាំដដែរ។ បច្ចុប្បន្ននេះ ក្រុមការងារ Tracer Study បានបញ្ចប់ការពិភាក្សាទៅលើកម្រងសំណួរជាមួយមហាវិទ្យាល័យពាក់ព័ន្ធ នឹងកំពុងប្រមូលទិន្នន័យនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សារយៈពេល ១ ឆ្នាំ នៃឆ្នាំសិក្សា ២០២៤-២០២៥ និង រយៈពេល ៣ ឆ្នាំ នៃឆ្នាំសិក្សា ២០២២-២០២៣ នាខែសីហា និងកញ្ញា ឆ្នាំ ២០២៦។
- **ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ៖** កិច្ចលទ្ធកម្មបានបញ្ចប់ការដេញថ្លៃទំនិញនៃការផ្គត់ផ្គង់ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ។ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ (QuickBooks online system) អ្នកផ្គត់ផ្គង់បានរៀបចំ chart account ផ្អែកលើភាពចាំបាច់ និងតម្រូវការរបស់ស.ភ.វ.ស. ហើយផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីការិយាល័យគណនេយ្យក្នុងការប្រើប្រាស់ប្រព័ន្ធ។ ចំពោះប្រព័ន្ធគ្រប់គ្រងធនធានមនុស្សក្រុមការងារនៃការិយាល័យធនធានមនុស្សបានជួបពិភាក្សាជាមួយអ្នកផ្គត់ផ្គង់អំពីតម្រូវចាំបាច់ (customize) នានារបស់ស.ភ.វ.ស. នាពេលបច្ចុប្បន្ននេះ ការរៀបចំប្រព័ន្ធកំពុងបន្តដំណើរការ និងពិនិត្យមើលដោយក្រុមការងារការិយាល័យគ្រប់គ្រងធនធានមនុស្ស។

៣. បញ្ហាប្រឈម

២.១. ការកែលម្អគុណភាព និងភាពឆ្លើយតបនៃកម្មវិធីអប់រំ

- ដោយសារគោលការណ៍ណែនាំចំនួន ៣ (Program Modernization, Innovative Pedagogy, and Holistic Assessment) គឺបានបោះពុម្ពផ្សាយជាភាសាអង់គ្លេស ដែលមានភាពពិបាកដល់លោកគ្រូអ្នកគ្រូក្នុងការសិក្សារៀនសូត្រ ក៏ដូចជាការអនុវត្តទៅតាមវិធីសាស្ត្រដែលមានចែងក្នុងគោលការណ៍ណែនាំទាំង៣ នេះ។ លើសពីនេះទៀត លោកគ្រូ អ្នកគ្រូមានពេលវេលាមិនគ្រប់គ្រាន់ក្នុងការចាប់យកទស្សនៈទាននៃ OBE។ ម្យ៉ាងវិញទៀតគ្រូបង្គោលOBE មានចំនួនតិចដែលបានទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាល ពី DGHE ដែលធ្វើឱ្យមន្ត្រីដែលចូលរួមក្នុងគម្រោងប្រើប្រាស់ថាមពលលើសលុបក្នុងការដឹកនាំកែលម្អកម្មវិធីសិក្សា និងពង្រឹងសមត្ថភាពបន្តជូនដល់ មន្ត្រី និងលោកគ្រូ អ្នកគ្រូកម្មវិធីក្នុងការរៀបចំ CLO ឱ្យបានទាន់ពេលវេលានៃការអនុវត្ត។ ឆ្លើយតបទៅនឹងបញ្ហាដែលកំពុងប្រឈម ក្រុមការងារបានសំណូមពរទៅកាន់ DGHE សូមធ្វើការបកប្រែសៀវភៅគោលការណ៍ទាំង ៣ មកជាភាសាខ្មែរ ។ បន្ថែមពីនេះទៀត ដើម្បីរក្សាមន្ត្រីសកម្មដែលបានចូលរួមចំណែកក្នុងការកែលម្អកម្មវិធីសិក្សា ថ្នាក់ដឹកនាំរបស់មហាវិទ្យាល័យក៏ដូចជាសាកលវិទ្យាល័យមានយន្តការលើកទឹក

ចិត្តដោយផ្តល់ម៉ោងបង្រៀនបន្ថែម និងទទួលយកជាមន្ត្រីកិច្ចសន្យាផ្នែកក្នុងតាមលទ្ធភាពដែលសាកលវិទ្យាល័យមាន។

២.២. ការពង្រឹងអភិបាលកិច្ចស្ថាប័ន

- ទោះបីជាយើងមានបទពិសោធន៍ក៏ដូចជារៀបចំផែនការសកម្មភាពនិងស្នើសុំកិច្ចសហការជាមួយមហាវិទ្យាល័យយ៉ាងណាក៏ដោយ ការប្រមូលទិន្នន័យនៃការសិក្សាអំពីស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សារយៈពេល ១ ឆ្នាំ និងក្រោយរយៈពេល ៣ ឆ្នាំនៅតែជាបញ្ហាប្រឈមដដែរ ព្រោះចំនួនអ្នកដែលចូលរួមឆ្លើយតបគឺមិនទាន់គ្រប់ទៅតាមតម្រូវការដែលបានកំណត់ទុកនៅក្នុងគោលការណ៍ណែនាំនៃការសិក្សានិស្សិតក្រោយបញ្ចប់ការសិក្សាដែរ។ ដើម្បីដោះស្រាយបញ្ហានេះ ក្រុមការងារបានពន្យាពេលនៃការប្រមូលទិន្នន័យរហូតដល់បញ្ចប់ខែកញ្ញា ហើយក៏សំណូមពរដល់មហាវិទ្យាល័យដែលជាម្ចាស់កម្មវិធីជួយជំរុញឱ្យនិស្សិតដែលបានបញ្ចប់ការសិក្សាចូលរួមក្នុងការស្ទង់មតិផងដែរ។

៣. ទិសដៅបន្ត

៣.១. ការកែលម្អគុណភាព និងភាពឆ្លើយតបនៃកម្មវិធីអប់រំ

- កម្មវិធីសិក្សាស្តាបត្យកម្ម និងនគរោបនីយវិទ្យាកម្រិតបរិញ្ញាបត្រដែលបានធ្វើទំនើបកម្មរួច នឹងដាក់ឱ្យដំណើរការអនុវត្តក្នុងឆ្នាំសិក្សា ២០២៦-២០២៧ ចំពោះថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងថ្នាក់ឆ្នាំទី ២ បន្ទាប់មក ក្រុមការងារបច្ចេកទេសរបស់មហាវិទ្យាល័យនឹងធ្វើការផ្ទៀងផ្ទាត់នៃការអនុវត្តកម្មវិធីសិក្សានាត្រីមាសទី ៤ ឆ្នាំ ២០២៧ ក្នុងគោលបំណងធ្លុះបញ្ចាំងនិងកែលម្អនូវចំណុះខ្វះខាតឱ្យមានភាពប្រសើរឡើង។ ចំពោះកម្មវិធីសិក្សាស្តាបត្យកម្ម និងនគរោបនីយវិទ្យាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ក្រុមការងារនឹងចាប់ផ្តើមពិភាក្សាក្នុងការរៀបចំកម្រងសំណួរនៃ Market Need Analysis នឹងរៀបចំផែនការចុះប្រមូលទិន្នន័យ។
- កម្មវិធីសិក្សាបុរាណវិទ្យាកម្រិតបរិញ្ញាបត្រនឹងត្រូវដាក់ឱ្យដំណើរការអនុវត្តនាឆ្នាំសិក្សា ២០២៧-២០២៨ សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន។ ដោយឡែកសម្រាប់កម្មវិធីសិក្សាបុរាណវិទ្យា និងគ្រប់គ្រងបេតិកណ្ឌវប្បធម៌កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ក្រុមការងារធ្វើទំនើបកម្មវិធីនឹងចាប់ផ្តើមរៀបចំធ្វើ Market Need Analysis នៅត្រីមាសទី ៤ នៃឆ្នាំ ២០២៦។
- ការជួសជុលកែលម្អ និងធ្វើទំនើបកម្មបណ្ណាល័យនឹងចាប់ផ្តើមដំណើរនៅត្រីមាសទី ៤ នៃឆ្នាំ ២០២៦ បន្ទាប់ពីដំណើរការដេញថ្លៃ និងចុះកិច្ចសន្យាជាមួយអ្នកផ្តល់សេវាកម្មរួចរាល់នៅខែកញ្ញា។
- ចំពោះការរៀបចំរចនាប្លង់នៃគម្រោងអាគារសិល្បៈសូនរូបនឹងត្រូវបញ្ចប់ក្នុងត្រីមាសទី ៣ ជាមួយនឹងការសិក្សា Environmental and safeguarding ដែលអាចរៀបចំដាក់ដេញថ្លៃនៅដើមឆ្នាំ ២០២៧។

៣.២. ការពង្រឹងអភិបាលកិច្ចស្ថាប័ន

- **ការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង (IQA)៖** ក្រុមការងារនឹងផ្តល់វគ្គបណ្តុះបណ្តាលអំពីរបៀបសរសេរ SAR ដល់ក្រុមការងារស្វ័យវាយតម្លៃមកពី ៥ មហាវិទ្យាល័យនៅក្នុងត្រីមាសទី ៤ នៃឆ្នាំ ២០២៦ បន្ទាប់ពីទទួលបានវគ្គបណ្តុះបណ្តាលពីរបៀបសរសេរ SAR ពីក្រុមការងារ DGHE។
- **ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា (Tracer Study)៖** ក្រុមការងារនឹង ពន្លឿនការប្រមូលទិន្នន័យនៃការស្ទង់មតិពីនិស្សិតបញ្ចប់ការសិក្សាក្នុងរយៈពេលមួយឆ្នាំ និង រយៈពេលបីឆ្នាំ ដើម្បីធ្វើការវិភាគ និងរៀបចំរបាយការណ៍ត្រឹមបំណាច់ខែធ្នូ ឆ្នាំ២០២៦។
- **ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ៖** ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សនឹងត្រូវបញ្ចប់ និងដាក់ឱ្យដំណើរការនៅដើមត្រីមាសទី ៤ នៃឆ្នាំ ដោយមានភ្ជាប់នូវការស្កេនមេដៃសម្រាប់វត្តមាន និងការគិតប្រាក់ម៉ោងបង្រៀនសម្រាប់មន្ត្រីក៏ដូចជាគ្រូ បង្រៀន។ ចំណែកប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក៏ដាក់ឱ្យប្រើប្រាស់ផ្លូវការនៅត្រីមាសទី ៤ នៃឆ្នាំ ២០២៦ ផងដែរ។

២.កម្មវិធីសិក្សា និងការបណ្តុះបណ្តាលជំនាញដេប៉ាតឺម៉ង់ភាសា

សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈបានបង្កើតដេប៉ាតឺម៉ង់ភាសាឆ្នាំ២០១៥ដើម្បីគ្រប់គ្រងនិងសម្របសម្រួលកិច្ចការបង្រៀនភាសាបារាំងជាពិសេសសម្រាប់និស្សិតដែលត្រូវចូលរៀនកម្មវិធីមូសុងនៃគម្រោងមនុស្សសាស្ត្រ។ សាកលវិទ្យាល័យភូមិន្ទវិចិត្រជាសមាជិកនៃបណ្តាញគ្រឹះស្ថាន ឧត្តមសិក្សាដែលប្រើប្រាស់ភាសាបារាំងរបស់AUF ក្នុងនាមជាសមាជិក ស.ភ.វ.ស តែងតែខិតខំប្រឹងប្រែងលើកកម្ពស់ការរៀននិងការបង្រៀន ភាសាបារាំង។

និស្សិតដែលជ្រើសរើសរៀនភាសាបារាំងភាគច្រើនមានបំណងចង់បន្តការសិក្សានៅប្រទេសបារាំងឬប្រទេសប្រើប្រាស់ភាសាបារាំងលើកលែងតែនិស្សិតផ្នែកបុរាណវិទ្យាដែលតម្រូវឱ្យរៀនភាសាបារាំងក្នុងគោលបំណងជំរុញឱ្យពួកគាត់អាចចូលរៀនកម្មវិធីមូសុងបាននៅវិស្សមកាលឆ្នាំទី២។

វឌ្ឍនភាព

នៅឆ្នាំសិក្សា២០២២-២០២៣ ចំនួននិស្សិតដែលជ្រើសរើសភាសាបារាំងមានការកើនជាងឆ្នាំមុន។ ដោយសារមានការចុះផ្សព្វផ្សាយព័ត៌មានអំពីប្រយោជន៍នៃការរៀនភាសាបារាំងនៅតាមថ្នាក់នីមួយៗដែលបានអាក់ខានអំឡុងពេលវិបត្តិកូវីដ។

កម្រិតបរិញ្ញាបត្រ

	២០១៨-២០១៩	២០១៩-២០២០	២០២០-២០២១	២០២១-២០២២	២០២២-២០២៣
ឆ្នាំទី ១	២៦១	៣០៩	៣១៥	២៥៤	២៨០
ឆ្នាំទី ២	៧១	៧៨	៩៣	៨៣	៥០
ឆ្នាំទី ៣	២៣	៤០	២៩	៤៥	១៣
ឆ្នាំទី ៤	១៧	១៦	២០	១៩	១៣

ឆ្នាំទី ៥	០	៦	១១	៤	៤
សរុប	២៧២	៤៤៩	៤៦៨	៤០៥	៣៦០

បញ្ហាប្រឈម

- បច្ចុប្បន្នស្ថិតិនិស្សិតសិក្សាភាសាបារាំងមានការថយចុះ
- អត្រាអាហារូបករណ៍និស្សិតទៅរៀនបន្តនៅប្រទេសបារាំង និងបណ្តាលប្រទេសប្រើប្រាស់ភាសាបារាំងមានការថយចុះ

ដំណោះស្រាយ

- បង្កើនកិច្ចសហការជាមួយគ្រិះស្ថានឧត្តមសិក្សាភាសាបារាំងដើម្បីផ្តល់ឱកាសឱ្យនិស្សិតទទួលបានអាហារូបករណ៍ទៅបន្តការសិក្សានៅប្រទេសបារាំង ឬប្រទេសប្រើប្រាស់ភាសាបារាំង
- ជំរុញឱ្យនិស្សិតខិតខំរៀនភាសាបារាំងបន្ថែមដើម្បីបង្កើនសមត្ថភាពភាសាបារាំងឱ្យកាន់តែមានគុណភាព
- បង្កើនថ្នាក់ភាសាបារាំងដើម្បីបំប៉នបន្ថែមដល់និស្សិត
- បន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការសិក្សាភាសាបារាំង តាមរយៈការធ្វើវីដេអូខ្លីៗបីនិស្សិតដែលបានសិក្សាចប់ពីបរទេស ឬកំពុងសិក្សានៅក្រៅប្រទេស

គម្រោងមនុស្សសាស្ត្រ៖ របាយការណ៍អនុវត្តការងារផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស

គម្រោងមនុស្សសាស្ត្រ ត្រូវបានបង្កើតឡើងដោយវិទ្យាស្ថាន INALCO និង IRD ក្នុងកិច្ចសហការជាមួយសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នៃប្រទេសកម្ពុជាតាំងពីឆ្នាំ២០១៤។

គោលដៅនៃគម្រោង គឺពង្រឹងការបណ្តុះបណ្តាល និងការស្រាវជ្រាវផ្នែកមនុស្សសាស្ត្រនៅក្នុងប្រទេសកម្ពុជា និងនៅអាស៊ីអាគ្នេយ៍ តាមរយៈកម្មវិធីបង្រៀនយ៉ាងយកចិត្តទុកដាក់ ដោយប្រើភាសាបារាំងជាភាសាយាន (សាកលវិទ្យាល័យមូសុង)។ កម្មវិធីបន្ថែមនេះ ផ្តល់នូវការបង្រៀនពហុជំនាញ ទាំងទ្រឹស្តី និងវិធីសាស្ត្រ ក្នុងវិស័យមនុស្សសាស្ត្រ ដល់និស្សិតដែលកំពុងរៀនថ្នាក់បរិញ្ញាបត្របុរាណវិទ្យានៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈដល់និស្សិតមកពីដេប៉ាតឺម៉ង់សិក្សាភាសាបារាំងនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិងដល់គរុនិស្សិតផ្នែកភាសាបារាំងនៃវិទ្យាស្ថានជាតិអប់រំ។ និស្សិតដែលចូលរៀនក្នុងកម្មវិធីនឹងទទួលបានសញ្ញាប័ត្រពីរគឺ សញ្ញាបត្រមួយពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឬវិទ្យាស្ថានជាតិអប់រំ និងមួយទៀតពីវិទ្យាស្ថាន INALCO។

មុខវិជ្ជាសំខាន់ៗដែលបង្រៀនរួមមាន បុរាណវិទ្យា ប្រវត្តិសាស្ត្រ ប្រវត្តិសិល្បៈ នរវិទ្យា សិលាចារឹកវិទ្យា និងភាសាវិទ្យា។

គម្រោងនេះទទួលបានការគាំទ្រពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា។

១. បរិបទ និងការគ្រប់គ្រង

កិច្ចព្រមព្រៀងសហប្រតិបត្តិការឆ្នាំ ២០១៤-២០១៩ បានបង្កើតកិច្ចសហការរវាងស្ថាប័នវិទ្យាសាស្ត្រនានា រួមមាន EFEO, CNRS និង AUF។ កិច្ចព្រមព្រៀងជាបន្តបន្ទាប់ធ្វើឡើងនៅឆ្នាំ ២០១៩-២០២២ និង

២០២២-២០២៧ បានរួមបញ្ចូល CKS, INE, URPP និងស្ថានទូតបារាំងប្រចាំកម្ពុជា ជាដៃគូសហការ ដែលមានគោលដៅធានាដល់ការគ្រប់គ្រងនិងដំណើរការគម្រោង ព្រមទាំងពង្រីកកម្មវិធីសិក្សា។

ការគ្រប់គ្រងគម្រោងមានគណៈកម្មការចំនួនបី៖

១) គណៈកម្មការគ្រប់គ្រង មានតួនាទីត្រួតពិនិត្យ សកម្មភាពនានា
២) ក្រុមប្រឹក្សាវិទ្យាសាស្ត្រ និងគរុកោសល្យ ដើម្បីកំណត់ទិសដៅសិក្សា និងស្រាវជ្រាវ
៣) គណៈកម្មការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ និងរដ្ឋបាល។

២. ការផ្សព្វផ្សាយ និងទំនាក់ទំនង

ក្រុមការងាររបស់យើងបានផ្សព្វផ្សាយគម្រោងនេះនៅក្នុងសាលានានា ជាពិសេសក្នុងថ្នាក់ដែលមានការបង្រៀនជាភាសាខ្មែរ-បារាំង។ គម្រោងមនុស្សសាស្ត្រ ក៏បានបង្ហាញឱ្យមហាជនទូទៅបានស្គាល់តាមរយៈ សន្និសីទអន្តរជាតិ គេហទំព័រ និងទំព័រហ្វេសប៊ុកដែលមានសកម្មភាពជាប្រចាំ។

៣. ផ្នែកអប់រំ៖ សាកលវិទ្យាល័យមូសុង និងបរិញ្ញាបត្រជាន់ខ្ពស់ LLCER

ចាប់ពីឆ្នាំ ២០១២ រហូតដល់ ២០២៤ គម្រោងបានទទួលនិស្សិតចំនួន **២៥៥**នាក់ សម្រាប់**កម្រិតបរិញ្ញាបត្រ**និង **៥៥**នាក់ សម្រាប់បរិញ្ញាបត្រជាន់ខ្ពស់ LLCER របស់ INALCO នៅ URBA។ សាកលវិទ្យាល័យមូសុង ត្រូវបានរៀបចំរៀងរាល់ឆ្នាំក្នុងរយៈពេលបីខែ (កក្កដា-កញ្ញា) ដែលបានផ្តល់ឱកាសសិក្សាសម្រាប់និស្សិតខ្មែរ និងឡាវ។ ចាប់ពីឆ្នាំ ២០១៨ គម្រោងបានកែសំរួលកម្មវិធីសិក្សា ដោយរៀបចំឱ្យមាននិស្សិតខ្មែរម្នាក់ដែលកំពុងរៀនថ្នាក់បណ្ឌិតនៅវិទ្យាស្ថាន INALCO ហើយដែលសុទ្ធតែធ្លាប់ឆ្លងកាត់វគ្គបណ្តុះបណ្តាលក្នុងគម្រោងមនុស្សសាស្ត្រ ឱ្យចូលរួមបង្រៀនអមសាស្ត្រាចារ្យជំនាញក្នុងទិសដៅសម្រួលដល់ការផ្ទេរចំណេះដឹងឱ្យបានកាន់តែប្រសើរឡើង។ បច្ចុប្បន្ន មុខវិជ្ជាភាគច្រើនគឺបង្រៀនដោយអតីតនិស្សិតដែលបានទទួលការបណ្តុះបណ្តាលនៅក្នុងគម្រោងមួយនេះ។ ក្រៅពីការបន្តវេន លោកគ្រូ អ្នកគ្រូទាំងនេះបានជួយសម្រួលបន្ទុកផ្នែកហិរញ្ញវត្ថុបានមួយភាគធំសម្រាប់គម្រោង។

ថ្នាក់**បរិញ្ញាបត្រជាន់ខ្ពស់** បានបង្កើតឡើងនៅឆ្នាំ ២០១៤ ដែលមាន INALCO ជាអ្នកចេញសញ្ញាបត្រតាមរយៈការសិក្សាចំនួនពីរឆ្នាំ ស្របតាមប្រព័ន្ធក្រេឌីត ECTS របស់សហភាពអឺរ៉ុប។ វគ្គបណ្តុះបណ្តាលនេះផ្តោតលើជំនាញផ្សេងៗដែលមានបង្រៀននៅ មហាវិទ្យាល័យបុរាណវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងវិទ្យាស្ថាន INALCO។

៤. ផ្នែកស្រាវជ្រាវ

គម្រោងបានអភិវឌ្ឍផ្នែកស្រាវជ្រាវជាច្រើន ជាពិសេសទាក់ទងនឹងការយល់ដឹងពីអតីតកាល ភាសា និងវប្បធម៌ របស់ជនជាតិខ្មែរ និងបច្ចុប្បន្នភាពនៃអាស៊ីអាគ្នេយ៍។ សន្និសីទអន្តរជាតិត្រូវបានរៀបចំជាបន្តបន្ទាប់ចាប់ពីឆ្នាំ ២០១៤ និងបន្តដោយការបោះពុម្ពផ្សាយអត្ថបទវិទ្យាសាស្ត្រ ដូចជា៖

- Joseph Thach, Nasir Abdoul-Carime et Grégory Mikaelian (éds.), *Le passé des Khmers. Langues, textes, rites*, Berne, Peter Lang, juillet 2016.

- Joseph Thach, Nasir Abdoul-Carime, Éric Bourdonneau et Grégory Mikaelian (éds.), *Temporalités khmères : de près, de loin, entre îles et péninsules*, Bern, Peter Lang, 2021.
- Joseph Thach et H. de Penanros (éds.), *Du temps et de l'aspect dans les langues Approches linguistiques de la temporalité*, Berne, Peter Lang, 2024.

ក្នុងចំណោមការបោះពុម្ពផ្សាយទាំងនេះ អត្ថបទស្រាវជ្រាវភាគច្រើនសរសេរដោយសាស្ត្រាចារ្យខ្មែរ និងបរទេសដែលសុទ្ធតែធ្លាប់បានមកបង្រៀននិស្សិតក្នុងគម្រោងមនុស្សសាស្ត្រ។

៥. ប្រភពហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានសម្ភារៈ

យោងតាមកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខានៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ភាគីទាំងអស់ (ដូចបានរៀបរាប់ខាងលើ) មានកាតព្វកិច្ចចូលរួមចំណែកក្នុងសកម្មភាពផ្សេងៗក្នុងក្របខណ្ឌនៃគម្រោង ក្រោមរូបភាពជាធនធានមនុស្ស ធនធានសម្ភារៈ និងហិរញ្ញវត្ថុដែលមានបញ្ជាក់នៅក្នុងឧបសម្ពន្ធទី ៣ និងទី ៤ នៃកិច្ចព្រមព្រៀង រួមមាន ៖

- ការទទួលបន្ទុកដោយផ្ទាល់លើបេសកកម្មរបស់សាស្ត្រាចារ្យ និង/ឬ លើការចំណាយទាក់ទងនឹងគម្រោង។
- សៀវភៅដែលផ្តល់ជូនក្នុងអំឡុងពេលនៃសកម្មភាពផ្សេងៗរបស់គម្រោងមនុស្សាសាស្ត្រ។ ដៃគូម្ចាស់ជំនួយអាចចូលរួមវិភាគទានក្នុងការអនុវត្តគម្រោង ដោយអនុលោមតាមថវិកាដែលមានភ្ជាប់មកជាមួយ (ឧបសម្ពន្ធទី៤)។

ប៉ុន្តែជាការជាក់ស្តែង ភាគីមួយចំនួន (AUF, ស្ថានទូតបារាំង) បានបញ្ឈប់ការផ្តល់ជំនួយ និងមួយចំនួនទៀត (CKS, INE, URPP) ពុំធ្លាប់បានផ្តល់ជំនួយផ្នែកណាមួយមកដល់គម្រោងទេ។ នៅដើមឆ្នាំ ២០២២ AUF បានផ្តល់ជំនួយហិរញ្ញវត្ថុឡើងវិញ សម្រាប់រយៈពេលពីរឆ្នាំ ប៉ុន្តែជំនួយនេះក៏បានបញ្ចប់ទៅវិញត្រឹមចុងឆ្នាំ ២០២៤។ បច្ចុប្បន្ន គម្រោងបានទទួលជំនួយផ្នែកហិរញ្ញវត្ថុពីវិទ្យាស្ថាន INALCO និងវិទ្យាស្ថាន IRD តែប៉ុណ្ណោះ។ ចំណែក សាលាបារាំងចុងបូព៌ា (EFEO) និងមជ្ឈមណ្ឌលអាស៊ីអាគ្នេយ៍ (CASE) នៅបន្តទទួលបន្ទុកលើផ្នែកបេសកកម្មរបស់សាស្ត្រាចារ្យចំនួនមួយនាក់ក្នុងមួយឆ្នាំមកបង្រៀននៅកម្ពុជា។

ក្រៅពីនោះគឺចាប់ពីដើមឆ្នាំ ២០២០ (ក្រោយពេលដែលលោក Joseph Thach បានបាត់បង់ជីវិតទៅ) សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈជាអ្នករ៉ាប់រងមួយភាគធំលើផ្នែក ធនធានបុគ្គលិកសម្រាប់សម្របសម្រួលកិច្ចការទូទៅ ហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈ ឬបរិក្ខាប្រើប្រាស់។ សាកលវិទ្យាល័យក៏បានរ៉ាប់រងរាល់ការចំណាយទៅលើការរៀបចំដំណើរកម្មសិក្សារបស់និស្សិត ទៅកាន់តំបន់រមណីយដ្ឋាននានា ជារៀងរាល់ឆ្នាំ។ រីឯភាគីបារាំង (វិទ្យាស្ថាន INALCO និង IRD) គឺមានលោក នន់ ដារ៉ា និងលោកស្រី Isabelle Léglise ជាអ្នកគ្រប់គ្រងកិច្ចការរដ្ឋបាលទូទៅនៃគម្រោង ស្វែងរកជំនួយហិរញ្ញវត្ថុ និងសម្របសម្រួលបេសកកម្មគ្រូបង្រៀន។

៦. ការអភិវឌ្ឍន៍ និងទិសដៅអនាគត

តាមរយៈការបណ្តុះបណ្តាលក្នុងក្របខណ្ឌគម្រោងមនុស្សសាស្ត្រ និស្សិតទទួលបានសញ្ញាបត្រអឺរ៉ុប ក្នុង វិស័យវិទ្យាសាស្ត្រមនុស្សសាស្ត្រ ដែលពង្រឹងសមត្ថភាពរបស់ពួកគេឱ្យក្លាយជាអ្នកបន្តវេនបណ្តុះបណ្តាលនាពេលអនាគត។ គម្រោងនេះក៏បានពង្រឹងកិច្ចសហការរវាងបារាំងនិងកម្ពុជា។

ជាគោលដៅទៅថ្ងៃអនាគត សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈមានគោលបំណងផ្លាស់ប្តូរគម្រោងមនុស្សសាស្ត្រមកជាស្ថាប័នមួយពេញលេញ ចំណុះឱ្យមហាវិទ្យាល័យបុរាណវិទ្យា ដោយរក្សាទុករចនាសម្ព័ន្ធឱ្យនៅដដែល (បណ្តុះបណ្តាលនិងស្រាវជ្រាវមនុស្សសាស្ត្រ សង្គមសាស្ត្រ ស្របតាមប្រព័ន្ធអប់រំបារាំង)។ សាកលវិទ្យាល័យនឹងទទួលខុសត្រូវទាំងស្រុងលើស្ថាប័នថ្មីនេះ ទាំងផ្នែកគ្រប់គ្រងរដ្ឋបាល ផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ។ ចំណែកវិទ្យាស្ថាន INALCO និងវិទ្យាស្ថាន IRD នៅតែជាដៃគូចម្បងរបស់សាកលវិទ្យាល័យរាល់កិច្ចសហប្រតិបត្តិការទាំងអស់។

និស្សិតថ្នាក់បណ្ឌិត ដែលត្រូវបញ្ចប់ការសិក្សារបស់ខ្លួនក្នុងពេលឆាប់ៗខាងមុខ នឹងក្លាយទៅជាសាស្ត្រាចារ្យបង្គោលក្នុងការបណ្តុះបណ្តាលនិស្សិត ទាំងថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។ ក្រុមការងារស្រាវជ្រាវក្នុងវិស័យដដែលនេះក៏នឹងត្រូវបង្កើតឡើងតាមរយៈអតីតនិស្សិតទាំងនេះ និងពង្រីកសហប្រតិបត្តិការជាមួយអ្នកស្រាវជ្រាវបរទេសឱ្យកាន់តែទូលំទូលាយ។

៣. បច្ចេកវិទ្យា និងកិច្ចសហប្រតិបត្តិការអន្តរជាតិ

ល.រ	ឈ្មោះគ្រឹះស្ថាន	គោលបំណង	គម្រោងនៃកិច្ចសហប្រតិបត្តិការ	ផ្សេងៗ
ស្ថាប័នក្នុងស្រុក				
	ក្រុមហ៊ុន អ៊ីអន ម៉ល (ខេមបូឌា) ខូអិលធីឌី (ផ្សារទំនើប អ៊ីអន ម៉ល មានជ័យ)	កិច្ចសហប្រតិបត្តិការលើកកំពស់សិល្បៈវប្បធម៌ខ្មែរ	- ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងក្រុមហ៊ុនអ៊ីអនម៉ល (ខេមបូឌា) ខូអិលធីឌី (ផ្សារទំនើបអ៊ីអនម៉លមានជ័យ) ដើម្បីផ្សព្វផ្សាយអំពីសិល្បៈវប្បធម៌ខ្មែរនៅផ្សារទំនើបអ៊ីអនម៉លមានជ័យ។ - សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនឹងរៀបចំក្រុមការងារដែលមានសាស្ត្រាចារ្យដឹកនាំ និងនិស្សិតក្នុងការសម្តែងសិល្បៈប្រពៃណីខ្មែរនៅផ្សារទំនើបអ៊ីអនម៉លមានជ័យ។	ចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០២២ ត្រៀមចុះម្តងទៀតនៅថ្ងៃទី ១៥ ធ្នូ ២០២៤ ចុះទៀតថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០២៦រយៈពេល៣ឆ្នាំ
	សាកលវិទ្យាល័យជាតិបាត់ដំបង	កិច្ចសហប្រតិបត្តិការលើវិស័យបណ្តុះបណ្តាល ស្រាវជ្រាវ និងនវានុវត្តន៍	- សហការ និងចូលរួមផ្តល់ជាតុចូលសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាជំនាញស្ថាបត្យកម្ម និងជំនាញផ្សេងទៀតតាមការចាំបាច់ដើម្បីឱ្យស្របនឹងស្ថានភាពទីផ្សារការងារបច្ចុប្បន្ន និងអនាគត - សហការបណ្តុះបណ្តាលមុខជំនាញស្ថាបត្យកម្មកម្រិតបរិញ្ញាបត្រ និងជំនាញចាំបាច់ផ្សេងទៀត	ចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០២២

			- សហការផ្តល់ធនធានមនុស្ស ជាវាគ្មិនក្នុងកម្មវិធីបណ្តុះបណ្តាល សិក្ខាសាលា វេទិកា ផ្សព្វផ្សាយ និងពិគ្រោះយោបល់ដើម្បីផលប្រយោជន៍រួម - សហការផ្តល់ធនធានសាស្ត្រាចារ្យ គ្រូបង្រៀនដើម្បីពិនិត្យ និងកែលម្អកម្មវិធីសិក្សាលើជំនាញស្តាបត្យកម្ម និងជំនាញផ្សេងទៀត - សហការផ្តល់ធនធានសាស្ត្រាចារ្យ និងគ្រូបង្រៀនតាមការស្នើសុំ - បង្កើតគម្រោងស្រាវជ្រាវរួមគ្នាទាក់ទងនឹងជំនាញស្តាបត្យកម្ម និងជំនាញផ្សេងៗ - ស្ថាប័នទាំងពីរផ្តល់អ្នកតំណាងរបស់ខ្លួន ចូលរួមក្នុងក្រុមប្រឹក្សាគរុកោសល្យសាកលវិទ្យាល័យតាមការចាំបាច់ - សហការក្នុងការបង្កើតគម្រោងសកម្មភាព និងស្វែងរកមូលនិធិ ដើម្បីអភិវឌ្ឍស្ថាប័នទាំងពីរ - ចែករំលែកព័ត៌មានដែលផ្តល់ផលប្រយោជន៍ដល់ស្ថាប័នទៅវិញទៅមក - បង្កើតកម្មវិធីផ្លាស់ប្តូរក្រេឌីតសិក្សាលើមុខវិជ្ជាសំខាន់ៗមួយចំនួនតាមការព្រមព្រៀងគ្នា	

			រវាងសាកលវិទ្យាល័យទាំងពីរ។	
	អង្គការយសោធរ	ចូលរួមចំណែកលើកកម្ពស់ចំណេះដឹង និងការលើកស្ទួយវប្បធម៌ជាតិ	- សកម្មភាពស្រាវជ្រាវរាប់បញ្ចូលទាំងការរុករកឯកសារជាសំណេរផង និងការសិក្សាចុះទៅតាមទឹកដីផង - លទ្ធផលនៃការស្រាវជ្រាវជាកម្មសិទ្ធបញ្ញារួមគ្នា - ផ្សព្វផ្សាយក្រោមរូបភាពធ្វើឡើងរួមគ្នា - រួមគ្នាធ្វើបាឋកថា ឬសន្និសីទ	- ចុះហត្ថលេខាលើកិច្ចព្រមព្រៀងឆ្នាំ ២០១៩(សុពលភាពប្រាំឆ្នាំ) - ចុះហត្ថលេខាឆ្នាំ២០២០ លើគម្រោងកិច្ចសហប្រតិបត្តិការមានឈ្មោះ *បណ្តាញវប្បធម៌ខ្មែរ-KhmeRenaissance*
	សាកលវិទ្យាល័យព្រះសីហនុរាជ	កិច្ចសហប្រតិបត្តិការលើការងារស្រាវជ្រាវ និងការបណ្តុះបណ្តាលធនធានមនុស្ស	- ផ្លាស់ផ្តូរសាស្ត្រាចារ្យ និស្សិត និងអ្នកស្រាវជ្រាវ - សហការលើសកម្មភាពលើការបណ្តុះបណ្តាល ភាសាខ្មែរ បុរាណ សំស្ក្រឹត-បាលី និងសិលាចារឹក - សហការរៀបចំគម្រោងស្រាវជ្រាវអំពីសាស្ត្រាបុរាណ បុរាណវត្ថុ និងបុរាណស្ថាន - សហការរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗទាក់ទៅនឹងនៃមហាវិទ្យាល័យទាំងប្រាំ - ទទួលស្គាល់ប្រព័ន្ធសិក្សាទៅវិញទៅមក	ចុះហត្ថលេខាឆ្នាំ២០១៩ (សុពលភាពប្រាំឆ្នាំ)

			- ផ្លាស់ប្តូរនិស្សិត សាស្ត្រាចារ្យ អ្នកស្រាវជ្រាវសហការលើសកម្មភាពអប់រំ និងបណ្តុះបណ្តាលសហការរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗ។	
	សេចក្តីប្រកាសរបស់សាកលវិទ្យាល័យរដ្ឋទាំង៧ (Magnus 7)	- ទទួលស្គាល់ចំណុចខ្លាំង និងជំនាញឯកទេស - ជឿជាក់លើឋាមពលនៃកិច្ចសហប្រតិបត្តិការ និងកិច្ចពង្រឹងសាមគ្គីភាព	- ជំរុញឱ្យមានវប្បធម៌នៃការអប់រំប្រកបដោយឧត្តមភាព ដើម្បីទទួលបានជោគជ័យ និងបំរើផលប្រយោជន៍សាធារណៈ - ជំរុញឱ្យមានសកម្មភាពរួមគ្នាក្នុងការទទួលខុសត្រូវចំពោះសង្គម និងសហគមន៍ - បង្កើតជាវេទិការដើម្បីផ្លាស់ប្តូរគំនិត និងប្រាជ្ញាក្នុងការចំណេះដឹងសកល	សុពលភាពគិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ (ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩)
	អាជ្ញាធរអប្សរា	កិច្ចសហប្រតិបត្តិការដើម្បីបណ្តុះបណ្តាលធនធានមនុស្សលើវិស័យវប្បធម៌	- បញ្ជូនអ្នកជំនាញឱ្យមកជួយបណ្តុះបណ្តាល និស្សិតនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ - ជួយសម្រួលដល់កម្មសិក្សារបស់និស្សិត និងផ្តល់អ្នកជំនាញដើម្បីធ្វើបទបង្ហាញដល់និស្សិតនៅតាមរមណីយដ្ឋានបុរាណ - អាជ្ញាធរអប្សរាទទួលនិស្សិតដែលបានបញ្ចប់វិញ្ញាប័ត្រជំនាញបុរាណវិទ្យា, ស្ថាបត្យកម្មនិងសិល្បៈសូនរូប	សុពលភាពគិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ

	រាជបណ្ឌិតសភាកម្ពុជា	កិច្ចសហប្រតិបត្តិការផ្តោតសំខាន់លើការពង្រឹងធនធានសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នៅពេលដែលអង្គការ UNESCO ចប់បេសកម្មរបស់ខ្លួន	- បណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកបុរាណវិទ្យាក្រោមការឧបត្ថម្ភពីរដ្ឋាភិបាលជប៉ុន តាមរយៈអង្គការ UNESCO - ផ្តល់សាស្ត្រាចារ្យជួយបណ្តុះ-បណ្តាលធនធានមនុស្សនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ	គម្រោងមានរយៈពេលពីរឆ្នាំ (២០០៥ - ២០០៦) មាននិស្សិតសរុបចំនួន ២៨ រូប។ ស្ថាប័ននៅបន្តធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នារហូតសល់បច្ចុប្បន្ន។
	ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	គោលបំណង ធ្វើងផ្ទាត់ឯកសារ verify.gov.kh រៀបចំប្រព័ន្ធគ្រប់គ្រងសាកល តភ្ជាប់អ៊ីនធឺណិត និងសហការបណ្តុះបណ្តាលផ្នែកឌីជីថល	សាកលវិទ្យាល័យ	កិច្ចព្រមព្រៀងនេះ ចុះហត្ថលេខា នៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០២៣។ សុពលភាព៥ឆ្នាំ
	ក្រុមហ៊ុន AGENT21 GLOBLE.Co,.LTD	កិច្ចសហប្រតិបត្តិការលើកកំពស់ការអប់រំ	ក) លើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរដើម្បីរៀបចំវគ្គអប់រំ បណ្តុះបណ្តាល ចែករំលែកចំណេះដឹងដល់មន្ត្រី សាស្ត្រាចារ្យ និងនិស្សិតរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និង/ឬ បុគ្គលិកក្រុមហ៊ុន AGENT21 GLOBAL Co., LTD.។ ខ)ផ្តល់ឱកាសឱ្យនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈអាចចូលរួមហាត់ការ និង	កិច្ចព្រមព្រៀងនេះ ចុះហត្ថលេខា នៅថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០២៣)។ សុពលភាព៥ឆ្នាំ

			ធ្វើការនៅក្រុមហ៊ុន AGENT21 GLOBAL Co., LTD.។	
	វិទ្យាស្ថានបារាំង	កិច្ចសហប្រតិបត្តិការលើកកំពស់សិល្បៈវប្បធម៌ខ្មែរ	- ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងវិទ្យាស្ថានបារាំង ដើម្បីផ្សព្វផ្សាយអំពីសិល្បៈវប្បធម៌ខ្មែរនៅវិទ្យាស្ថានបារាំង។ - សហការរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗទាក់ទៅនឹងនៃមហាវិទ្យាល័យទាំងប្រាំ - ទទួលនិស្សិតចុះកម្មសិក្សា	កិច្ចព្រមព្រៀងនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ក្នុងរយៈពេល៤ ឆ្នាំ (ចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅថ្ងៃទី១ ខែ វិច្ឆិកា ឆ្នាំ ២០២២)
	Phnom Penh Dance Studio	គោលបំណងផ្តល់អាហារូបករណ៍ដល់និស្សិត កែលម្អសម្ភារបាំ ចូលរួមថវិធ្វើសិក្ខាសាលា, ការប្រជុំ, ការបណ្តុះបណ្តាលរួមគ្នា	ពង្រឹងផ្នែកនាដសាស្ត្រ	កិច្ចព្រមព្រៀងនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ក្នុងរយៈពេល៥ ឆ្នាំ (ចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅថ្ងៃទី១១ ខែ មករា ឆ្នាំ ២០២៤)
	Samdech Rasmi Sobbhana Women Foundation	កិច្ចសហប្រតិបត្តិការលើកកំពស់ការអប់រំ	ផ្តល់អាហារូបករណ៍ដល់និស្សិតស្រីម្នាក់ក្នុងមួយឆ្នាំ	ចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០២៣ មិនមានការផុតសុពលភាព

	ក្រុមហ៊ុន ដីបម៉ុងគ្រុប	កិច្ចសហប្រតិបត្តិការលើកកំពស់ការអប់រំ	ផ្តល់ឱកាសដល់និស្សិតហាត់ការ និងការធ្វើទស្សនកិច្ចសិក្សា	កិច្ចព្រមព្រៀងនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ក្នុងរយៈពេល៣ ឆ្នាំ (ចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅថ្ងៃទី២១ ខែ ឧសភា ឆ្នាំ ២០១៩)
	Cambodia-Korea Arts of Phnom Penh	កិច្ចសហប្រតិបត្តិការលើកកំពស់ការអប់រំ	បញ្ជូនលោកគ្រូ Ryu Ki Yong មកបង្រៀននៅមហាវិទ្យាល័យតូរ្យតន្ត្រី	កិច្ចព្រមព្រៀងនេះ ចុះហត្ថលេខា នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៧) មិនមានថ្ងៃផុតសុពលភាព
	ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	ពង្រឹងសមត្ថភាពអ្នកវិជ្ជាជីវៈនិងបណ្តុះបណ្តាលនិស្សិត	អនុញ្ញាតឱ្យនិស្សិតចុះហាត់ការធ្វើកម្មសិក្សានិងស្រាវជ្រាវនៅក្រសួង	កិច្ចព្រមព្រៀងនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ក្នុងរយៈពេល៣ ឆ្នាំ (ចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅថ្ងៃទី៤ ខែ

				កញ្ញា ឆ្នាំ ២០២៤)
	The Center of Khmer Study	កិច្ចសហប្រតិបត្តិការលើកកំពស់ការអប់រំ និងស្រាវជ្រាវ	ផ្តល់អទិភាពដល់និស្សិតសាកលវិទ្យាល័យក្នុងការចូលរួមកម្មវិធីរបស់CKS រៀបចំសន្និសីទ, សិក្ខាសាលា, ការប្រជុំ, ការបណ្តុះបណ្តាល ការបោះពុម្ព រួមគ្នា	កិច្ចព្រមព្រៀងនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ក្នុងរយៈពេល៥ ឆ្នាំ (ចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ ២០២២)
	ក្រុមហ៊ុន ហ៊ូប៊ីក	សម្រាប់ផ្នែកស្ថាបត្យកម្មនិងរចនា	ផ្តល់ការហាត់ ការប្រលងប្រកួតប្រជែង ផ្លាស់ប្តូរឯកសារបច្ចេកទេស	កិច្ចព្រមព្រៀងនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ក្នុងរយៈពេល២ ឆ្នាំ (ចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ ២០២៥)
	ក្រសួងអប់រំ	កិច្ចព្រមព្រៀងHIEP 2	ការកែលម្អការអប់រំឧត្តមសិក្សា	ចុះហត្ថលេខានៅឆ្នាំ២០២៥
	ទីស្តីការគណៈរដ្ឋមន្ត្រី	សម្រាប់ការស្រាវជ្រាវ	ការបង្កើតបណ្តាញស្រាវជ្រាវកម្ពុជា	ចុះហត្ថលេខានៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០២៦(មាន

				សុពលភាពរយៈពេល៥ឆ្នាំ)
ស្ថាប័នក្រៅស្រុក **ក. ប្រទេសបារាំង**				
	វិទ្យាស្ថានជាតិនៃភាសា និងអារ្យធម៌ Institut National des Langues et Civilisations Orientales (INALCO)	កិច្ចសហប្រតិបត្តិការផ្តោតសំខាន់លើការងារស្រាវជ្រាវ និងគរុកោសល្យ	មហាវិទ្យាល័យបុរាណវិទ្យា៖ - សហប្រតិបត្តិការផ្នែកស្រាវជ្រាវ និងគរុកោសល - ជួយសម្រួលការងារអ្នកស្រាវជ្រាវ គ្រូបង្រៀន និងនិស្សិត - ទទួលគ្រប់គ្រងការបណ្តុះបណ្តាលនិស្សិតក្នុងផ្នែកស្រាវជ្រាវ - សហការបោះពុម្ពលទ្ធផលនៃការស្រាវជ្រាវ - បណ្តុះបណ្តាលនិស្សិតថ្នាក់អនុបណ្ឌិត	គម្រោងនេះបានចាប់ផ្តើមតាំងពីឆ្នាំ ២០១០ បន្តរហូតមកដល់បច្ចុប្បន្ន។ ស្ថាប័នទាំងពីរបានសហការបណ្តុះបណ្តាលនិស្សិត៖ - បរិញ្ញាបត្រ ១១២នាក់ (ឡាវ ៦នាក់ និងបារាំង ៧នាក់) - អនុបណ្ឌិត ២៤នាក់ - បេក្ខជនបណ្ឌិតចំនួន ៦នាក់
	សាកលវិទ្យាល័យប៉ារីសវីត (Université Paris 8)	កិច្ចសហប្រតិបត្តិការផ្តោតលើវិស័យឧត្តមសិក្សានិងការងារស្រាវជ្រាវ	- ដៃគូរសំខាន់ គឺវិស័យសិល្បៈ សូនរូប ក្នុងនោះក៏មានកិច្ចសហប្រតិបត្តិការលើវិស័យផ្សេងៗទៀតដែរ ដូចជា៖ របាំ ល្ខោន និងភាពយន្តជាដើម។ - ការផ្លាស់ប្តូរលើវិស័យអប់រំ, អ្នកស្រាវជ្រាវកំរិតបណ្ឌិត និងក្រោយបណ្ឌិត	សុពលភាពរយៈពេលប្រាំឆ្នាំ គិតចាប់ពីឆ្នាំ ២០០៨

			- កម្មវិធីផ្លាស់ប្តូរនិស្សិត និងមន្ត្រីរាជការ	
	សាលាស្តាបត្យកម្មជាន់ខ្ពស់ប៉ារីសប៊ែលវីល	កិច្ចព្រមព្រៀងមានគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការដើម្បីពង្រឹង និងការអភិវឌ្ឍន៍វិធីសាស្ត្របង្រៀនជាលក្ខណៈវិទ្យាសាស្ត្រ	មានទំនាក់ទំនងជាមួយមហាវិទ្យាល័យទាំងប្រាំនៃសាកលវិទ្យាល័យកូមិន្ទវិចិត្រសិល្បៈ៖ - ស្ថាប័នទាំងពីរធ្វើកិច្ចសហប្រតិបត្តិការដើម្បីបង្កើនការផ្លាស់ប្តូរកម្មវិធីសិក្សា និស្សិត និងសាស្ត្រាចារ្យ - បង្កើនចំណេះដឹងទៅលើគរុកោសល្យបង្រៀនតាមរយៈការផ្លាស់ប្តូរសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ	កិច្ចព្រមព្រៀងបានចុះហត្ថលេខាឆ្នាំ ២០១៤ ចុះម្តងទៀតថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០២២ សុពលភាព ៥ឆ្នាំ
	សាកលវិទ្យាល័យទូលូស	កិច្ចសហប្រតិបត្តិការផ្តោតលើការបង្រៀន និងស្រាវជ្រាវ ដើម្បីពង្រឹងធនធានមនុស្សក្នុងស្ថាប័នទាំងពីរ	ផ្តោតលើមហាវិទ្យាល័យពីរ គឺ មហាវិទ្យាបុរាណវិទ្យា និងមហាវិទ្យាល័យស្ថាបត្យកម្ម និងនគរោបនីយវិទ្យា។ កិច្ចព្រមព្រៀងផ្តោតលើវិស័យអប់រំកំរិតឧត្តមសិក្សាដោយបង្កើតសកម្មភាពជាច្រើនដូចជា៖ ការផ្លាស់ប្តូរនិស្សិត សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវជាដើម។	កិច្ចសហប្រតិ-បតិបត្តិការចាប់ពីឆ្នាំ២០១៦ (សុពលភាពប្រាំឆ្នាំ) ចុះម្តងទៀតថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ ២០២០ សុពលភាព ៣ឆ្នាំ ចុះម្តងទៀតថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៥
	បណ្ណាល័យ BULAC	ផ្លាស់ប្តូរឯកសារស្រាវជ្រាវ	បណ្ណាល័យ	ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៥ដល់ ២០២៦
ខ. ប្រទេសជប៉ុន				
	សាកលវិទ្យាល័យ ក្យូតូ មានបី	ការផ្លាស់ប្តូរគ្នាលើវិស័យបណ្តុះបណ្តាល	មហាវិទ្យាបុរាណវិទ្យា និងមហាវិទ្យាល័យស្ថាបត្យកម្ម និងនគ	កិច្ចសហប្រតិបតិបត្តិការចាប់ពី

	ស្ថាប័ន៖ (មជ្ឈមណ្ឌលស្រាវជ្រាវអំពីអាស៊ីអគ្នេយ៍ មហាវិទ្យាល័យសិក្សាតំបន់អាស៊ី និងអាហ្វ្រិក និងមជ្ឈមណ្ឌលស្រាវជ្រាវអំពីសមាហរណកម្មតំបន់)	និងកិច្ចសហប្រតិបត្តិស្រាវជ្រាវ	រោបនីយវិទ្យា។ កិច្ចព្រមព្រៀងផ្តោតលើវិស័យអប់រំកំរិតឧត្តមសិក្សាដោយបង្កើតសកម្មភាពជាច្រើនដូចជា៖ ការផ្លាស់ប្តូរនិស្សិត សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ។	ឆ្នាំ២០១៦។ ឆ្នាំ ២០២១ ភាគីទាំងពីរបានបន្តកិច្ចព្រមព្រៀងរបស់ខ្លួនប្រាំឆ្នាំបន្តទៀត។
	សាកលវិទ្យាល័យសិល្បៈតូក្យូ	លើកកំពស់វិស័យសិល្បៈ និងបង្កើនសកម្មភាពផ្លាស់ប្តូរវប្បធម៌គ្នាក្នុងតំបន់អាស៊ាន	មហាវិទ្យាល័យសិល្បៈសូនរូប៖ - រៀបចំកម្មវិធីបណ្តុះបណ្តាលឱ្យនិស្សិត សាស្ត្រាចារ្យ និងមន្ត្រីរាជការមានឱកាសបញ្ចេញស្នាដៃដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក - ផ្លាស់ប្តូរពត៌មាន និងឯកសារអប់រំទាក់ទងទៅនឹងវិស័យសិល្បៈវប្បធម៌ជប៉ុន និងខ្មែរ។	កិច្ចព្រមព្រៀងនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ក្នុងរយៈពេល៥ ឆ្នាំ (ឆ្នាំ ២០១៧ រហូតដល់ ឆ្នាំ ២០២២)
	សាកលវិទ្យាល័យមីជី (Meiji)	ធ្វើកិច្ចសហប្រតិបត្តិដើម្បីពង្រឹងលើវិស័យអប់រំ សិល្បៈវប្បធម៌ និងស្រាវជ្រាវ	មហាវិទ្យាល័យទាំងប្រាំ៖ សហការបណ្តុះបណ្តាលលើវិស័យមនុស្សសាស្ត្រ, វិទ្យាសាស្ត្រសង្គម, វិទ្យាសាស្ត្រ ធម្មជាតិ រួមទាំងផ្នែកដែលពាក់ព័ន្ធផ្សេងៗទៀត	កិច្ចព្រមព្រៀងនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ (ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧)
	សាកលវិទ្យាល័យសូហ្វីយ៉ា (ប្រទេសជ៉ុន)	បណ្តុះបណ្តាលលើបច្ចេកទេសស្រាវជ្រាវ	ដៃគូរសំខាន់ គឺស្ថាបត្យកម្ម និងបុរាណវិទ្យាធ្វើកិច្ចសហប្រតិបត្តិការដើម្បីផ្លាស់ប្តូរនិស្សិត សាស្ត្រាចារ្យ និងមន្ត្រីរាជការ។ ជា	កិច្ចសហប្រតិបតិបត្តិការចាប់ពីឆ្នាំ២០១៤

		បែបធ្វើកំណាយ អភិរក្ស និងជួសជុល	ពិសេសផ្លាស់ប្តូរកម្មវិធីសិក្សា សហការស្រាវជ្រាវ និងកិច្ចសហប្រតិបត្តិការរៀបចំគម្រោងស្រាវជ្រាវរួមគ្នា	(សុពលភាពប្រាំឆ្នាំ)
	សាកលវិទ្យាល័យណាន់សាន់ (ប្រទេសជប៉ុន)	ផ្លាស់ប្តូរនិស្សិត និងបង្កើតទំនាក់ទំនងនៃការស្រាវជ្រាវ រួមទាំងសម្ភារៈ	មហាវិទ្យាល័យ៖ - ស្ថាបត្យកម្ម - បុរាណវិទ្យា	កិច្ចសហប្រតិបតិបត្តិការចាប់ពីឆ្នាំ២០១៥
	សមាគមន៍ព្រះពុទ្ធសាសនាជប៉ុន Shinnyo-en	ផ្តល់អាហារូបករណ៍ជាថវិកាដល់និស្សិតក្រីក្រ	- ស្ថាបត្យកម្ម និងនគរោបនីយវិទ្យា - បុរាណវិទ្យា	កិច្ចសហប្រតិ-បតិបត្តិការចាប់ផ្តើមពីឆ្នាំ ២០១៥ រហូតមកដល់បច្ចុប្បន្ន
	សមាគមន៍ OSAKA in the World	ផ្សព្វផ្សាយវប្បធម៌ OSAKA នៅក្នុងពិភពលោក	- តូរ្យតន្ត្រី - សិល្បៈនាដសាស្ត្រ	កិច្ចសហប្រតិ-បតិបត្តិការនៅឆ្នាំ២០១៤
	លោកស្រី សាស្ត្រាចារ្យ Tanahashi Hisako	សាស្ត្រាចារ្យស្ម័គ្រចិត្តបង្រៀនមុខវិជ្ជា Piano	តូរ្យតន្ត្រី	កិច្ចសហប្រតិ-បតិបត្តិការចាប់ឆ្នាំ២០១៧
	Elisabeth University of Music	គោលបំណងផ្លាស់ប្តូរនិស្សិត, បុគ្គលិកជំនាញ និង ការចូលរួមសន្និសីទ, សិក្ខាសាលា, ការប្រជុំ, ការបណ្តុះបណ្តាល រួមទាំងគម្រោងនៃការស្រាវជ្រាវផ្សេងៗក្នុងកំ	តូរ្យតន្ត្រី	កិច្ចព្រមព្រៀងនេះ មានរយៈពេល ៥ ឆ្នាំ (ចាប់ពីថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០២៣។)

		ឡុងពេលនៃកិច្ច ប្រតិបត្តិការ		
គ. ប្រទេសថៃ				
	វិទ្យាស្ថាន Bunditpatanasilpa	ផ្លាស់ប្តូរនិស្សិត សាស្ត្រាចារ្យ និងមន្ត្រីរាជការ	សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ	កិច្ចសហប្រតិ-បតិបត្តិការចាប់ពីឆ្នាំ២០១៩
	សាកលវិទ្យាល័យសិល្បៈកន និងឈៀងម៉ៃ	គោលបំណងផ្លាស់ប្តូរនិស្សិត, បុគ្គលិកជំនាញ និងការបោះពុម្ពផ្សាយ រួមទាំងការផ្តល់ពត៌មានតាមរយៈការចូលរួមសន្និសីទ, សិក្ខាសាលា, ការប្រជុំ, ការបណ្តុះបណ្តាល រួមទាំងគម្រោងនៃការស្រាវជ្រាវផ្សេងៗក្នុងកំឡុងពេលនៃកិច្ចប្រតិបត្តិការ	**មហាវិទ្យាល័យ៖** - ស្ថាបត្យកម្ម និងនគរោបនីយវិទ្យា - សិល្បៈសូនរូប	កិច្ចព្រមព្រៀងចាប់ពីឆ្នាំ ២០០៤ (រយៈពេលប្រាំឆ្នាំ ប៉ុន្តែកិច្ចសហប្រតិបតិ-បត្តិការនៅបន្តរហូតដល់បច្ចុប្បន្ន)
	សាកលវិទ្យាល័យដូឡាលុងកន (ប្រទេសថៃ)	កិច្ចព្រមព្រាងនេះមានទិសដៅផ្លាស់ប្តូរ៖ - និស្សិត - បុគ្គលិកជំនាញ	**មហាវិទ្យាល័យ៖** - បុរាណវិទ្យា - សូនរូប - តូរតន្ត្រី - សិល្បៈនាដសាស្ត្រ - ស្ថាបត្យកម្ម	កិច្ចព្រមព្រៀងនេះ មានរយៈពេល ៥ ឆ្នាំ (ចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១)។
	សាកលវិទ្យាល័យ Mahasarakham	កិច្ចព្រមព្រាងនេះមានទិសដៅផ្លាស់ប្តូរ៖ - និស្សិត - បុគ្គលិកជំនាញ		ចប់ឆ្នាំ២០០៩
ឃ. ប្រទេសកូរ៉ែ				

	សាកលវិទ្យាល័យលិល្បៈជាតិកូរ៉ែ (កូរ៉ែខាងត្បូង) Korea University of Arts	ការសហប្រតិបត្តិការមានគោលដៅផ្លាស់ប្តូរនូវ៖ - សមាជិកនៃមហាវិទ្យាល័យ - និស្សិត - មុខវិជ្ជាសិក្សា - ការសម្តែង និងការតាំងពិពណ៌	**មហាវិទ្យាល័យ៖** - សិល្បៈនាដសាស្ត្រ - សូនរូប	កិច្ចព្រមព្រៀងនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ (ថ្ងៃទី២៩ ខែ មីនា ឆ្នាំ ២០០៤) សាកលវិទ្យាល័យក៏ផ្តល់អាហារូបករណ៍ឱ្យនិស្សិតកម្ពុជាចំនួនបួននាក់ (បីនាក់មកពីមហាវិទ្យាសិល្បៈនាដសាស្ត្រ និងមួយនាក់មកពីមហាវិទ្យាសូនរូប)។ ចុះឡើងវិញថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០២៥ សុពលភាព៥ឆ្នាំ
	National Gugak Center	គោលបំណងផ្លាស់ប្តូរបុគ្គលិកជំនាញ និងសកម្មភាពតាមរយៈការចូលរួមសន្និសីទ, សិក្ខាសាលាជាដើម។	តូរ្យតន្ត្រី	កិច្ចព្រមព្រៀងនេះ មានរយៈពេល ៣ ឆ្នាំ (ចាប់ពីថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០២៣។)
	Art Avenue Company	គោលបំណងផ្លាស់ប្តូរសកម្មភាពសិល្បៈតាមរយៈការចូលរួម	សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ	កិច្ចព្រមព្រៀងនេះ មានរយៈពេល ៥ ឆ្នាំ

		សន្និសីទ, សិក្ខាសាលាជាដើម។		(ចាប់ពីថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២៣។)
	Korean National University of Cultural Heritage	គោលបំណងផ្លាស់ប្តូរនិស្សិត, បុគ្គលិកជំនាញ និងការបោះពុម្ពផ្សាយ រួមទាំងការផ្តល់ពត៌មានតាមរយៈការចូលរួមសន្និសីទ, សិក្ខាសាលា, ការប្រជុំ, ការបណ្តុះបណ្តាល រួមទាំងគម្រោងនៃការស្រាវជ្រាវផ្សេងៗក្នុងកំឡុងពេលនៃកិច្ច	ជាដៃគូសំខាន់ក្នុងការផ្លាស់ប្តូរនិស្សិតមួយឆមាស (២ដងក្នុងមួយឆ្នាំ)៖ - បុរាណវិទ្យា - សូនរូប - ស្ថាបត្យកម្ម	កិច្ចព្រមព្រៀងនេះ មានរយៈពេល ៥ ឆ្នាំ (ចាប់ពីថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០២៣។)
	Woosuk University	គោលបំណងផ្លាស់ប្តូរសកម្មភាពសិល្បៈតាមរយៈការចូលរួមសន្និសីទ, សិក្ខាសាលាជាដើម។		កិច្ចព្រមព្រៀងនេះ មានរយៈពេល ៥ ឆ្នាំ (ចាប់ពីថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០២៥។)
ង. សហរដ្ឋអាមេរិក				
	សាកលវិទ្យាល័យហ៊ាវ៉ៃ នៅម៉ានៅ (សហរដ្ឋអាមេរិក) University of Havaii at Manoa, USA	ការប្រតិបត្តិការមានគោលដៅ៖ - ផ្លាស់ប្តូរមហាវិទ្យាល័យទាំងពីរ - ផ្លាស់ប្តូរសិស្ស - សហការជាដៃគូក្នុងការស្រាវជ្រាវ - ផ្លាស់ប្តូរនៃសម្ភារៈ	**មហាវិទ្យាល័យ៖** - បុរាណវិទ្យា	- កិច្ចព្រមព្រៀងនេះ មានរយៈពេល ៥ ឆ្នាំ (ចាប់ពីថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០៤)។ - សាកលវិទ្យាល័យក៏បានផ្តល់អាហាររូបករណ៍

				ដល់និស្សិតបុរាណវិទ្យា ដូចជាលោក **បុង សុវត្តិ** បានបញ្ចប់ថ្នាក់បណ្ឌិត នៅសាកលវិទ្យាល័យនេះ។ ដូច្នេះ សាកលវិទ្យាល័យត្រូវការបណ្តុះបណ្តាលនិស្សិតបុរាណវិទ្យាជាបន្តទៀត ទាក់ទងនឹងកំណាយស្រាវជ្រាវ, ផែនទី និងមុខវិជ្ជាស្នូលផ្សេងៗ។
	Northern Illinois University	គោលបំណងផ្លាស់ប្តូរនិស្សិត, បុគ្គលិកជំនាញ	**សាកលវិទ្យាល័យ**	- កិច្ចព្រមព្រៀងនេះ មានរយៈពេល ៥ ឆ្នាំ (ចាប់ពីថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០២២)។
ច. ប្រទេសឥណ្ឌូនេស៊ី				
	វិទ្យាស្ថានសិល្បៈបាលី (ប្រទេសឥណ្ឌូនេស៊ី)	កិច្ចព្រមព្រាងនេះមានគោលបំណង៖ - ផ្លាស់ប្តូរនូវកម្មវិធីសិក្សា - បុគ្គលិក	**មហាវិទ្យាល័យ៖** - សិល្បៈនាដសាស្ត្រ - តូរតន្ត្រី	កិច្ចព្រមព្រៀងនេះ មានរយៈពេល ៣ ឆ្នាំ។

		- និស្សិត		
ឆ. ប្រទេសអាឡឺម៉ង់				
	The Interdisciplinary Centre for Scientific Computing (IWR) of the Ruprecht-Karis Universitat at Heidelberg, ប្រទេសអាឡឺម៉ង់	ការចុះអនុសារណៈមានគោលបំណងពង្រីកបន្ថែម និងការណែនាំឱ្យស្គាល់ពីៈ - ពត៌មាន ឬទិន្នន័យនៃបច្ចេកវិទ្យា - ការថែរក្សា - វិធីសាស្ត្រនៃការគណនានៃស្ថាបត្យកម្ម (Method of computational architecture)	**មហាវិទ្យាល័យៈ** - បុរាណវិទ្យា - ស្ថាបត្យកម្ម	គម្រោងនៃការស្រាវជ្រាវជាមួយនិស្សិត ៥នាក់ដែលមកពីមហាវិទ្យាល័យស្ថាបត្យកម្ម និងបុរាណវិទ្យា។
	បណ្ឌិត Gerd Albrecht នៃសាកលវិទ្យាល័យ Tubingen	កំណាយ និងបុរេប្រវត្តិសាស្ត្រ	**មហាវិទ្យាល័យៈ** - បុរាណវិទ្យា	- DAAN, អាឡឺម៉ង់ - បង្រៀន ២ ខែ ក្នុងរយៈពេល ២ ឆ្នាំ (វិច្ឆិកា-ធ្នូ)
	បណ្ឌិត Babara Albrecht	បង្រៀនពីមីក្រូទស្សន៍	**មហាវិទ្យាល័យៈ** - បុរាណវិទ្យា	- DAAN, អាឡឺម៉ង់ - បង្រៀន ២ ខែ ក្នុងរយៈពេល ២ ឆ្នាំ (វិច្ឆិកា-ធ្នូ)។
ជ. ប្រទេសវៀតណាម				
	Université d'architecture d'Hanoi	គោលបំណងផ្លាស់ប្តូរបុគ្គលិកជំនាញ និងការបោះពុម្ពផ្សាយ រួមទាំងការផ្តល់ពត៌មានតាមរយៈការចូលរួមសន្និសីទ, សិក្ខា	**មហាវិទ្យាល័យៈ** - ស្ថាបត្យកម្ម	កិច្ចព្រមព្រៀងនេះ មានរយៈពេល ៥ ឆ្នាំ (ចាប់ពីថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០២៣។)

		សាលា, ការប្រជុំ, ការបណ្តុះបណ្តាល រួមទាំងគម្រោងនៃការស្រាវជ្រាវផ្សេងៗក្នុងកំឡុងពេលនៃកិច្ច		
	Van Lang University	គោលបំណងផ្លាស់ប្តូរនិស្សិត, បុគ្គលិក ជំនាញ និងការបោះពុម្ពផ្សាយ រួមទាំងការផ្តល់ពត៌មានតាមរយៈ ការចូលរួមសន្និសីទ, សិក្ខាសាលា, ការប្រជុំ, ការបណ្តុះបណ្តាល ទស្សនកិច្ចសិក្សា រួមទាំងគម្រោងនៃការស្រាវជ្រាវផ្សេងៗក្នុងកំឡុងពេលនៃកិច្ច	**មហាវិទ្យាល័យ៖** - បុរាណវិទ្យា - សូនរូប - តូរតន្ត្រី - ស្ថាបត្យកម្ម	កិច្ចព្រមព្រៀងនេះ មានរយៈពេល ៥ ឆ្នាំ (ចាប់ពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២៣។)
ឈ. ប្រទេសចិន				
	Asia united architecture association	គោលបំណងចូលរួមក្នុងការរៀបចំ Asian contest of Architectural Rookie´s Award	សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ	កិច្ចព្រមព្រៀងនេះ មានរយៈពេល ៣ ឆ្នាំ (ចាប់ពីថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៩។)
	Wuhan University	គោលបំណងរៀបចំដំណើរទស្សនកិច្ចនៅបុរាណដ្ឋាននៃប្រទេសទាំង២រួមទាំងការចូលរួមធ្វើសន្និសីទ, សិក្ខាសាលា, ការប្រជុំ, ការបណ្តុះបណ្តាល និង	**មហាវិទ្យាល័យ៖** - បុរាណវិទ្យា	កិច្ចព្រមព្រៀងនេះ មានរយៈពេល ៥ ឆ្នាំ (ចាប់ពីថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៩។

		គម្រោងនៃការស្រាវជ្រាវផ្សេងៗក្នុងកំឡុងពេលនៃកិច្ចប្រតិបត្តិការ		ចុះម្តងទៀតខែធ្នូ២០២៤
	Sunwalk group	គោលបំណងចូលរួមបង្កើតមហាវិទ្យាល័យភាពយន្តនិង ផ្លាស់ប្តូរនិស្សិត, បុគ្គលិក ជំនាញ ទៅប្រទេសចិន រួមទាំងការចូលរួមធ្វើសន្និសីទ, សិក្ខាសាលា, ការប្រជុំ, ការបណ្តុះបណ្តាល ការស្រាវជ្រាវផ្សេងៗលើផ្នែកវប្បធម៌។	**សាកលវិទ្យាល័យ**	កិច្ចព្រមព្រៀងនេះ មានរយៈពេល ៥ ឆ្នាំ (ចាប់ពីថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៩។
	Yunnan Institute of Cultural Relics and Archaeology	ដើម្បីធ្វើការផ្លាស់ប្តូរផ្នែកវិទ្យាសាស្ត្រ និង/ឬ ផ្នែកអប់រំ ដោយផ្តោតសំខាន់លើផ្នែកបុរាណវិទ្យា	**បុរាណវិទ្យា**	កិច្ចព្រមព្រៀងនេះ មានរយៈពេល ៥ ឆ្នាំ (ចាប់ពីថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៨។
	Tianjin Conservatory of Music	តូរ្យតន្ត្រី		ចុះហត្ថលេខាថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០២៥ ចប់ ២០៣០
អាស៊ី				
	Asia united architecture association	ផ្នែកស្ថាបត្រកម្ម	**ជាសមាជិតនៃសមាគមន៍**	កិច្ចព្រមព្រៀងនេះ មានរយៈពេល ៣ ឆ្នាំ (ចាប់ពីថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៩។

៤. ការស្រាវជ្រាវ និងបណ្តាញដៃគូសកល

វឌ្ឍភាពការងារស្រាវជ្រាវ របស់មជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌ និងនវានុវត្ត

២០១៦

ល.រ	ការងារ	សម្រេចបាន	បញ្ហាប្រឈម	ទិសដៅទៅមុខ
១	បោះពុម្ពផ្សាយ	គ្មាន		
២	ការងារស្រាវជ្រាវ	គ្មាន		
៣	ផលិតកុនឯកសារ	១. ថតបទភ្លេង និង ចម្រៀងអារក្ស		

២០១៧

ល.រ	ការងារ	សម្រេចបាន	បញ្ហាប្រឈម	ទិសដៅទៅមុខ
១	បោះពុម្ពផ្សាយ	គ្មាន		
២	ការងរស្រាវជ្រាវ	គ្មាន		
៣	ផលិតកុនឯកសារ	គ្មាន		

២០១៨

ល.រ	ការងារ	សម្រេចបាន	បញ្ហាប្រឈម	ទិសដៅទៅមុខ
១	បោះពុម្ពផ្សាយ	ព្រឹត្តបត្រសាកលវិទ្យាល័យលេខ ១		
២	ការងរស្រាវជ្រាវ			
៣	ផលិតកុនឯកសារ	គ្មាន		

២០១៩

ល.រ	ការងារ	សម្រេចបាន	បញ្ហាប្រឈម	ទិសដៅទៅមុខ
១	បោះពុម្ពផ្សាយ	១. ព្រឹត្តបត្រលេខសាកលវិទ្យាល័យលេខ២ ២. កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរលេខ១៤		
២	ការងារស្រាវជ្រាវ	១. ពិធីឡើងអ្នកតានៅខេត្តកំពង់ធំ		
៣	ផលិតកុនឯកសារ	គ្មាន		

២០២០

ល.រ	ការងារ	សម្រេចបាន	បញ្ហាប្រឈម	ទិសដៅទៅមុខ
១	បោះពុម្ពផ្សាយ	១. ព្រឹត្តបត្រសាកលវិទ្យា លំយ លេខ៣ ២. កម្រងអត្ថបទក្នុងបណ្តាញ ព័ត៌មានវប្បធម៌ខ្មែរលេខ១៥ ៣. ពិធីសំពះគ្រូភ្លេងមហោរី ៤. បោះពុម្ពផ្សាយផែនការយុទ្ធ-សាស្ត្រ៥ឆ្នាំ (២០១៩-២០២៣) របស់សាកលវិទ្យាល័យភូមិន្ទ វិចិត្រសិល្បៈ		
២	ការងារស្រាវជ្រាវ	១.ចុះស្រាវជ្រាវមេដំបែស្រានៅខេត្តសៀមរាប ២.ចុះស្រាវជ្រាវពីកន្ទេលផ្ការនៅខេត្តសៀមរាប ៣.ចុះប្រមូលព័ត៌មានពីពិធីអកអំបុកនៅខេត្តសៀមរាប ៤.ស្រាវជ្រាវអំពីដើមជ្រៃនៅស្រុកកោះធំ ខេត្តកណ្តាល។		
៣	ផលិតកុនឯកសារ	១.មេដំបែស្រានៅខេត្តសៀមរាប ២.កន្ទេលផ្ការនៅខេត្តសៀមរាប ៣.ធម្មជាតិនិងជ្រៃ		

២០២១

ល.រ	ការងារ	សម្រេចបាន	បញ្ហាប្រឈម	ទិសដៅទៅមុខ
១	បោះពុម្ពផ្សាយ	១.ព្រឹត្តបត្រសាកលវិទ្យាល័យ លេខ៤ ២.កម្រងអត្ថបទក្នុងបណ្តាញ ព័ត៌មានវប្បធម៌ខ្មែរលេខ១៦ ៣.បោះពុម្ពលើកទី២ សៀវភៅដំណើរប្រវត្តិសាកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ, ដំណើរ១០០ ឆ្នាំ ក្នុងវិស័យសិល្បៈនិងវប្បធម៌ខ្មែរ		

២	ការងារស្រាវជ្រាវ	១.ពិធីបុណ្យសពនៅតំបន់អង្គរ		
៣	ផលិតកុនឯកសារ	១.ពិធីបុណ្យសពនៅតំបន់អង្គរ		

២០២២

ល.រ	**ការងារ**	**សម្រេចបាន**	**បញ្ហាប្រឈម**	**ទិសដៅទៅមុខ**
១	បោះពុម្ពផ្សាយ	១.ព្រឹត្តបត្រសាកលវិទ្យាល័យលេខ ៥ ២.កម្រងអត្ថបទក្នុងបណ្តាញ ព័ត៌មានវប្បធម៌ខ្មែរលេខ១៧	១.ធនធានមនុស្ស លើការងារ ស្រាវជ្រាវនៅមាន កម្រិត - ដំណោះស្រាយ ៖ មជ្ឈមណ្ឌល បានសហការ ស្រាវជ្រាវជាមួយ ស្ថាប័នផ្សេងៗ ដើម្បីបំពេញបន្ថែ ម។ ឧទាហរណ៍ សហការជាមួយ អង្គការយសោធរ, នាយកដ្ឋាន បុរាណវត្ថុ និង ជាមួយអ្នក ស្រាវជ្រាវផ្សេងៗ ទៀត។ ២. រចនាសម្ព័ន្ធ គ្រប់គ្រងនៅក្នុង មជ្ឈមណ្ឌលមិន ទាន់រៀបចំបាន ស្រួលបួល - ដំណោះស្រាយ ៖ មជ្ឈមណ្ឌល បានរៀបចំរចនា សម្ព័ន្ធថ្មី ដែល	-ព្រឹត្តិបត្រ សាកលវិទ្យា ល័យភូមិន្ទវិចិត្រ សិល្បៈ, លេខ៥, ឆ្នាំ២០២៣ -បោះពុម្ព សៀវភៅស្តីពី « របរហត្ថកម្ម ប្រពៃណីនៅ ស្រុកស្ទោង ខេត្តកំពង់ធំ» -សហការ ជាមួយអង្គការ យសោធរបោះ ពុម្ពសៀវភៅប ណ្តាញព័ត៌មាន វប្បធម៌ខ្មែរ, លេខ១៨, ឆ្នាំ ២០២៣។
២	ការងារស្រាវជ្រាវ	១.ហត្ថកម្មប្រពៃណីនៅស្រុកស្ទោង ខេត្តកំពង់ធំ។ ២.អាហារប្រចាំតំបន់នៅខេត្តតាកែ វ។ ៣.ប្រពៃណីចូលម្លប់ នៅតំបន់ផ្អាវ ខេត្តកំពង់ចាម		-ចុះស្រាវជ្រាវ អំពីការលម្អលើ សំណង់ស្តាបត្យ កម្មប្រពៃណីខ្មែរ សម័យមុនអង្គរ (ខេត្តកែវ, កំពត, ព្រៃវែង)

			មាននៅក្នុង ប្រកាសរួមស្តីពី ការរៀបចំនិងការ ប្រព្រឹត្តទៅ នៃ សាកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ ៣. ថវិកាសម្រាប់ ការងារស្រាវជ្រាវ នៅមានកម្រិតតិច តួច - ដំណោះស្រាយ ៖ មជ្ឈមណ្ឌល បានស្វែងរកដៃគូ ឧបត្ថម្ភមក បំពេញបន្ថែម។	-ស្រាវជ្រាវអំពី សិប្បកម្ម តម្បាញនៅ តំបន់ជុំវិញ ប្រាសាទសំបូរ ព្រៃគុក -ស្រាវជ្រាវអំពី ភាពប្លែកគ្នានៃ ពិធីមង្គលការ នៅតាមភូមិ បុរាណមួយ ចំនួននៃខេត្ត សៀមរាប
៣	ផលិតកុនឯកសារ	១.ផលិតវីដេអូឯកសារស្តីពីពិធីចូលម្លប់ នៅតំបន់ផ្អាវ ខេត្តកំពង់ចាម ២.ផលិតវីដេអូឯកសារស្តីពីពិធីអកអំបុក ៖ ស្រូវថ្មី, យុវជន, ខែពេញបូណ៌មីទី១ ៣.ផលិតវីដេអូឯកសារស្តីពីភព អមនុស្សក្នុងជំនឿខ្មែរ (បាឋកថា ដោយនរវិទូ អាំង ជូលាន)		- កុនឯកសារស្តីពី ៖ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ដំណើរ ១០០ឆ្នាំក្នុងវិស័យ វប្បធម៌ខ្មែរ - កុនឯកសារស្តីពី ៖ ម្រ័ក្សណ៍ខ្មែរ - កុនឯកសារស្តីពី ៖ ល្ខោនយីកេ នៅស្រុកឈូក ខេត្តកំពត

២០២៣

ល.រ	ការងារ	សម្រេចបាន	បញ្ហាប្រឈម	ទិសដៅទៅមុខ
១	បោះពុម្ពផ្សាយ	១.ព្រឹត្តបត្រសាកលវិទ្យាល័យ លេខ៦		

		២.កម្រងអត្ថបទក្នុងបណ្ណាញ ព័ត៌មានវប្បធម៌ខ្មែរលេខ១៨		
២	ការងារស្រាវជ្រាវ	១.បានចុះសិក្សាស្រាវជ្រាវពីល្ខោនឡាំស្រុកឈូក ខេត្តកំពត ២.បានចុះស្រាវជ្រាវអំពីលៀងគ្រូអារក្ស (គ្រូហ្មដំរី) នៅភូមិសំបូរ ខេត្តកំពង់ធំ ៣.បានចុះសង្កេតពិធី សែនត្រណមផ្ទះ នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ៤.បានចុះស្រាវជ្រាវអំពីម្ហូបអាហារ និងការធ្វើដំបែរស្រា នៅភូមិអូរឈើទាល ខេត្តកំពង់ធំ ៥.បានចុះស្រាវជ្រាវពី ពិធីបុណ្យភូមិ នៅភូមិដំយ (តំបន់សំបូរព្រៃគុក) ខេត្តកំពង់ធំ ៦.បានចុះស្រាវជ្រាវពិធីច្រត់ព្រះនង្គ័លនៅភូមិចំណារ និងភូមិដងអន្ទាក់ ខេត្តកំពង់ធំ ៧.បានចុះប្រមូលទិន្នន័យអំពីក្បាច់លម្អស្ថាបត្យកម្មសម័យមុនអង្គរនៅខេត្តតាកែវមានដូចជា ប្រាសាទបាយ៉ង់កោ ប្រាសាទនាងសក់ក្រអូប ប្រសាទព្រះបាទដៃខ្លី ប្រាសាទភ្នំខ្យង ប្រាសាទភ្នំទទុង និងប្រាសាទភ្នំឈ្មោក។ ៨.បានចុះប្រមូលទិន្នន័យអំពីក្បាច់លម្អស្ថាបត្យកម្មសម័យមុនអង្គរនៅខេត្តកំពង់ធំមានដូចជា៖ ប្រាសាទត្នោតជុំខាងលិច ប្រាសាទត្នោតជុំខាងកើត ប្រាសាទភូមិប្រាសាទ ប្រាសាទ		

		គុកវៀង ប្រាសាទអណ្តែត ប្រាសាទស្វាយលើ និងក្រុមប្រាសាទសំបូរព្រៃគុក។ ៩.បានចុះស្រាវជ្រាវពីពិធីបុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌនៅខេត្តសៀមរាប។		
៣	ផលិតកុនឯកសារ	១.ផលិតនិងផ្សព្វផ្សាយវីដេអូល្ខោននិយាយរឿង **វង្សត្រកូលកំសត់** ជាស្នាដៃប្រលងបញ្ចប់បរិញ្ញាបត្ររបស់និស្សិតមហាវិទ្យាល័យសិល្បៈនាដសាស្ត្រនៅលើគេហទំព័ររបស់មជ្ឈមណ្ឌលនិងសាកលវិទ្យាល័យ។ ២.ផលិតវីដេអូល្ខោនបាសាក់រឿង **បុប្ផាទងដៃក** ជាស្នាដៃប្រលងបញ្ចប់បរិញ្ញាបត្ររបស់និស្សិតមហាវិទ្យាល័យសិល្បៈនាដសាស្ត្រនិងផ្សព្វផ្សាយនៅលើគេហទំព័រមជ្ឈមណ្ឌលនិងសាកលវិទ្យាល័យ។		

២០២៤

ល.រ	**ការងារ**	**សម្រេចបាន**	**បញ្ហាប្រឈម**	**ទិសដៅទៅមុខ**
១	បោះពុម្ពផ្សាយ	១.ព្រឹត្តបត្រសាកលវិទ្យាល័យលេខ៧ ២.កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរលេខ១៩		
២	ការងារស្រាវជ្រាវ	១.ចុះប្រមូលទិន្នន័យក្បាច់លម្អស្តាបត្យកម្ម ២.ចុះស្រាវជ្រាវអំពីប្រពៃណីលេងត្រុដិ នៅខេត្តសៀមរាប ៣.ចុះស្រាវជ្រាវការធ្វើដំបែស្រានៅខេត្តព្រះវិហារ		

៣	ផលិតកុនឯកសារ	១.ផលិតវីដេអូឯកសារស្រាវជ្រាវអំពីៈ «បុណ្យភ្ជុំបិណ្ឌ» ២.ផលិតវីដេអូបាឋកថាអំពីៈ ដើម កំណើត តជំនាន់ ភ្ជាប់ ៣.ផលិតវីដេអូបាឋកថាអំពីៈ ការយល់ឃើញខ្លះៗពីទេសភាពវប្បធម៌នៅខេត្តសៀមរាប ៤.ផលិតវីដេអូបាឋកថាអំពីៈ លទ្ធផលស្រាវជ្រាវថ្មីៗនៅទួលបាសាន (ស្រីសន្ធរ) ៥.ផលិតវីដេអូបាឋកថាអំពីៈ ការវិវត្តន៍អក្សរខ្មែរ ករណីសិក្សាអំពីគំនូសអក្សរខ្លីៗសម័យអង្គរ ៦.ផលិតវីដេអូបាឋកថាអំពីៈ ជីវិតប្រចាំថ្ងៃក្នុងគំនូរតាមវត្ត		

២០២៥

ល.រ	**ការងារ**	**សម្រេចបាន**	**បញ្ហាប្រឈម**	**ទិសដៅទៅមុខ**
១	បោះពុម្ពផ្សាយ	១.ព្រឹត្តបត្រសាកលវិទ្យាល័យ លេខ៨ (មិនទាន់បោះពុម្ព) ២.កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរលេខ២០		
២	ការងារស្រាវជ្រាវ			
៣	ផលិតកុនឯកសារ	ផលិតវីឌេអូបាឋកថាអំពី ក្រមាក្នុងសង្គមខ្មែរ។ ផ្សព្វផ្សាយនៅថ្ងៃទី ២១/មករា/២០២៥ ផលិតវីឌេអូបាឋកថាអំពី ក្រម៉ាជ្រលក់ព័ណ៌ត្រុំ ។ ផ្សព្វផ្សាយនៅថ្ងៃទី ១៤/ឧសភា/២០២៥ កិច្ចសម្ភាសន៍ រវាងលោកគ្រូ ស៊ី យ៉ុន សុភាវិទ្ធ និងលោកគ្រូអាំង ជូលាន អំពីសៀវភៅប្រវត្តិសាស្ត្រ		

		កម្ពុជាសម័យអង្គរ។ ផ្សព្វផ្សាយនៅថ្ងៃទី ២១/ឧសភា/២០២៥ ផលិតវីឌេអូបាឋកថាអំពី ចម្លាក់ស្រីសួគ៌នៅតាមប្រាសាទ។ ផ្សព្វផ្សាយនៅថ្ងៃទី ២៦/មិថុនា/ ២០២៥។		

២០២៦

ល.រ	**ការងារ**	**សម្រេចបាន**	**បញ្ហាប្រឈម**	**ទិសដៅទៅមុខ**
១	បោះពុម្ពផ្សាយ	ព្រឹត្តបត្រសាកលវិទ្យាល័យលេខ ៩ (មិនទាន់បោះពុម្ព)		
២	ការងារស្រាវជ្រាវ	គ្មាន		
៣	ផលិតកុនឯកសារ	១. ផលិតវីឌេអូសិក្ខាសាលាអំពីៈ តឹកតាង ក្រណាត់និងសម្លៀកបំពាក់តាមសិលាចារឹក		

រចនាសម្ព័ន្ធនៃការបណ្តុះបណ្តាល ស្រាវជ្រាវ របស់សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ពីឆ្នាំ២០១៤ មកដល់ឆ្នាំ២០២៦

ខែកញ្ញា ឆ្នាំ២០២៦

១.ប្រវត្តិ

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ត្រូវបានបង្កើតឡើងដំបូង នៅខែមិថុនា ឆ្នាំ១៩៤៦ យោងតាមក្រឹត្យលេខ ១០៣ - សន ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៤៦ ដោយមានឈ្មោះ ថា សាលាមន្ត្រីសុខាភិបាល។ បន្ទាប់មក ដោយយោងតាមអនុក្រឹត្យលេខ ៥១៣ សន ចុះថ្ងៃទី ១២ ខែតុលា ឆ្នាំ១៩៥៣ សាលានេះ បានប្តូរឈ្មោះទៅជា មហាវិទ្យាល័យកូមិន្ទវិជ្ជាពេទ្យ ។

នៅឆ្នាំ ១៩៥៩ ផ្នែកមន្ត្រីសុខាភិបាល និង ឱសថសាស្ត្រ បានបង្កើតឡើងបន្ថែមនៅក្នុង សាលាកូមិន្ទវិជ្ជាពេទ្យនេះ។ រហូតដល់ឆ្នាំ១៩៦២ មហាវិទ្យាល័យកូមិន្ទវិជ្ជាពេទ្យ បានក្លាយ ទៅជា មហាវិទ្យាល័យ វេជ្ជសាស្ត្រ វេជ្ជប្រតិព័ទ្ធ និង ឱសថសាស្ត្រ តាមក្រឹត្យលេខ ១២០ CF ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ១៩៦២។

នៅឆ្នាំ ១៩៦៤ អគារសិក្សានៃមហាវិទ្យាល័យ ត្រូវបានខ័ណ្ឌចែកជា២ គឺ មហាវិទ្យាល័យ វេជ្ជសាស្ត្រ វេជ្ជប្រតិព័ទ្ធ និងមហាវិទ្យាល័យឱសថសាស្ត្រ។ ក្រោយមក មហាវិទ្យាល័យ ឱសថសាស្ត្រ បានផ្តាច់ចេញ ទៅនៅក្នុងបរិវេណនៃ សាកលវិទ្យាល័យកូមិន្ទភ្នំពេញ នៅឆ្នាំ ១៩៦៧។

ក្នុងកំឡុងឆ្នាំ១៩៧១ មហាវិទ្យាល័យវេជ្ជសាស្ត្រ និងវេជ្ជប្រតិព័ទ្ធ ត្រូវបានរៀបចំឡើងវិញ ដោយបង្កើតផ្នែកថ្មីមួយទៀតគឺ ផ្នែកទន្តសាស្ត្រ ហើយប្តូរឈ្មោះថា មហាវិទ្យាល័យវេជ្ជសាស្ត្ត និងវិទ្យាស្ថានទន្តវេទនសាស្ត្រ។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចន្លោះពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ មហាវិទ្យាល័យវេជ្ជសាស្ត្រ និង វិទ្យាស្ថានទន្តវេទនសាស្ត ត្រូវបានបោះបង់ចោលទាំងស្រុង។

ក្រោយថ្ងៃជ័យជម្នះ ៧ មករា ឆ្នាំ១៩៧៩ បានបញ្ចប់នូវយុគសម័យប្រល័យពូជសាសន៍ ហើយបើកឡើងនូវទំព័រថ្មីនៃប្រវត្តិសាស្ត្រកម្ពុជា គេសង្កេតឃើញអាគារមហាវិទ្យាល័យនេះ មានពណ៌ក្រហម ដែលនាំឱ្យគេហៅសាលានេះក្រៅផ្លូវការថា សាលាក្រហម។

យោងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ១៩៨០ មហាវិទ្យាល័យនេះបានបើកទ្វារឡើងវិញ ដែលមានឈ្មោះថា មហាវិទ្យាល័យ វេជ្ជសាស្ត្រ និងឱសថសាស្ត្រ ហើយក្រោយមក បានប្តូរឈ្មោះជា មហាវិទ្យាល័យចម្រុះ វេជ្ជសាស្ត្រ ឱសថសាស្ត្រ និងទន្តសាស្ត្រ ក្នុងរង្វង់ចុងឆ្នាំ ១៩៨០។

ដោយឡែក សាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ ដែលបច្ចុប្បន្នស្ថិតនៅក្រោមរចនាសម្ព័ន្ធរបស់សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល បានចាប់ផ្តើម បង្កើតនៅឆ្នាំ១៩៥០ - មានឈ្មោះ ដំបូងថា សាលាកូមិន្ទ គិលានុបដ្ឋាក គិលានុ បដ្ឋាយិកា និងឆ្មបរដ្ឋ រួចបានប្តូរទីតាំងថ្មីដោយប្តូរឈ្មោះ មកជា សាលា គិលានុបដ្ឋាក គិលានុបដ្ឋាយិការ និងឆ្មបរដ្ឋ នៅឆ្នាំ១៩៦៩។ សាលានេះក៏ត្រូវបានបិទទ្វារទាំងស្រុងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយបានបើកដំណើរការឡើងវិញ នៅខែមករា ឆ្នាំ១៩៨០ ដោយមានឈ្មោះជា សាលាកម្មាភិបាលសុខាភិបាលមធ្យឹម និងបានប្តូរឈ្មោះថា សាលាបច្ចេកទេស ថែទាំវេជ្ជសាស្ត្រ នៅដំណាក់កាលក្រោយមក។

នៅឆ្នាំ១៩៩៧ មហាវិទ្យាល័យចំរុះវេជ្ជសាស្ត្រ ឱសថសាស្ត្រ និងទន្តសាស្ត និង សាលាកម្មាភិបាលសុខាភិបាលមធ្យឹម បានច្របាច់បញ្ចូលគ្នាហើយបាន ប្រែក្លាយជា សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល រហូតដល់បច្ចុប្បន្ន។

នៅចុងឆ្នាំ២០០១ រាជរដ្ឋាភិបាលបានសម្រេចឱ្យសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលក្លាយជាគ្រឹះស្ថានសាធារណៈរដ្ឋបាល តាមអនុក្រឹត្យ លេខ ១២៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ២០០១ ដែលក្នុងនោះរួមមាន មហាវិទ្យាល័យ វេជ្ជសាស្ត្រ មហាវិទ្យាល័យឱសថសាស្ត្រ មហាវិទ្យាល័យទន្តវេទសាស្ត្រ និងសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ។

បរិបទនៃការប្រកួតប្រជែងទាំងក្នុងតំបន់ និងអន្តរជាតិ ជាពិសេស ការបើកនូវលំហូរការងារក្នុងបណ្តាប្រទេសអាស៊ាន និងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការយកចិត្តទុកដាក់ខ្ពស់លើការបណ្តុះ-បណ្តាលធនធានមនុស្សជារួម និងជាពិសេសការបណ្តុះបណ្តាលធនធានមនុស្ស ក្នុងវិស័យ សុខាភិបាល បានតម្រូវឱ្យសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល កាន់តែបន្តអភិវឌ្ឍខ្លួនជាបន្តបន្ទាប់ដើម្បីប្រែក្លាយសាកលវិទ្យាល័យ ជាថ្នាលបណ្តុះបណ្តាលឈានមុនគេមួយទាំងក្នុងប្រទេស និងក្នុងតំបន់ និងមានការទទួលស្គាល់គុណភាពបណ្តុះបណ្តាល កម្រិតតំបន់ និងកម្រិត អន្តរជាតិ។

បច្ចុប្បន្ន សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល មានអង្គភាពចំណុះចំនួន ០៩ រួមមាន ៖

1. មហាវិទ្យាល័យវេជ្ជសាស្ត្រ
2. មហាវិទ្យាល័យឱសថសាស្ត្រ
3. មហាវិទ្យាល័យទន្តវេទសាស្ត្រ
4. មហាវិទ្យាល័យសុខភាពសាធារណៈ
5. មហាវិទ្យាល័យគិលានុបដ្ឋាក និង ឆ្មប
6. មហាវិទ្យាល័យសម្ព័ន្ធសុខាភិបាល
7. មន្ទីរពេទ្យសាកលវិទ្យាល័យ
8. មជ្ឈមណ្ឌលសុខភាពសាកល
9. អង្គភាពកិច្ចការទូទៅ

(យោងតាមអនុក្រឹត្យលេខ៣៣១ អនក្រ.បក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣)

២.វឌ្ឍនភាព

ក. ប្រធានបទទី១ អំពីវឌ្ឍនភាពឧត្តមសិក្សា

ដោយមានការគាំទ្រយ៉ាងពេញទំហឹងពីរាជរដ្ឋាភិបាលកម្ពុជា សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល បានអភិវឌ្ឍន៍ខ្លួន យ៉ាងឆាប់រហ័ស និងពោពេញដោយសក្តានុពល ក្នុងការប្រកួតប្រជែង ទាំងកម្រិតជាតិ និងកម្រិតតំបន់ និងអន្តរជាតិ។ តាមរយៈការកែចំរើននេះ និងស្របតាមបរិបទរបស់ពិភពលោក សាកលវិទ្យាល័យ បានពង្រីករចនាសម្ព័ន្ធគ្រប់គ្រង និងបណ្តុះបណ្តាលរបស់ខ្លួន ពីអង្គភាព ដែលមានចំនួន ០៤ ទៅជា ៩ អង្គភាព ផ្តល់ការបណ្តុះបណ្តាល ការស្រាវជ្រាវ និងផ្តល់សេវាសុខាភិបាល ប្រកបដោយគុណភាព សមធម៌ និងវិជ្ជាជីវៈ។

សាកលវិទ្យាល័យ មានទីតាំងចំនួន ០៣ សម្រាប់បម្រើឱ្យការបណ្តុះបណ្តាល ស្រាវជ្រាវ និងការផ្តល់សេវាសុខាភិបាល៖

ទីតាំងទី១៖ មានមហាវិទ្យាល័យវេជ្ជសាស្ត្រ មហាវិទ្យាល័យឱសថសាស្ត្រ មហាវិទ្យាល័យ

សុខភាពសាធារណៈ មជ្ឈមណ្ឌលស្រាវជ្រាវសុខភាពសាកល និងអង្គភាពកិច្ចការទូទៅ។

ទីតាំងទី២៖ មានមហាវិទ្យាល័យគិលានុបដ្ឋាកនិងឆ្មប មហាវិទ្យាល័យសម្ព័ន្ធសុខាភិបាល និង មហាវិទ្យាល័យទន្តវេទសាស្ត្រ។

ទីតាំងទី៣៖ កំពុងដំណើរការសាងសង់មន្ទីរពេទ្យសាកលវិទ្យាល័យ និងត្រៀមដំណើរការ នៅ ឆ្នាំ២០២៧ ខាងមុខ។

បច្ចុប្បន្នសាកលវិទ្យាល័យ មានអាគារសិក្សា សរុប ចំនួន ៩ អគារ និងចំនួន បន្ទប់ប្រមាណសរុប ៤៦១ បន្ទប់ សម្រាប់ការបណ្តុះបណ្តាលបង្រៀនទ្រឹស្តី អនុវត្តបង្ហាញគ្រាប់ និងការវាយតម្លៃនិស្សិត។

សាកលវិទ្យាល័យ បានផ្តល់ការបណ្តុះបណ្តាលលើជំនាញសុខាភិបាល គ្រប់ជំនាញ និងគ្រប់កម្រិត ដែលរួមទាំង បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ វេជ្ជបណ្ឌិត ទន្តបណ្ឌិត និងវេជ្ជបណ្ឌិតជាន់ខ្ពស់ ឆ្លើយតបបាននឹងតម្រូវការថែទាំ និងព្យាបាលសុខភាព ជូនប្រជាជនកម្ពុជា ប្រកបដោយគុណភាព ប្រសិទ្ធ ភាព និងវិជ្ជាជីវៈខ្ពស់។ សាកលវិទ្យាល័យ បានទទួលនូវការទទួលស្គាល់ពេញសិទ្ធ ពីគណៈកម្មាធិការទទួល ស្គាល់គុណភាពអប់រំ នៅកម្ពុជា ចំនួន ០២ លើក ដោយលើកទី១ ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ និងលើកទី ២ ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨។ សាកលវិទ្យាល័យ ក៏បានខិតខំជំរុញការងារទទួលស្គាល់គុណភាពកម្រិត កម្មវិធី ពី AUN-QA ផងដែរ ដែលបច្ចុប្បន្ន សាកលវិទ្យាល័យកំពុងត្រៀមលក្ខណៈសម្រាប់ការទទួលការវាយ តម្លៃកម្មវិធីសិក្សា ចំនួន ០៤ រួមមាន៖ កម្មវិធីសិក្សាវេជ្ជបណ្ឌិតទូទៅ កម្មវិធីសិក្សាទន្តបណ្ឌិត កម្មវិធីសិក្សា បរិញ្ញាបត្រឱសថសាស្ត្រ និងកម្មវិធីសិក្សាបរិញ្ញាបត្រគិលានុបដ្ឋាក។

បច្ចុប្បន្នសាកលវិទ្យាល័យ មាននិស្សិតសរុបចំនួន ៩ ០៥៥ នាក់ (នារី ៥ ៦៤៤ នាក់) ក្នុងនោះ និស្សិតអាហារូបករណ៍បង់ថ្លៃជំនួសដោយរាជរដ្ឋាភិបាល ចំនួន ៧៧១ នាក់ (នារី ៥២០ នាក់), និស្សិតអា ហារូបករណ៍បង់ថ្លៃជំនួសដោយ សម្តេចអគ្គមហាសេនាបតីតេជោ និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ចំនួន ១៥៤ នាក់ (នារី ៨២ នាក់) និស្សិតអាហារូបករណ៍បង់ថ្លៃជំនួសដោយ សម្តេចមហាបវរធិបតី និង សលោកជំទាវ បណ្ឌិត ចំនួន ០២ នាក់ (នារី ០០ នាក់) និង ផ្នែកសិក្សាបង់ថ្លៃទូទៅ ចំនួន ៨ ១២៨ នាក់ (៥ ០៤២ នារី នាក់)។

តាមរយៈការសិក្សាក្នុងចំណោមអតីតនិស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខា ភិបាល ដែលបានអនុវត្តចាប់ពីឆ្នាំ២០១៧ មកដល់ឆ្នាំ២០២៦នេះ អត្រានិស្សិតមានការធ្វើ ក្រោយបញ្ចប់ការសិក្សា ពីសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល មានចំនួន ចន្លោះពី ៩២,៥% ដល់ ៩៧,២៦% និងភាគច្រើនលើស លប់នៃនិស្សិតដែលមានការងារធ្វើ គឺបម្រើការងារក្នុងវិស័យសុខាភិបាល។

ខ. ប្រធានបទទី២ អំពីកម្មវិធីសិក្សា និងការបណ្តុះបណ្តាលជំនាញ

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល កំពុងដំណើរការកម្មវិធីសិក្សា សរុប ចំនួន ៥១ កម្មវិធី ដែលមានបែងចែកដូចខាងក្រោម៖

ល.រ.រ	ល.រ	ឈ្មោះកម្មវិធីបណ្តុះបណ្តាល
វេជ្ជបណ្ឌិតឯកទេស		
១	១	វេជ្ជបណ្ឌិតឯកទេសប្រពោធនកម្ម ជាក់ថ្នាំសណ្តំ និង សង្គ្រោះបន្ទាន់

ល.រ.រ	ល.រ	ឈ្មោះកម្មវិធីបណ្តុះបណ្តាល
២	២	វេជ្ជបណ្ឌិតឯកទេសវិកលវិទ្យា
៣	៣	វេជ្ជបណ្ឌិតឯកទេសសម្ភព និង រោគស្ត្រី
៤	៤	វេជ្ជបណ្ឌិតឯកទេសវេជ្ជសាស្ត្រទូទៅ
៥	៥	វេជ្ជបណ្ឌិតឯកទេសវិជ្ជារោគកុមារ
៦	៦	វេជ្ជបណ្ឌិតឯកទេសវិទ្យុសាស្ត្រ និងរូបភាពវេជ្ជសាស្ត្រ
៧	៧	វេជ្ជបណ្ឌិតឯកទេសចក្ខុរោគ
៨	៨	វេជ្ជបណ្ឌិតឯកទេសត្រចៀក ច្រមុះ បំពង់ក
៩	៩	វេជ្ជបណ្ឌិតឯកទេសជំងឺមហារីក
១០	១០	វេជ្ជបណ្ឌិតឯកទេសបេះដូងវិទ្យា
១១	១១	វេជ្ជបណ្ឌិតឯកទេសជំងឺទឹកនោមផ្អែម និងក្រពេញ
១២	១២	វេជ្ជបណ្ឌិតឯកទេសជំងឺថ្លើម ក្រពះ ពោះវៀន
១៣	១៣	វេជ្ជបណ្ឌិតឯកទេសជំងឺសួត
១៤	១៤	វេជ្ជបណ្ឌិតឯកទេសសល្យសាស្ត្រទូទៅ និងប្រព័ន្ធរំលាយអាហារ
១៥	១៥	វេជ្ជបណ្ឌិតឯកទេសសល្យសាស្ត្រឆ្អឹង និងបាក់បែក
១៦	១៦	វេជ្ជបណ្ឌិតឯកទេសសល្យសាស្ត្រកុមារ
១៧	១៧	វេជ្ជបណ្ឌិតឯកទេសសល្យសាស្ត្រប្រព័ន្ធប្រសាទ
១៨	១៨	វេជ្ជបណ្ឌិតឯកទេសសល្យសាស្ត្រប្រព័ន្ធទឹកម៉ូត្រ
១៩	១៩	វេជ្ជបណ្ឌិតឯកទេសជំងឺសើរស្បែក
២០	២០	វេជ្ជបណ្ឌិតឯកទេសសោភ័ណសល្យសាស្ត្រ
២១	២១	វេជ្ជបណ្ឌិតឯកទេសកាយវិភាគ និងកោសិការោគវិទ្យា
២២	២២	វេជ្ជបណ្ឌិតឯកទេសប្រព័ន្ធប្រសាទ
វេជ្ជបណ្ឌិតទូទៅ ទន្តបណ្ឌិត		
២៣	១	វេជ្ជបណ្ឌិតទូទៅ
២៤	២	ទន្តបណ្ឌិត
បរិញ្ញាបត្រជាន់ខ្ពស់		
២៥	១	បរិញ្ញាបត្រជាន់ខ្ពស់វេជ្ជជីវសាស្ត្រ
២៦	២	បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកស្បែក និង គ្រឿងសម្អាង
២៧	៣	បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកជំងឺឆ្លង
២៨	៤	បរិញ្ញាបត្រជាន់ខ្ពស់សុខភាពសាធារណៈ
២៩	៥	បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រផ្នែកអេពីដឺមីសាស្ត្រ

ល.រ.រ	ល.រ	ឈ្មោះកម្មវិធីបណ្តុះបណ្តាល
៣០	៦	បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកពត់ធ្មេញ
៣១	៧	បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវះកាត់ មុខមាត់-ឆ្នឹងថ្ពាម
បរិញ្ញាបត្រ		
៣២	២	បរិញ្ញាបត្រវិទ្យាសាស្ត្រវេជ្ជសាស្ត្រ
៣៣	៣	បរិញ្ញាបត្រវិទ្យាសាស្ត្រទន្តវេទសាស្ត្រ
៣៤	៤	បរិញ្ញាបត្រឱសថសាស្ត្រ
៣៥	៥	បរិញ្ញាបត្រគិលានុបដ្ឋាក
៣៦	៦	បរិញ្ញាបត្រឆ្មប
៣៧	៧	បរិញ្ញាបត្របច្ចេកទេសមន្ទីរពិសោធន៍
៣៨	៨	បរិញ្ញាបត្រព្យាបាលដោយចលនា
៣៩	៩	បរិញ្ញាបត្រសុខភាពសាធារណៈ
៤០	១០	បរិញ្ញាបត្រសណ្តំ ប្រពោធនកម្ម និងសង្គ្រោះបន្ទាន់
៤១	១១	បរិញ្ញាបត្រគិលានុបដ្ឋាកបណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង
៤២	១២	បរិញ្ញាបត្រចក្ខុគិលានុបដ្ឋាកបន្តពីបរិញ្ញាបត្ររង
៤៣	១៣	បរិញ្ញាបត្រព្យាបាលដោយចលនាបណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង
៤៤	១៤	បរិញ្ញាបត្រគិលានុបដ្ឋាក ឆ្មប បន្តពីបរិញ្ញាបត្ររង
៤៥	១៥	បរិញ្ញាបត្របច្ចេកទេសមន្ទីរពិសោធន៍វេជ្ជសាស្ត្របណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង
៤៦	១៦	បរិញ្ញាបត្រគិលានុបដ្ឋាក ឆ្មប បណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង
បរិញ្ញាបត្ររង		
៤៧	១	បរិញ្ញាបត្ររងគិលានុបដ្ឋាក
៤៨	២	បរិញ្ញាបត្ររងឆ្មប
៤៩	៣	បរិញ្ញាបត្ររងព្យាបាលដោយចលនា
៥០	៤	បរិញ្ញាបត្ររងបច្ចេកទេសមន្ទីរពិសោធន៍វេជ្ជសាស្ត្រ
៥១	៥	បរិញ្ញាបត្ររងបច្ចេកទេសវិទ្យុសាស្ត្រ
៥២	៦	បរិញ្ញាបត្ររងវិស្វកម្មវេជ្ជជីវសាស្ត្រ

ចាប់ពីឆ្នាំ២០១៤ មកដល់បច្ចុប្បន្ននេះ សាកលវិទ្យាល័យបានវិនិយោគជាអាទិភាពលើការកែលម្អកម្មវិធីសិក្សា ផ្អែកលើសមត្ថភាព ការវិនិយោគលើហេដ្ឋរចនាសម្ព័ន្ធ សម្ភារៈបង្ហាញត្រាប់ ការវាយតម្លៃនិស្សិត ដើម្បីធានាថា និស្សិតមានទាំងចំណេះដឹង ជំនាញ និងឥរិយាបទសមស្រប សម្រាប់ការផ្តល់សេវា សុខាភិបាលជូនប្រជាពលរដ្ឋ។



រូបទី១៖ ហេដ្ឋារចនាសម្ព័ន្ធបង្ហាញគ្រាប់ នៅស.វ.ស.

បច្ចុប្បន្ន កម្មវិធីសិក្សាចំនួន ៩ បានកែសម្រួល ឱ្យក្លាយជាកម្មវិធីសិក្សាដែលផ្អែកលើ សមត្ថភាព និង បានដាក់ឱ្យអនុវត្ត ដោយក្រសួងសុខាភិបាល៖

១. កម្មវិធីសិក្សាជាតិបរិញ្ញាបត្ររងគិលានុបដ្ឋាក
២. កម្មវិធីសិក្សាជាតិថ្នាក់បរិញ្ញាបត្រគិលានុបដ្ឋាក
៣. កម្មវិធីសិក្សាជាតិថ្នាក់បរិញ្ញាបត្រគិលានុបដ្ឋាកសណ្តំ ប្រពោធនកម្ម និងសង្គ្រោះបន្ទាន់
៤. កម្មវិធីសិក្សាថ្នាក់ជាតិថ្នាក់បរិញ្ញាបត្ររងឆ្មប
៥. កម្មវិធីសិក្សាជាតិថ្នាក់បរិញ្ញាបត្រឆ្មប
៦. កម្មវិធីសិក្សាថ្នាក់ជាតិថ្នាក់បរិញ្ញាបត្រឆ្មបបន្តពីបរិញ្ញាបត្ររង
៧. កម្មវិធីសិក្សាជាតិបរិញ្ញាបត្ររងបច្ចេកទេសមន្ទីរពិសោធន៍វេជ្ជសាស្ត្រ
៨. កម្មវិធីសិក្សាជាតិបរិញ្ញាបត្រវិទ្យាសាស្ត្របច្ចេកទេសមន្ទីរពិសោធន៍វេជ្ជសាស្ត្រ
៩. កម្មវិធីសិក្សាជាតិបរិញ្ញាបត្រឱសថសាស្ត្រ

សាកលវិទ្យាល័យ កំពុងចូលរួមយ៉ាងសកម្មជាមួយក្រសួងសុខាភិបាល បន្តកែសម្រួលកម្មវិធីសិក្សាផ្សេងៗទៀត ដើម្បីឱ្យកម្មវិធីសិក្សាទាំងអស់ ដែលអនុវត្តនៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ជាកម្មវិធីសិក្សា ដែលផ្តោតលើសមត្ថភាពជាគោល។

សាកលវិទ្យាល័យ បានបង្កើត និងដាក់ដំណើរការកម្មវិធីអន្តរជាតិចំនួន ០៣ កម្មវិធីសិក្សា ដែលរួមមាន កម្មវិធីសិក្សាបរិញ្ញាបត្រវិទ្យាសាស្ត្រវេជ្ជសាស្ត្រ កម្មវិធីសិក្សាបរិញ្ញាបត្រឱសថសាស្ត្រ និង កម្មវិធីសិក្សា

គិលានុបដ្ឋាក ដើម្បីជំរុញការផ្លាស់ប្តូរការសិក្សានិស្សិត និងការប្រកួតប្រជែងអាហារូបករណ៍ឱ្យបានកាន់តែច្រើន ជាពិសេសការឈានទៅរកការផ្លាស់ប្តូរក្រៅឌីត ជាមួយ សាកលវិទ្យាល័យ នានា ទាំងជាតិ និងអន្តរជាតិ។

គ. ប្រធានបទទី៣ អំពីបច្ចេកវិទ្យា និងកិច្ចសហប្រតិបត្តិការអន្តរជាតិ

សាកលវិទ្យាល័យ មានកិច្ចសហប្រតិបត្តិការទូលំទំលាយ ជាមួយបណ្តាប្រទេសទាំងអស់។ បច្ចុប្បន្ន សាកលវិទ្យាល័យ មានដៃគូសរុប ចំនួន ១០៣ អង្គភាព (ដោយរាប់បញ្ចូលទាំងបណ្តាញសិក្សាធិការជាតិ និងអន្តរជាតិ)។ ប្រទេសបារាំង ជាដៃគូយ៉ាងសំខាន់ របស់សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងមានទំនាក់ទំនងរឹងមាំ ដូចបណ្តាប្រទេសជាមិត្តនានា។

ក្នុងចំណោមកម្មវិធីទាំង៥២ ខាងលើ កម្មវិធីសិក្សាចំនួន ០២ ជាកម្មវិធីសិក្សា ដែលនិស្សិតអាចទទួលបានសញ្ញាបត្រពីសាកលវិទ្យាល័យពីរ (Double diplôme) ក្រោមក្របខ័ណ្ឌសហការជាមួយសាកលវិទ្យាល័យបារាំង គឺ៖

1. បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកស្បែក និង គ្រឿងសម្អាង ៖ ជាកិច្ចសហប្រតិបត្តិការរវាងសាកលវិទ្យាល័យ វិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងសាកលវិទ្យាល័យ Aix-Marseilles។
2. កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកជំងឺឆ្លង ដែលជាកិច្ចសហប្រតិបត្តិការរវាងសាកលវិទ្យាល័យវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងសាកលវិទ្យាល័យ Paris Saclay។

បន្ថែមនេះ ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល នៃប្រទេសបារាំង ស្ថានទូតបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា ចាប់ពីឆ្នាំ២០១៤មក សាកលវិទ្យាល័យ បានបង្កើនចំនួននិស្សិតថ្នាក់វេជ្ជបណ្ឌិត ឯកទេស ទៅធ្វើកម្មសិក្សា ជារៀងរាល់ឆ្នាំ ប្រមាណពី២០ នាក់ក្នុងមួយឆ្នាំ មកដល់ ៨០ នាក់ ក្នុងមួយឆ្នាំ។ បច្ចុប្បន្ន និស្សិតស.វ.ស. សរុប ចំនួន ១ ៣២២ នាក់ បានអនុវត្តកម្មសិក្សាតាមមន្ទីរពេទ្យ អង្គភាពស្រាវជ្រាវនានា នៅប្រទេសបារាំង។

ឃ. ប្រធានបទទី៤ អំពីការស្រាវជ្រាវនិងបណ្តាញដៃគូសាកល

ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល បានបង្កើតឱ្យមានមជ្ឈមណ្ឌលស្រាវជ្រាវសុខភាពសាកល ដែលនឹងដើរតួនាទីយ៉ាងសំខាន់ ជាសេនាធិការរបស់ក្រសួងសុខាភិបាល ក្នុងការសំយោគនូវឯកសារវិទ្យាសាស្ត្រ គោលនយោបាយ យុទ្ធសាស្ត្រ មគ្គុទេសន៍ណែនាំនានា ដែលបាន និងកំពុងប្រើប្រាស់នៅលើពិភពលោកដែលទាក់ទងនឹងបញ្ហាសុខភាពសាកល និងលើកកម្ពស់ការងារស្រាវជ្រាវ នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ប្រកបដោយឧត្តមភាព។

សាកលវិទ្យាល័យ បានសហការជាមួយដៃគូនានា ដ៏មានសក្តានុពល ជាច្រើន ក្នុងការអនុវត្តការងារស្រាវជ្រាវរួមគ្នា។ ដៃគូសហការសំខាន់ៗ រួមមាន ភ្នាក់ងារ: Infectious Diseases Research Agency (ANRS MIE), Institut de Recherche pour le Développement (IRD), National University of Singapore (NUS), Merieux Foundation, Pierre Fabre Foundation, University of New South Wales, សាកលវិទ្យាល័យនានា ជាច្រើនទៀតទាំងក្នុង និងក្រៅប្រទេស។

បច្ចុប្បន្ន សាកលវិទ្យាល័យ បានទទួលការឧបត្ថម្ភថវិកា ពីបណ្តាញផ្តល់ថវិកា និងដៃគូនានា អនុវត្តគម្រោងសរុប ចំនួន ១៥ ទៅ២០គម្រោង ក្នុងមួយឆ្នាំៗ និងបានបោះផ្សាយលទ្ធផលស្រាវជ្រាវ ក្នុងទិន្នានុវត្តវិទ្យាសាស្ត្រសរុប ប្រមាណពី១០ ទៅ១៥ អត្ថបទស្រាវជ្រាវ ក្នុងមួយឆ្នាំៗ។

៣.ទិសដៅការងារបន្ត ទាក់ទងនឹងការងារបណ្តុះបណ្តាល និងស្រាវជ្រាវ

ក្នុងគោលបំណងផលិតមូលធនមនុស្សក្នុងវិស័យសុខាភិបាល ឱ្យកាន់តែមានសមត្ថភាព ក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល បន្តខិតខំដូចខាងក្រោម៖

- អនុវត្តការកែលម្អកម្មវិធីសិក្សា ដែលកំពុងអនុវត្តនៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ឱ្យផ្តោតលើសមត្ថភាព
- បន្តអភិវឌ្ឍកម្មវិធីសិក្សាថ្មីៗបន្ថែមទៀត ឆ្លើយតបនឹងតម្រូវការទីផ្សារ សង្គម និងជា ពិសេសជំរុញការប្រកួតប្រជែងទីផ្សារការ ក្នុងតំបន់
- បន្តជំរុញកម្មវិធីអន្តរជាតិ ដែលមានស្រាប់ និងពង្រីកកម្មវិធីអន្តរជាតិ សម្រាប់ជំនាញមួយចំនួនស្របតាមការចាំបាច់ ដើម្បីឈានទៅរកការផ្លាស់ប្តូរក្រៅឹត ជាមួយ សាកលវិទ្យាល័យ នានា ទាំងជាតិ និងអន្តរជាតិ
- បន្តពង្រឹងសមត្ថភាពគរុកោសល្យដល់គ្រូ ឆ្លើយតបនឹងការបណ្តុះបណ្តាលផ្អែកលើ សមត្ថភាព
- បន្តពង្រឹងក្រមសីលធម៌វិជ្ជាជីវៈ ដល់គ្រូ និងនិស្សិត
- សមាហរណកម្មការបង្រៀនពីចម្ងាយតាមប្រព័ន្ធ LearningManagementSystem និងផ្តាល់ជំរុញបង្កើនប្រសិទ្ធភាព នៃការរៀន និងបង្រៀន
- បន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធបង្ហាញគ្រាប់
- ពង្រឹងគុណភាពកម្មសិក្សានិស្សិត តាមរយៈការរៀបចំអនុវត្ត Portfolio និងការបង្កើនកិច្ចសហការស្មិតរមួតជាមួយទីតាំងសម្ព័ន្ធកម្មសិក្សា
- បន្តពង្រឹងគុណភាព និងទំនើបកម្មការវាយតម្លៃនិស្សិត ដោយរៀបចំការប្រឡងតាមប្រព័ន្ធកុំព្យទ័រ ការរៀបចំការប្រឡងគ្លីនីក Objective structured clinical examination (OSCE)
- ពង្រឹងការធានាគុណភាព ដោយបន្តរក្សាការទទួលស្គាល់គុណភាពនៅកម្រិតជាតិ និងឈានទៅរកការទទួលស្គាល់គុណភាពបណ្តុះបណ្តាលកម្រិតតំបន់ និងអន្តរជាតិ
- បន្តពង្រីកកិច្ចសហប្រតិបត្តការស្រាវជ្រាវ ដោយបង្កើតឱ្យមាន Plateform ប្រមូលផ្តុំ និង ផ្តល់បរិស្ថានគាំទ្រដ៏មានសក្តានុពល សម្រាប់ការងារស្រាវជ្រាវនៅសាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាលតាមរយៈការកំណត់នូវផែនការយុទ្ធសាស្ត្ររបស់មជ្ឈមណ្ឌលស្រាវជ្រាវនេះ។
- រៀបចំបើកដំណើរការមន្ទីរពេទ្យសាកលវិទ្យាល័យដើម្បីជាទីតាំងបណ្តុះបណ្តាល និងជា ទីតាំងស្រាវជ្រាវ។

CADT បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា
Cambodia Academy of Digital Technology

ទោយការណ៍ឥឡ្ឍនភាពរបស់ បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (២០១៤-២០២៦)

I. សេចក្តីផ្តើម

បណ្ឌិត្យសភា CADT ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៤ ដោយមានឈ្មោះដើមថា វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ហៅកាត់ថា NIPTICT បំពេញតួនាទីជាសេនាធិការផ្ទាល់របស់ ក.ប.ទ. ក្នុងការអប់រំបណ្តុះបណ្តាលកម្រិតឧត្តមសិក្សានិងស្រាវជ្រាវលើជំនាញក្នុងវិស័យដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួង។ ដោយយល់ឃើញអំពីសារៈសំខាន់របស់មូលធនមនុស្សក្នុងការជំរុញការអភិវឌ្ឍវិស័យឌីជីថល និងជាការដោះស្រាយបញ្ហាខ្វះខាតអ្នកជំនាញនិងគម្លាតជំនាញឌីជីថលនៅកម្ពុជា ក.ប.ទ. បានសម្រេចលើកសំណើប្រែក្លាយវិទ្យាស្ថាន NIPTICT ទៅជាបណ្ឌិត្យសភា CADT ដែលត្រូវបង្កើតដោយព្រះរាជក្រឹត្យលេខ នស/រកត/០១២១/០០៣ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០២១ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ ក.ប.ទ. និងអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយបំពេញមុខងារក្នុងការផ្តល់ការអប់រំបណ្តុះបណ្តាលលើជំនាញឌីជីថលដល់និស្សិត មន្ត្រីរាជការ ព្រមទាំងធ្វើការស្រាវជ្រាវ និងនវានុវត្តន៍វិស័យបច្ចេកវិទ្យាឌីជីថល ចូលរួមលើកកម្ពស់ប្រព័ន្ធនវានុវត្តន៍ជាតិ។ បណ្ឌិត្យសភា CADT មានវិទ្យាស្ថានក្រោមឱវាទចំនួន ៣ និងនាយកដ្ឋានចំនួន ១ គឺ៖ វិទ្យាស្ថានបច្ចេកវិទ្យាឌីជីថល វិទ្យាស្ថានអភិបាលកិច្ចឌីជីថល វិទ្យាស្ថានស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល និងនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ។

II. សកម្មភាពដែលសម្រេចបាន

១. អភិបាលកិច្ច ស្វ័យភាព និងការធានាគុណភាព

ក. អភិបាលកិច្ច និងស្វ័យភាព

បណ្ឌិត្យសភា CADT មានបេសកកម្មចម្បងគឺ ដឹកនាំ គ្រប់គ្រង អភិវឌ្ឍន៍ការសិក្សាស្រាវជ្រាវ អប់រំ និងនវានុវត្តន៍លើបច្ចេកវិទ្យាឌីជីថលព្រមទាំងចូលរួមលើកកម្ពស់ប្រព័ន្ធនវានុវត្តន៍ជាតិ ជាមួយនឹងចក្ខុវិស័យឱ្យក្លាយជាស្ថាប័នអប់រំសាធារណៈ និងស្រាវជ្រាវឈានមុខគេ ដែលអភិវឌ្ឍធនធានមនុស្សឌីជីថលប្រកបដោយឧត្តមភាព និងអ្នកច្នៃប្រឌិត ដើម្បីជំរុញកម្ពុជាឆ្ពោះទៅរកសង្គមឌីជីថល។ បច្ចុប្បន្ន បណ្ឌិត្យសភា CADT មានបណ្តុះបណ្តាលលើកម្មវិធីចំនួន ២កម្រិត គឺថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ដោយក្នុងនោះកម្រិតបរិញ្ញាបត្របានផ្តោតការយកចិត្តទុកដាក់ជាខ្លាំងលើជំនាញឯកទេសបច្ចេកវិទ្យាឌីជីថលចំនួន ៥ រួមមាន៖ វិស្វកម្មទូរគមនាគមន៍និងបណ្តាញ (Telecommunications & Networking Engineering) សន្តិសុខសាយប័រ (Cybersecurity) វិស្វកម្មសុសវែរ (Software Engineering) បញ្ញាសិប្បនិម្មិតនិងវិទ្យាសាស្ត្រ

ទិន្នន័យ (AI and Data Science) ពាណិជ្ជកម្មអេឡិចត្រូនិក (e-Commerce) ដែលជំនាញឯកទេសទាំងនេះពុំទាន់ផ្តល់នៅឡើយទេ នៅតាមគ្រឹះស្ថានឧត្តមសិក្សារដ្ឋនិងឯកជនមួយចំនួន។ ចំពោះថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ មានចំនួន ៣ឯកទេស ដូចជា៖ វិទ្យាសាស្ត្រទិន្នន័យនិងបញ្ញាសិប្បនិម្មិត បច្ចេកវិទ្យាឌីជីថល និងសន្តិសុខសាយប័រ។

បណ្ឌិត្យសភា CADT ក៏បានបង្កើតឡើងនូវកម្មវិធីចំនួនពីរ ក្នុងគោលបំណងបញ្ជ្រាបនិងផ្សព្វផ្សាយឱ្យកាន់តែទូលាយជូនដល់សិស្សានុសិស្សនៅតាមវិទ្យាល័យមួយចំនួនធំដែលនៅឆ្ងាយពីទីប្រជុំជន ដើម្បីឱ្យកាន់តែយល់ដឹងពីវិស័យបច្ចេកវិទ្យាឌីជីថល និងងាកមកចាប់អារម្មណ៍ចង់រៀនជំនាញបច្ចេកវិទ្យាឌីជីថលនេះឱ្យកាន់តែច្រើនស្របនឹងយុគសម័យឌីជីថល។ កម្មវិធីទាំងពីរនេះមានឈ្មោះថា **១.កម្មវិធីអ្នកស្ម័គ្រចិត្តបច្ចេកវិទ្យាឌីជីថលកម្ពុជា** ដែលទទួលបានការគាំទ្រពីក្រសួងប្រៃសនីយ៍និងទូរគមនាគមន៍យ៉ាងពេញទំហឹងក្នុងការអនុវត្តគម្រោងនេះ **២.កម្មវិធី KHODING HERO** ដែលមានការចូលរួមសហការពីអង្គការ USAID ផងដែរ ដោយបានបញ្ជូននិស្សិតប្រមាណ ៤០០នាក់ ចុះទៅបណ្តុះបណ្តាលដល់សិស្សានុសិស្សនៅតាមវិទ្យាល័យមួយចំនួនក្នុងខេត្តកណ្តាល កំពង់ឆ្នាំង សៀមរាប បាត់ដំបង បន្ទាយមានជ័យ ស្វាយរៀង និងតាកែវ ដែលមានសិស្សានុសិស្ស ប្រជាជន មន្ត្រីមូលដ្ឋាន បានចុះឈ្មោះចូលរៀនរាប់ម៉ឺននាក់។

បណ្ឌិត្យសភា CADT បានបង្កើតឱ្យមានសមាគមនិស្សិត CADT ចាប់តាំងពីឆ្នាំ២០១៤ រហូតមកដល់បច្ចុប្បន្ន ដោយអនុញ្ញាតឱ្យនិស្សិតបានចូលរួមបង្កើតនូវកម្មវិធីជួយដល់សង្គម តាមរយៈការបង្កើតជាក្លិបសិក្សាជាច្រើនសម្រាប់គាំទ្រដល់និស្សិតដែលកំពុងសិក្សា។ នៅក្នុងឆ្នាំ២០២៣ បណ្ឌិត្យសភា CADT បានសម្រេចបង្កើតគណៈកម្មការទ្រទ្រង់ជីវិតនិស្សិត ដើម្បីជួយសម្របសម្រួលរាល់ការស្នើសុំរបស់និស្សិតទាក់ទងទៅនឹងការសិក្សាប្រចាំថ្ងៃ។ បណ្ឌិត្យសភា CADT បានបង្កើតនូវកម្មវិធីលើកទឹកចិត្តដល់សិស្សអាទិភាពនារីដែលមានបំណងចង់ចូលសិក្សា ដោយផ្តល់ជូននូវការបញ្ចុះតម្លៃ ៥០% លើថ្លៃសិក្សារហូតដល់រៀនចប់ថ្នាក់បរិញ្ញាបត្រ។

សម្រាប់និស្សិតដែលបានប្រឡងជាប់តេស្តវាស់ស្ទង់សមត្ថភាព ហើយបានចុះឈ្មោះចូលរៀននៅបណ្ឌិត្យសភា CADT នឹងទទួលបានកុំព្យូទ័រយួរដៃថ្មីមួយគ្រឿងសម្រាប់គាំទ្រដល់ការសិក្សារហូតដល់ចប់កម្មវិធីសិក្សា។ រីឯនិស្សិតដែលមានបំណងចង់សិក្សានៅបណ្ឌិត្យសភា CADT ប៉ុន្តែពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់ថ្លៃសិក្សា បណ្ឌិត្យសភា CADT ក៏បានបានបង្កើតការគាំទ្រលើកម្ចីសិក្សាដោយមិនមានការប្រាក់រហូតដល់រៀនចប់មួយកម្មវិធីសិក្សាផងដែរ។

ខ. ការធានាគុណភាព

នៅក្នុងឆ្នាំ២០២៣ បណ្ឌិត្យសភា CADT បានធ្វើការកែសម្រួលនូវបទបញ្ជាផ្ទៃក្នុងរបស់និស្សិត ដែលតម្រូវឱ្យនិស្សិតសិក្សានៅបណ្ឌិត្យសភា CADT ទាំងអស់ ត្រូវមករៀនឱ្យបានទៀងទាត់ មិនអនុញ្ញាតឱ្យមកយឺត មិនអនុញ្ញាតឱ្យធ្លាក់មុខវិជ្ជាណាមួយដាច់ខាតមុននឹងចុះកម្មសិក្សាលើកទី២ បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជាពិសេស គឺតម្រូវឱ្យប្រឡងជាប់តេស្តភាសាអង់គ្លេសតាមស្តង់ដា IELTS យ៉ាងតិច ៥.០។

នៅក្នុងឆ្នាំ២០២៤ គណៈគ្រប់គ្រងនៃបណ្ឌិត្យសភា CADT បានសម្រេចបង្កើតនូវគណៈកម្មការ ពិនិត្យនិងវាយតម្លៃបញ្ចប់ការសិក្សារបស់និស្សិត ដោយត្រូវអនុវត្តឱ្យបាននូវការកិច្ចសំខាន់ដូចជា៖ ១.ត្រួតពិនិត្យពិន្ទុ

និងលក្ខន្តិក:ដែលជាតម្រូវការសម្រាប់ឆ្នាំសិក្សានីមួយៗ ២.វាយតម្លៃការបញ្ចប់ការសិក្សារបស់និស្សិតចាប់តាំងពីថ្នាក់ឆ្នាំសិក្សាមូលដ្ឋានរហូតដល់បញ្ចប់ការសិក្សា និង ៣.ពិនិត្យ និងសម្រេចចុងក្រោយលើលទ្ធផលសិក្សារបស់និស្សិត ដើម្បីឱ្យជាក់ច្បាស់ថានិស្សិតពិតជាមានសមត្ថភាពអាចបញ្ចប់ការសិក្សាដោយជោគជ័យពិតប្រាកដមែន។

នៅបណ្ឌិត្យសភា CADT បន្ទប់សិក្សាត្រូវបានរៀបចំជា ៣ប្រភេទ ដោយក្នុងនោះមាន ១.បន្ទប់សម្រាប់បង្រៀននិងរៀនទ្រឹស្តី ២.បន្ទប់សម្រាប់បង្រៀននិងរៀនអនុវត្ត និង ៣.បន្ទប់សម្រាប់បង្រៀននិងរៀនក្នុងម៉ោងពិភាក្សាជាក្រុម ដែលបានផ្តល់ភាពងាយស្រួលដល់សាស្ត្រាចារ្យ និងនិស្សិតទាំងការបង្រៀននិងរៀនប្រកដដោយគុណភាព។

និស្សិតដែលសិក្សានៅបណ្ឌិត្យសភា CADT គឺតម្រូវឱ្យធ្វើការចុះកម្មសិក្សាផ្គាល់ជាមួយក្រុមហ៊ុនចំនួនពីរលើក។ លើកទីមួយ ត្រូវចុះកម្មសិក្សានៅក្នុងវគ្គសិក្សាទី១ នៃឆ្នាំទី៣ មានរយៈពេល ៣ខែ (ក្នុងករណីនិស្សិតធ្លាក់កម្មសិក្សាលើកទី១ នោះមានន័យថានិស្សិតត្រូវរៀនត្រួតក្នុងឆ្នាំទី៣) និងលើកទី២ ត្រូវចុះកម្មសិក្សានៅឆ្នាំទី៤ នៃវគ្គសិក្សាទី២ មានរយៈពេលពី ៤ ទៅ ៦ខែ ដែលជាឆ្នាំបញ្ចប់ថ្នាក់បរិញ្ញាបត្រ។

ក្នុងឆ្នាំ២០២៣ បណ្ឌិត្យសភា CADT បានបង្កើតមជ្ឈមណ្ឌលការងារ ក្នុងគោលបំណងពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន និងសហគ្រាស ដើម្បីសម្របសម្រួលកម្មវិធីហាត់ការ និងការចុះកម្មសិក្សាផ្តល់ការប្រឹក្សាអាជីពការងារ អភិវឌ្ឍន៍ជំនាញភាសាបរទេស ជំនាញទន់ គ្រប់គ្រង និងរៀបចំបណ្ណាល័យ។

ជារៀងរាល់ឆ្នាំថ្នាក់ដឹកនាំនៃបណ្ឌិត្យសភាតែងតែយកចិត្តទុកដាក់ទៅលើកម្មវិធីសិក្សា និងធ្វើការកែសម្រួលជាប់ជាប្រចាំ ដើម្បីឆ្លើយតបទៅនឹងការជឿនលឿននៃបច្ចេកវិទ្យាឌីជីថលក្នុងសម័យបច្ចុប្បន្ន។

បណ្ឌិត្យសភា CADT បានពង្រឹងគុណភាពបណ្តុះបណ្តាលដោយអញ្ជើញសាស្ត្រាចារ្យឯកទេសពីសាកលវិទ្យាល័យដៃគូក្នុងតំបន់និងអន្តរជាតិមានដូចជា ៖ University of Grenoble Alpes ប្រទេសបារាំង Singapore Institute of Technology ប្រទេសសឹង្ហបុរី និងប្រទេសវៀតណាម ព្រមទាំងបង្កើតជាបណ្តាញអ្នកជំនាញជាន់ខ្ពស់ពីក្រុមហ៊ុននានា ដើម្បីធ្វើជាគ្រូឯកទេសនៅបណ្ឌិត្យសភា CADT ព្រមទាំងពង្រឹងនូវសមត្ថភាពរបស់សាស្ត្រាចារ្យផ្ទៃក្នុងដោយបន្ថែមនូវចំនួនសាស្ត្រាចារ្យដែលមានសញ្ញាបត្រថ្នាក់បណ្ឌិតនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

២. ការបណ្តុះបណ្តាល

ក្នុងរយៈពេល ១០ ឆ្នាំនេះ បណ្ឌិត្យសភា CADT បានបំពេញបេសកកម្មស្នូលរបស់ខ្លួនលើការបណ្តុះបណ្តាលនិស្សិតសរុបជាង ២ ០០០នាក់ លើជំនាញបច្ចេកវិទ្យាឌីជីថលកម្រិតខ្ពស់ ដែលមានការទទួលស្គាល់ទាំងថ្នាក់ជាតិនិងអន្តរជាតិ ជាពិសេស គឺបានបញ្ជូននិស្សិតចូលរួមការប្រកួតប្រជែងកម្មវិធីផ្សេងៗ ដែលក្នុងនោះទទួលបានជ័យលាភី៖ ១.ទទួលបានជ័យលាភីជើងឯកលេខមួយថ្នាក់តំបន់ក្នុងកម្មវិធីប្រកួតប្រជែងប

ច្នៃកវិទ្យាតាមដានទឹកទន្លេមេគង្គ Mekong River Water Technology Competition ២.ទទួលបានពានរង្វាន់លេខមួយក្នុងកម្មវិធីប្រកួតប្រជែងធុរកិច្ចថ្មីឌីជីថល Smart Start ៣.ទទួលបានពានរង្វាន់លេខមួយក្នុងការប្រកួតប្រជែងវិទ្យាសាស្ត្រទិន្នន័យ Data Science របស់ក្រុមហ៊ុន AWS ៤. ទទួលបានជ័យលាភីលេខ១ និងជ័យលាភីលេខ៣ លើការប្រកួតប្រជែងក្នុងកម្មវិធី ASEAN CYBER SHIELD HACKING CONTEST 2023 រៀបចំឡើងនៅប្រទេសឥណ្ឌូណេស៊ី ៥. ទទួលបានជ័យលាភីក្រុមឆ្នើមក្នុងកម្មវិធី Huawei ICT Competition Regional Final Exam 2023-2024 និង ៦.ទទួលបានជ័យលាភីលេខមួយក្នុងការប្រកួតកម្មវិធីយុវជន២១ ក្រោមប្រធានបទ "**សហគ្រិនឌីជីថល**"។

ក. ការបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ទិន្នន័យនិស្សិតដែលបានចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចាប់ពីឆ្នាំ២០២៤ ដល់ឆ្នាំ ២០២៦

ចំនួននិស្សិត	បញ្ញាសិប្បនិម្មិត និងវិទ្យាសាស្ត្រទិន្នន័យ	បច្ចេកវិទ្យាឌីជីថល	សន្តិសុខសាយប័រ	សរុប
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់	៣១	១១	កំពុងជ្រើសរើស	**៤២**

ខ. ការបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រ

ទិន្នន័យនិស្សិតដែលបានចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្រយៈពេល១០ឆ្នាំ ចុងក្រោយចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ២០២៦

	ឯកទេស						
ឆ្នាំសិក្សា	**វិទ្យាសាស្ត្រកុំព្យូទ័រ**	**វិស្វកម្មសុសវ៉ែរ**	**បញ្ញាសិប្បនិម្មិត និងវិទ្យាសាស្ត្រទិន្នន័យ**	**ពាណិជ្ជកម្មអេឡិចត្រូនិក**	**វិស្វកម្មទូរគមនាគមន៍ និងបណ្តាញ**	**សន្តិសុខសាយប័រ**	**សរុប**
២០១៦-២០១៧	២៨			៣៤	៣៦		៩៨
២០១៧-២០១៨	៥២			៣១	២៤		១០៧
២០១៨-២០១៩	៤៨			២៥	៥៦		១២៩

២០១៩-២០២០	៥២			៥៦	២៦		១៣៤
២០២០-២០២១	៧០			៥៥	៣៩		១៦៤
២០២១-២០២២		៦៩	៣០	២៨		២៤	១៥១
២០២២-២០២៣		៩៩	៥៥	៤៩	២៧	២៥	២៥៥
២០២៣-២០២៤		១៥១	៥១	៦៨	១៨	៧៤	៣៦៦
២០២៤-២០២៥		១៧២	៥៥	៦០	៣២	៥៩	៣៧៨
២០២៥-២០២៦		១០៦	៩១	៣៨	៤៣	៩៥	៣៧៣
សរុប	**២៥០**	**៦០១**	**២៨២**	**៤៤៤**	**៣០១**	**២៧៧**	**២ ១៥៥**

គ. និស្សិតបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រដោយជោគជ័យ

ទិន្នន័យនិស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ

	ឯកទេស						
ចំនួននិស្សិតបញ្ចប់ការសិក្សា	**វិទ្យាសាស្ត្រកុំព្យូទ័រ**	**វិស្វកម្មសុសវែរ**	**បញ្ញាសិប្បនិម្មិត និងវិទ្យាសាស្ត្រទិន្នន័យ**	**ពាណិជ្ជកម្មអេឡិចត្រូនិក**	**វិស្វកម្មទូរគមនាគមន៍ និងបណ្តាញ**	**សន្តិសុខសាយប័រ**	**សរុប**
ថ្នាក់បរិញ្ញាបត្រ	១៩១	៥៤	២១	២០៦	១១៤	២៤	**៦១០**

ផ្អែកលើទិន្នន័យដែលប្រមូលបាននៅក្នុងឆ្នាំ២០២៤ ហើយតាមការអង្កេត និស្សិត ៩៩% ទទួលបានការងារត្រូវនឹងជំនាញរបស់ខ្លួន នៅតាមក្រសួងស្ថាប័នរដ្ឋនិងក្រុមហ៊ុនឯកជនក្នុងវិស័យធនាគារ វិស័យឌីជីថល និងវិស័យអប់រំព្រមទាំងទទួលបានប្រាក់ខែជាមធ្យម ៤៥០ដុល្លារ។

៣. បច្ចេកវិទ្យា និង កិច្ចសហប្រតិបត្តិការអន្តរជាតិ

ក្នុងរយៈពេល១០ឆ្នាំកន្លងមកនេះ បណ្ឌិត្យសភា CADT បានខិតខំពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទាំងក្នុងនិងក្រៅប្រទេសដើម្បីទទួលបាននូវការបណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាព ការផ្លាស់ប្តូរនិស្សិត និងបុគ្គលិកសិក្សា អាហារូបករណ៍ កម្មសិក្សា ការអភិវឌ្ឍកម្មវិធីសិក្សា ការផ្ទេរបច្ចេកវិទ្យា និងការភ្ជាប់ជាមួយវិស័យឯកជន ដែលជួយពង្រឹងគុណភាពអប់រំ ស្រាវជ្រាវ និងកត្តាជាច្រើនដែលគាំទ្រដល់និស្សិត។ សម្រាប់ក្រុមហ៊ុននិងស្ថាប័នដែលបណ្ឌិត្យសភា CADT ធ្វើកិច្ចសហប្រតិបត្តិការជាមួយមានដូចជា University of California, Berkeley, Glasgow Caledonian University, EUROCHAM, China Academy of Information and Communications Technology, Beijing University of Post and Telecommunications, Kangwon National University, Gunma University, NARA Institute of Science and Technology, University Beihang, -Global Entrepreneurship Network, Sala Tech Digital Solutions (Cambodia) Co., Ltd, Smart, Methane, Huawei, Microsoft, Book Me Bus, biz solution, path mazing, ធនាគារ ហ្វីលីព កីអិលស៊ី សមាគមសហគ្រិនវ័យក្មេងកម្ពុជា (YEAC) ក្រុមហ៊ុន PillTech វិទ្យាស្ថានជាតិអប់រំពិសេស (NISE) វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនបាត់ដំបង។

៤. ការស្រាវជ្រាវ និងបណ្តាញដៃគូសាកល

វិទ្យាស្ថានស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថលនៃបណ្ឌិត្យសភា CADT ជាគ្រឹះស្ថានស្រាវជ្រាវនិងនវានុវត្តន៍សាធារណៈជាន់ខ្ពស់ដំបូងដែលផ្តោតលើបច្ចេកវិទ្យាឌីជីថល។ ចាប់តាំងពីឆ្នាំ២០១៥ ស្នាដៃនៃការស្រាវជ្រាវនេះ កំពុងត្រូវបានប្រើប្រាស់ក្នុងគម្រោងគាំទ្រដល់ការអប់រំ ជាពិសេសការអប់រំដល់ជនមានពិការភាព វិស័យសុខាភិបាល វិស័យកសិកម្ម និងវិស័យហិរញ្ញវត្ថុនិងធនាគារផងដែរ។ វិទ្យាស្ថានមានអ្នកស្រាវជ្រាវពេញម៉ោងចំនួន ៣៨នាក់ កំពុងធ្វើការស្រាវជ្រាវនិងអភិវឌ្ឍន៍ ដោយផ្តោតលើការប្រើប្រាស់បច្ចេកវិទ្យា បញ្ញាសិប្បនិម្មិត (AI) វិទ្យាសាស្ត្រទិន្នន័យ (Data Science) អ៊ីនធឺណិតនៃវត្ថុ (IoT) និងរ៉ូបូទិក (Robotic)។ ដៃគូសហការលើគម្រោងស្រាវជ្រាវជាមួយវិទ្យាស្ថានស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល នៃបណ្ឌិត្យសភា CADT រួមមាន៖ បណ្តាញ ASEAN IVO វិទ្យាស្ថាន IRD CIRAD និងសាកលវិទ្យាល័យមួយចំនួននៅប្រទេសបារាំង ចិន កូរ៉េខាងត្បូង ជប៉ុន និងក្នុងតំបន់អាស៊ាន។ ក្នុងនោះ គម្រោងសំខាន់ៗដែលវិទ្យាស្ថានកំពុងអនុវត្ត មានជាអាទិ៍៖

- គម្រោងប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត ដើម្បីបម្រើដល់ការសិក្សារបស់កុមារមានពិការភាពគថ្លង់ និងខ្សោយគំហើញ នៅវិទ្យាស្ថានជាតិអប់រំពិសេសនៃក្រសួងអប់រំ យុវជន និងកីឡា រួមមាន៖ ប្រព័ន្ធបកប្រែភាសាកាយវិការខ្មែរ (Khmer Sign Language Recognition) ម៉ាស៊ីនបកប្រែភាសាខ្មែរប្រៃយ៍ (Khmer Braille Machine Translation) ដែលទទួលបានមេដាយមាស ASEAN Digital Awards 2025 ពានរង្វាន់ Best Digital Research 2024 និង Best Accessibility Awards នៅសន្និសីទបញ្ញាសិប្បនិម្មិតពិភពលោកឆ្នាំ២០២៤

- គម្រោង CAMPRA សម្រាប់ព្យាករណ៍ភាពស៊ាំថ្នាំអង់ទីប៊ីយោទិច ដែលជាគម្រោងសហការជាមួយសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល មន្ទីរពេទ្យកាល់ម៉ែត និងដៃគូមួយចំនួនពីប្រទេសបារាំងរួមមាន៖ SESSTIM/INSERM/IRD/AMU ដែលបានទទួលបានពានរង្វាន់ Best Digital Research 2026
- គម្រោងប្រើប្រាស់បញ្ញាសិប្បនិម្មិតក្នុងវិស័យកសិកម្ម HealthyRice សម្រាប់ពិនិត្យមើលជំងឺដំណាំស្រូវដែលជាគម្រោងសហការ ជាមួយវិទ្យាស្ថានស្រាវជ្រាវសម្រាប់ការអភិវឌ្ឍ (IRD) របស់បារាំង សាកល-វិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

III. បញ្ហាប្រឈម និងដំណោះស្រាយ

ក្នុងការរៀបចំផែនការសេកម្មភាព និងស្នើសុំកិច្ចសហការពីនិស្សិតដែលបានបញ្ចប់ការសិក្សាពីការប្រមូលទិន្នន័យការងាររបស់និស្សិតក្រោយបញ្ចប់ការសិក្សាគឺនៅតែជាបញ្ហាប្រឈមដដែរ ព្រោះចំនួននិស្សិតដែលបានចូលរួមបំពេញព័ត៌មាននៅក្នុងកម្រងសំណួរគឺមិនទាន់គ្រប់ទៅតាមតម្រូវការដែលបានចង់បាន។ ដូចនេះ ជាទូទៅ ដើម្បីដោះស្រាយបញ្ហានេះ ក្រុមការងារតែងតែធ្វើការពន្យារពេលនៃការប្រមូលទិន្នន័យ និងពេលខ្លះត្រូវព្យាយាមទាក់ទងទៅកាន់និស្សិតផ្ទាល់ ឬអាណាព្យាបាលនិស្សិត និងបងប្អូនមិត្តភក្តិនិស្សិតផងដែរ។

ការប្រឈមនឹងការស្វែងរកក្រុមហ៊ុន ឬស្ថាប័នសម្រាប់ឱ្យនិស្សិតដែលត្រូវចុះកម្មសិក្សាផ្ទាល់នៅតាមក្រុមហ៊ុន និងស្ថាប័ន ព្រោះជារៀងរាល់ឆ្នាំនៅបណ្ឌិត្យសភា CADT មាននិស្សិតត្រូវចុះកម្មសិក្សាផ្ទាល់ចំនួនជិត ៧០០នាក់ ដោយត្រូវសរសេររបាយការណ៍ស្តីពីការចុះកម្មសិក្សារៀងៗខ្លួន ដើម្បីយកមកការពារបញ្ចប់ឆ្នាំសិក្សា។ ខណៈដែលជាគោលការណ៍របស់បណ្ឌិត្យសភា CADT ក្នុងមួយក្រុមហ៊ុនមិនអនុញ្ញាតឱ្យមាននិស្សិតចុះកម្មសិក្សាលើសពី ៣នាក់ ដាច់ខាត ក្នុងករណីឈ្មោះប្រធានបទនៃគម្រោងចុះកម្មសិក្សាដូចៗគ្នា។ ក្នុងមួយឆ្នាំគិតជាមធ្យម បណ្ឌិត្យសភា CADT ត្រូវការការចូលរួមពីក្រុមហ៊ុនចំនួនយ៉ាងតិចបំផុត ១០០ក្រុមហ៊ុន ឬស្ថាប័នផងដែរ។ ដំណោះស្រាយគឺបណ្ឌិត្យសភា CADT បានបង្កើតឱ្យមានមជ្ឈមណ្ឌលការងារ ក្នុងគោលបំណងពង្រឹងនិងពង្រីកនូវកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន និងស្ថាប័នជារៀងរាល់ឆ្នាំ ព្រមទាំងមានការជួយជ្រោមជ្រែងពីថ្នាក់ដឹកនាំនៃបណ្ឌិត្យសភា CADT ផងដែរ ព្រោះកត្តាចុះកម្មសិក្សាផ្ទាល់នៅតាមក្រុមហ៊ុន និងស្ថាប័ន គឺជាការធានាបាននូវគុណភាពក្នុងការសិក្សារបស់និស្សិតតាមរយៈការវាស់ស្ទង់ពីសមត្ថភាពការងាររបស់និស្សិត និងចូលរួមផ្តល់ការវាយតម្លៃយ៉ាងយកចិត្តទុកដាក់ពីក្រុមហ៊ុន និងស្ថាប័នផងដែរ។

ចាប់ផ្តើមដំបូងបណ្ឌិត្យសភាCADT មានកង្វះខាតធនធានមនុស្សដែលមានជំនាញកម្រិតខ្ពស់ (Expertise gap) និងការខ្វះខាតធនធានសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ក្នុងវិស័យបច្ចេកវិទ្យាទំនើបៗ។ ប៉ុន្តែចាប់ពីឆ្នាំ ២០១៨មក បណ្ឌិត្យសភា CADT បានបញ្ជូននិស្សិត គ្រូបង្គោល និងអ្នកស្រាវជ្រាវទៅសិក្សាថ្នាក់បណ្ឌិត និងបរិញ្ញាបត្រជាន់ខ្ពស់ បានសរុបចំនួន ៣៣រូប គិតត្រឹមឆ្នាំ២០២៦ ក្រោមគម្រោងសហប្រតិបត្តិការរវាង **ក.ប.ទ.** និងស្ថានទូតបារាំង ដើម្បីបង្កើនធនធានមនុស្សឱ្យត្រូវជំនាញ ចំគោលដៅ និងដោះស្រាយបញ្ហាគម្លាតឌីជីថល។

IV. ទិសដៅបន្ត

បណ្ឌិត្យសភា CADT នឹងដើរតួនាទីជាគ្រឹះស្ថានបណ្តុះបណ្តាលគន្លឹះ និងជាសេនាធិការរបស់ **ក.ប.ទ** ក្នុងការអនុវត្ត "ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍ជំនាញឌីជីថល ២០២៤-២០៣៥ (Digital Skill Development Roadmap 2024-2035)" ក្នុងការសម្រេចឱ្យបាននូវការបណ្តុះបណ្តាលធនធានមនុស្សក្នុងជំនាញឌីជីថល និងបណ្តុះបណ្តាលកម្រិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងថ្នាក់បណ្ឌិត តាមរយៈការរៀបចំផែនការសកម្មភាពការងារជាអាទិភាពសំខាន់ៗដូចខាងក្រោម៖

- ជ្រើសរើសនិស្សិតចូលសិក្សាថ្នាក់បរិញ្ញាបត្រចំនួន ៣០០នាក់ ក្នុងមួយឆ្នាំ ដែលក្នុងនោះជ្រើសរើសនិស្សិត អាហារូបករណ៍ទេពកោសល្យឌីជីថលតេជោចំនួន ១៥០នាក់ និងនិស្សិតបង់ថ្លៃសិក្សាចំនួន ១៥០នាក់
- ជំរុញ និងដាក់ឱ្យនិស្សិតប្រើប្រាស់លើប្រព័ន្ធគ្រប់គ្រងនិស្សិត ដែលអាចឱ្យនិស្សិតអាចទាញយកទិន្នន័យពីប្រវត្តិនៃការសិក្សាបានដោយខ្លួនឯងដែលជួយសម្របសម្រួលលើឯកសារចាំបាច់មួយចំនួន ដូចជា ព្រឹត្តិបត្រពិន្ទុជាដើម...។
- បន្តធ្វើកំណែទម្រង់លើកម្មវិធីសិក្សាថ្មីក្នុងមហាវិទ្យាល័យសម្រាប់ការសិក្សារបស់និស្សិត
- បន្តជំរុញឱ្យនិស្សិតចូលរួមសិក្ខាសាលាប្រចាំសប្តាហ៍ដែលរៀបចំដោយដេប៉ាតឺម៉ង់ នៃវិទ្យាស្ថានបច្ចេកវិទ្យាឌីជីថល និងមជ្ឈមណ្ឌលការងារ
- បន្តអនុវត្តកម្មវិធីអ្នកស្ម័គ្រចិត្តបច្ចេកវិទ្យាឌីជីថលកម្ពុជា ដែលជាកម្មវិធីមួយអាចឱ្យនិស្សិតចុះទៅបណ្តុះបណ្តាលពីបច្ចេកវិទ្យាឌីជីលជូនដល់សិស្សានុសិស្ស លោកគ្រូ/អ្នកគ្រូនៅតាមវិទ្យាល័យជាពិសេស គឺក្នុងគោលបំណងបញ្ជ្រាបវិស័យបច្ចេកវិទ្យាឌីជីថលទៅកាន់សិស្សានុសិស្សដែលកំពុងរៀននៅវិទ្យាល័យ
- អញ្ជើញសាស្ត្រាចារ្យឯកទេសពីសាកលវិទ្យាល័យដៃគូក្នុងតំបន់និងអន្តរជាតិ ដើម្បីពង្រឹងគុណភាពបណ្តុះបណ្តាល
- កែសម្រួលកម្មវិធីសិក្សាថ្មីដោយបន្ថែម និងធ្វើបច្ចុប្បន្នភាពមុខវិជ្ជាស្នូលសំខាន់ៗ ដើម្បីបង្កើនសមត្ថភាពស្រាវជ្រាវដល់និស្សិត និងការធ្វើគម្រោងរួម (Capstone Project)
- ពង្រឹងទំនាក់ទំនងដៃគូសហការ ដើម្បីសម្របសម្រួលនិស្សិតក្នុងការស្វែងរកឱកាសការងារ និងការចុះកម្មសិក្សានៅតាមបណ្តាក្រុមហ៊ុនផ្សេងៗ និងបង្កើនឱកាសក្នុងការផ្លាស់ប្តូរបទពិសោធសិក្សាជាមួយសាកលវិទ្យាល័យបរទេស
- សិក្សាស្រាវជ្រាវពីស្ថានភាពនិងវាយតម្លៃភាពរួចរាល់ផ្នែកសីលធម៌បញ្ញាសិប្បនិម្មិត តម្រូវការនៃហេដ្ឋារចនាសម្ព័ន្ធមន្ទីរពិសោធ និងការស្រាវជ្រាវគោលនយោបាយពាក់ព័ន្ធការអភិវឌ្ឍបញ្ញាសិប្បនិម្មិតនៅកម្ពុជា
- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធមន្ទីរពិសោធទិន្នន័យនិងបញ្ញាសិប្បនិម្មិត

- សិក្សា ស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍លើវិទ្យាសាស្ត្រទិន្នន័យនិងបញ្ញាសិប្បនិម្មិត
- បង្កើត និងធ្វើឱ្យប្រសើរឡើងកម្មវិធីសិក្សាលើជំនាញវិទ្យាសាស្ត្រទិន្នន័យនិងបញ្ញាសិប្បនិម្មិតរៀបចំការិយាល័យផ្ទេរបច្ចេកវិទ្យា និងជំរុញការសហការផ្ទេរបច្ចេកវិទ្យា ទៅវិស័យសាធារណៈនិងវិស័យឯកជន
- អនុវត្តគម្រោងអាហារូបករណ៍ដើម្បីបញ្ជូននិស្សិត និងអ្នកស្រាវជ្រាវទៅបន្តការសិក្សាថ្នាក់បណ្ឌិតនៅប្រទេសបារាំង និងប្រទេសនានា
- ពង្រឹងនិងពង្រីកសមត្ថភាពស្រាវជ្រាវនិងនវានុវត្តន៍តាមរយៈការសហការស្រាវជ្រាវ និងនវានុវត្តន៍ជាមួយសាកលវិទ្យាល័យដៃគូ
- បង្កើនដៃគូសហការជាតិ និងអន្តរជាតិ សម្រាប់ការងារស្រាវជ្រាវ នវានុវត្តន៍ និងផ្ទេរបច្ចេកវិទ្យា។

V. សន្និដ្ឋាន

បណ្ឌិត្យសភា CADT នឹងបន្តបំពេញបេសកកម្មរបស់ខ្លួន ដើម្បីក្លាយទៅជាមជ្ឈមណ្ឌលឧត្តមភាពសម្រាប់ការអប់រំ ស្រាវជ្រាវ និងនវានុវត្តន៍កម្រិតខ្ពស់លើបច្ចេកវិទ្យាឌីជីថលនៅកម្ពុជា ដែលមានការទទួលស្គាល់ទាំងក្នុងកម្រិតជាតិ និងតំបន់ ផ្តោតលើការបណ្តុះបណ្តាលមូលធនមនុស្សឆ្នើម ប្រមូលផ្តុំដោយសាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងអ្នកនវានុវត្តន៍ ដើម្បីលើកកម្ពស់សមត្ថភាពស្រាវជ្រាវនិងនវានុវត្តន៍របស់កម្ពុជា ព្រមទាំងផ្តល់ការបណ្តុះបណ្តាលថ្នាក់ក្រោយឧត្តមសិក្សា ដែលពឹងផ្អែកលើការស្រាវជ្រាវ ដល់គ្រូបង្គោលមកពីគ្រឹះស្ថានឧត្តមសិក្សានានា សំដៅចូលរួមចំណែកពង្រឹងគុណភាពអប់រំជំនាញឌីជីថលនៅកម្ពុជា គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងរដ្ឋាភិបាលឌីជីថល។